គ្រោះធំរបស់អ្នកប្រុសទីពីរ ហួត ខេមរិទ្ធិ

...ក្នុងពេលដែលឪពុកនិងកូនកំពុងជួបគ្នាស្ងាត់ៗក្នុងមជ្ឈមណ្ឌល កីឡា វាយកូនគោលដើម្បីបង្ហាញភស្តុតាងពីគម្រោងការស្រមោល«រតនៈសោភ័ណ»នោះ លេខាប៉េងដែលមិនត្រូវបាន ហួត ស៊ីវ ហៅទៅជាមួយកាន់តែឆ្អែឆ្អា។

សម្រាប់មនុស្សមានពុតត្បុតម្នាក់ ដែលបានព្យាយាមលាក់កំបាំងគម្រោងការខ្លួនយ៉ាងម៉ត់ចត់អស់ពេលជាច្រើនឆ្នាំមក ថ្មីៗនេះបណ្ដោយឲ្យសល់ដានខ្លះហើយខ្លួនប្រឹងប្រែងទៅកាក់ពន្យល់ខាង ហួត ស៊ីវមុនក្នុងបំណងយកប្រៀបជាងកូនចិញ្ចឹមដែលនៅឆ្ងាយបែរជាឥឡូវមកឃើញឪកូនគេណាត់ជួប គ្នាស្ងាត់ៗហើយហាមប្រាម មិនឲ្យអ្នកណាចូលទៅជិតទៀត មិនឲ្យប៉េងស្លន់ស្លោម្ដេចនឹងបាន?

គេហើបមាត់មួយៗសួរពួកដៃជើងតែចិត្តកំពុងតឹងចង់ផ្ទុះ៖

«ស៊ើបមិនដឹងថាឪកូននោះនិយាយគ្នារឿងអីទេ?»

«អត់ទេទ្រា! លោកអគ្គដាក់មនុស្សរាយការពារ២០ម៉ែត្រជុំវិញនោះគ្មានអ្នកណាចូល ទៅជិតបានទេ។អ្នកប្រុសទីពីរដូចជាកាន់អ្វីមួយមកផង! មើលទៅដូចជាឯកសារបិទជិតទ្រា!»

ប៉េងជ្រួញចិញ្ចើម គេនឹកហើយនឹកទៀតនៅតែនឹកមិនឃើញថាតើ ខ្លួនមានឯកសារចំណុចខ្សោយណាមួយដែលភាគីខេមរិទ្ធិអាចនឹងយកទៅ បង្ហាញ ហួត ស៊ីវ បាន? ទោះគិតយ៉ាងណាក៏នៅតែគិតមិនចេញទើបចិនចំណាស់សួរបន្ថែម៖

«ប៉ុន្មានថ្ងៃនេះ ហួត ស៊ីវ មានអីប្លែកខ្លះ? គាត់មានជួបអ្នកប្រុសទីពីរទេ?»

«អត់ទេទាន! តែយប់មិញ បីនាក់ហ្នឹងនៅក្នុងពេទ្យជួប ប៉ែន ពេជ្រ!»

ប៉េងងើបមុខខ្វាច់។ គាត់មិនរកសំណួរសួរទាន់ទេ តែទឹកមុខគាត់គឺភ្ញាក់ផ្អើលធ្វើឲ្យកូនចៅនោះខំងក់ក្បាលបញ្ជាក់ ថាអ្វីដែលខ្លួននិយាយគឺច្បាស់ការណ៍ ១០០% ។ ដូច្នេះបុរសចិនមានពុតអស់ពីឆ្ងល់ទៅជាស្លេក គាត់មមីភ្នែកគិតស្របពេលដៃជើងបន្ថែមរបាយការណ៍៖

«លោកអគ្គទៅតែឯងពាក់ខោអាវបន្លំខ្លួនហៅតាក់ស៊ីមកដឹក គ្មានអ្នកណាទៅជាមួយទេ! គ្នាយើងតាមដល់ពេទ្យឃើញគាត់ចូលក្នុងបន្ទប់ឧកញ៉ា ប៉ែន ពេជ្រ បានស្រួលដូចមានគេរៀបចំឲ្យ ហើយបន្ទាប់មកអ្នកប្រុសទីពីរក៏ទៅតាមក្រោយហើយបីនាក់នោះសំងំ ក្នុងហ្នឹងជិតពីរម៉ោងទើបអ្នកប្រុសទីពីរចេញមកផ្ទះ ប៉ែន ពេជ្រ មុន។ ជាងម្ភៃនាទីក្រោយលោកអគ្គចេញម្ដងតែគាត់មិនទៅផ្ទះទេ!»

«គាត់ទៅណា?» ប៉េងសួរដោយតក់ក្រហល់។
«គាត់ទៅហាងបាយថៃមួយឈ្មោះថាយីនយុន! គាត់ទៅជួបប្រពន្ធ ប៉ែន ពេជ្រ!»

ប៉េងបើកភ្នែកដ៏តូចរបស់គាត់អស់មួយទំហឹង ព្រោះគិតមិនយល់នឹងភ្ញាក់ផ្អើលចំពោះហេតុការណ៍ដែលកើតឡើងជាប់ៗគ្នា នេះ។ ពេលនោះដៃរដៃជើងនៅតែមិនទាន់អស់ពាក្យរាយការណ៍ គេនិយាយមកបន្ថែម៖
«ចំណែកព្រឹកមិញនេះ អ្នកប្រុសទីពីរជជែកគ្នាយូរណាស់ជាមួយប៉ាធម៌គាត់ ក្នុងលានកូនគោលជាមួយលោកអគ្គ!»
ប៉េងកាន់តែស្តាប់គេកាន់តែភ័យ។ ម្ភៃឆ្នាំហើយមិនដែលមានអារម្មណ៍ថាលោកអគ្គរបស់គេមានគម្លាតឆ្ងាយ ពីគេដល់ថ្នាក់នេះឡើយ។ ហេតុអ្វីគាត់ធ្វើរឿងជាច្រើនក្នុងថ្ងៃតែមួយហើយមិនឲ្យខ្លួនដឹង និងចូលរួមផង?។
តើនោះជាអ្វីបានជាអាថ៌កំបាំងម្ល៉េះ តែ ហួត ខេមរិទ្ធិ បែរជាមានចំណែកក្នុងរឿងនោះទៅវិញ។ ឬមួយសម្តីយើងដែលខំនិយាយលាបពណ៌វានោះ ហួត ស៊ីវ ស្តាប់មិនចូលត្រចៀកទេ? គាត់ងើបមុខសួរដៃជើងជំនិតបន្តភ្លាម៖
«ម្តាយអ្នកប្រុសទីពីរនៅឯណា?»
«លោកអគ្គទុកនៅផ្ទះធំ មានអ្នកតាមឃ្លាំមើលម្ភៃបួនម៉ោង! បើមើលពីក្រៅទៅ អាចយល់ថាគាត់ថាបង្ខាំងស្រីនោះទុក! តែបើគិតឲ្យដល់ទៅដូចជាចង់ការពារម្តាយអ្នកប្រុសទីពីរពីពួកយើងទៅវិញ!»
ប៉េងដាក់បង្គុយប៉ុកទៅលើសាឡុងទាំងអស់កម្លាំងល្វើយ។
សម្តីរិទ្ធិកាលពីរាត្រីនៅឯក្រោមផ្ទះគាត់ លាន់រំលឹកមកវិញក្នុងអារម្មណ៍តែម្នាក់ឯង៖
«ពូប៉េង! ប៉ាខ្ញុំអត់ល្ងង់ជាងពូទេ! បើពូពិតជាឲ្យតម្លៃមនោសញ្ចេតនាច្រើនឆ្នាំមកនេះមែន ពូឈប់ទៅ!»

នៅពេលបេះដូងមនុស្សមានល្បិចកំពុងតឹងចប់ កូនចៅម្នាក់ស្ទុះមកខ្សឹប៖
«យើងចាប់បានកូនស្រីពៅ ប៉ែន ពេជ្រ អាទ្រា!»
ប៉េងបើកភ្នែកធំៗ។ ដៃជើងនោះនិយាយបន្ត៖
«មេធាវីពៅបញ្ញា!»
ប៉េងសម្លឹងម្នាក់នោះភ្លែព្រោះស្ទើរមិនជឿនឹងត្រចៀក។

«ព្រឹកមិញលោកអគ្គឲ្យពួកខ្ញុំល្បាតនៅជុំទីពីរ មិនឲ្យចូលទៅក្នុងលានកូនគោលបានទេ! ស្រាប់តែពេលអ្នកប្រុសទីពីរចូលផុតទៅក្នុងស្រីនោះជិះឡានមកតាម ពីក្រោយ ស្ទីលដូចតាមដានអ្នកប្រុសរិទ្ធិ។ ពេលអ្នកប្រុសរិទ្ធិគ្រាលោកអគ្គចុះពីឡាន ក៏លើកទូរសព្ទមកចុចប្រុងថតរូប ពួកខ្ញុំក៏ចាត់ការតែម្តង!»
ប៉េងសួរបន្ទាន់ខ្សឹបៗ៖
«ទុកវានៅឯណា?»
«នៅឃ្លាំងទួលគោកអាទ្រា! ពួកខ្ញុំប្រុងជម្រាបអ្នកប្រុសរិទ្ធិនិងលោកអគ្គដែរ! តែថាចាំសួរយោបល់អាទ្រាសិនគួរធ្វើម៉េច?»
«ចាំអីទៀត?»
លេខាប៉េងចេញដំណើររឹងដើម្បីទៅមើលស្ថានភាពគ្រាប់អុកសំខាន់ដែល ខ្លួនកំពុងមានក្នុងដៃ។ទោះបីយ៉ាងណាគេដឹងថា ហួត ខេមរិទ្ធិ និង ហួត យុត្តនា មិនអាចលោតរំលងគ្រាប់អុកមួយនេះបានឡើយ។ នៅក្នុងឡានតាមផ្លូវឆ្ពោះទៅកាន់ឃ្លាំងនោះគេញញឹមម្នាក់ឯងក្នុង ចិត្ត៖
«នៅសុខៗបានមេធាវីនោះមកនៅក្នុងដៃមិនចាំបាច់ប្រឹង??? ទេវតាមិនឲ្យយើងចាញ់ទេមើលទៅ! អ្វីៗគឺមេឃបានរៀបចំឲ្យយើងស្រេចហើយ!! មេឃឈរខាងយើង! អាហ៊ា??? អ្វីៗជិតបានដល់ដៃយើងហើយទេដឹង! អាហ៊ានៅលើមេឃកំពុងជួយខ្ញុំមែនអត់? ហាសហា»
ទោះយ៉ាងណានៅពេលទ្វារឃ្លាំងត្រូវបើក លេខាចំណាស់បែរជាខកចិត្ត។ ស្រីតូចសក្ខណាទោះបីរួមឈាមជាមួយពៅបញ្ញាមានទម្រង់ស្រដៀងគ្នាសឹងថា៨០% ប៉ុន្តែបុរសចិនគ្រាន់តែក្រឡេកក៏ដឹងស្រេចហើយថាស្រីតូចដែលដេក ស្ងៀមនេះមិនមែនជា មេធាវីសំណព្វចិត្តអ្នកប្រុស ហួត ស៊ីវ ទាំងទ្វេឡើយ។
គេចងចិញ្ចើមចាកចេញពីឃ្លាំងមកក្រៅវិញ ព្រោះមិនចង់និយាយអ្វីឲ្យឮសំឡេងនៅមុខអ្នកត្រូវគេចាប់។
«មិនមែនពៅបញ្ញាទេ ពួកអាបំបង់បាយ!»
«តែ.....តែនេះអាទ្រា!»
ពួកដៃជើងប៉េងហុចកាបូបពៅបញ្ញានិងទូរសព្ទនាងមកឲ្យបុរសចំណាស់។ ប៉េងលូកដៃទៅរើមើលទាំងនាមប័ណ្ណនិងចុចទូរសព្ទដៃរបស់នាងហើយរេ ភ្នែកដែលគ្មានត្របកតែមានល្បិចមួយរយជំពូកនោះគិតចុះឡើង។

ប៉េងគិតមិនទាន់ចេញ ស្រាប់តែអេក្រង់ទូរសព្ទលើដៃគេ លេចចេញនៅលើអេក្រង់ថា«បងរិទ្ធិ»។ លេខាប៉េងបើកភ្នែកធំៗព្រោះភ្ញាក់ផ្អើល តែគេជាមនុស្សមានល្បិចច្រើនឆ្នាំមកហើយ ស្ថានការណ៍លឿនបែបណាគេ នៅតែអាចបត់បែនទាន់។ គេងាកធ្វើដៃឲ្យសញ្ញាកូនចៅទាំងអស់ស្ងៀមស្ងាត់ស្របពេលដែល សំឡេងCall ហៅរបស់ជំនួយការរិទ្ធិលាន់មកកាន់តែខ្លាំងជាងមុន។ ប៉េងលូកដៃចុចទទួលភ្លាមហើយស្ងាត់មិនហ៊ានសូម្បីតែដកដង្ហើមឲ្យឮ ព្រោះខ្លាចគេចំណាំបាន។

«អ្នកនាង!? អ្នកនាង?»

ប៉េងចុចបិទវឹង ហើយអ្វីម្យ៉ាងថ្មីលេចឡើងក្នុងគំនិតគេ។ គេញញឹមយ៉ាងសាហាវធ្វើឲ្យកូនចៅគ្រប់គ្នា សម្លឹងភ្លឹះៗព្រោះមិនយល់សាច់រឿង។ លេខាប៉េងនិយាយមួយៗ៖

«អស់ពេលហើយ! ឆាកចុងក្រោយមកដល់ហើយវ៉ី! បើពួកវាមិនស្លាប់គឺយើងស្លាប់! រៀបគ្នាយើងទៅ ទៅចាប់អ្នកប្រុសទីពីរមកម្នាក់ទៀត! កំដរស្រីនេះ»

កូនចៅងើមង៉ាមនិមិត្តតែឮបញ្ជានេះ គេនិយាយតបរដាក់រដុប៖

«ចា...ចាប់....ចាប់អ្នកប្រុសទីពីរ???»

គ្រាន់តែឮនិងឃើញអាកប្បកិរិយារបស់ពួកវាដឹងស្រេចហើយថា ពួកគេមិនហ៊ានប្រឡែងជាមួយហ្លួត ខេមរិទ្ធិ ស្រេចទៅហើយ តែប៉េងលើកទូរសព្ទពៅបញ្ញាបង្ហាញពួកវា៖

«មានរបស់នេះក្នុងដៃ! ពួកឯងមិនបាច់ខ្លាចទេ!»

ពួកនោះតាមសម្លឹងទូរសព្ទដែលជាកម្មសិទ្ធិរបស់មេធាវីរូបល្អ។ បន្ទាប់មកចាប់ផ្ដើមយល់ពីអ្វីដែលប៉េងចង់និយាយ ហើយងក់ក្បាលផ្ងក់ៗ។

ប៉េងសង្កត់ពាក្យ៖

«ធ្វើឲ្យស្អាត កុំឲ្យបែកការវ៉ី!»

គេដើរត្រលប់ទៅអើតមើលនារីដែលដេកសន្លប់ស្តូកស្តឹង។ គំនិតសប្បាយមួយលេចឡើងក្នុងចិត្តលេខាប៉េង៖

«ស្រីនេះមិនមែនពៅបញ្ញាទេ! តែក៏ល្អព្រោះវាក៏ជាកូនអា ប៉ែន ពេជ្រ ទោះវាដើរមិនរួចក៏ត្រូវវារមកសែនផ្នូរអាហ៊ាអញដែរ»

គាត់បោះទូរសព្ទទៅឲ្យកូនចៅហើយបន្ថែម៖

«បើពេលនេះឪកូនគេកំពុងនៅកំពង់ស្ពឺលេងគោល ហោចណាស់ក៏មួយម៉ោងទៀតបានអាចត្រលប់មកដល់ភ្នំពេញ មុនពេលអ្នកប្រុសទីពីររកឃើញពៅបញ្ញា! ត្រូវចាត់ការឲ្យបានមុន!»

ប៉េងដឹងថា រិទ្ធិកំពុងនឹកចម្លែកដែលទូរសព្ទរបស់ចៅហ្វាយស្រីតូចមានអ្នកទទួល បែរជាគ្មានអ្នកឆ្លើយដូច្នេះ ចង់រកឱកាសដ៏ខ្លីនេះចាត់ការគេឲ្យហើយជាវិធីផ្សងគ្រោះថ្នាក់ តែហាក់មានប្រសិទ្ធភាពច្រើន។

មិនដល់ពីរម៉ោងផង ដៃជើងប៉េងរៀបផែនការហើយរាយគ្នារួចរាល់ ទើបចាប់ផ្ដើមលើកទូរសព្ទមេធាវី ដែលម្ចាស់ខ្លួនមិននៅទីនេះហើយវាយត្រលប់ទៅរកលេខរបស់អ្នកប្រុស ទីពីរ៖
«អាឡូ?»
រិទ្ធិលើកទទួលទាំងដៃម្ខាងនៅបើកឡាននៅឡើយ។
ប៉ុន្តែស្ងាត់ច្រៀបគ្មានសំឡេងតបធ្វើឲ្យចិត្តនាយកាន់តែអន្ទះសា។
«អ្នកនាង?»
ជនទុច្ចរិតសើចកក្អឹកបញ្ឈឺអ្នកប្រុសទីពីរធ្វើឲ្យនាយភ្ញាក់ស្ទើររបូតទូរសព្ទពីដៃ។
គេរវើ្ភកសម្លឹងដងផ្លូវរលះរលាំង គឺគេនៅឆ្ងាយពីភ្នំពេញណាស់ ប្រសិនបើនាងមានរឿងអ្វីមែន តើបានអ្នកណាជួយនាង។
គេរវើ្ភកទៅរកទូរសព្ទមួយផ្សេងទៀតព្រោះបន្ទាន់នេះគឺនឹកឃើញដល់ យុត្តនា ប៉ុន្តែជនពាលនៅក្នុងទូរសព្ទបានត្រៀមរួចរាល់ហើយវានិយាយមកបន្ថែម មុត៖
«ខ្ញុំកំពុងតាមដានឯង ហួត ខេមរិទ្ធិ! កុំកម្រើកដៃហើយកុំទាក់ទងអ្នកណាទាំងអស់បើមិនចង់មកទទួលសពពៅបញ្ញា!»
អ្នកប្រុសទីពីរជាន់ហ្វ្រាំងង៉ឹត! បញ្ចេញសំឡេងរថយន្តដែលអូស ស្ទើរធ្លាយបេះដូងដ៏តឹងណែន។
ទូរសព្ទនាងនៅនឹងពួកវាទៅហើយ នៅមានអ្វីនិយាយទៀត។ សំខាន់តើនាងកំពុងយ៉ាងណាទៅហើយ? នេះជាសំណួរដែលបេះដូងបុរសម្នាក់លោតចេញមុនគេ ព្រោះថាស្រីនោះជាស្រីដែលគេស្រលាញ់ និងគោរពទុកដូចវត្ថុបរិសុទ្ធ មានតម្លៃមួយក្នុងជីវិតនេះ។
សំឡេងនាយនៅតែនឹងន៖
«ឯងត្រូវការអី?»
ជនពាលតបវិញរឹង៖
«បកឡានមកក្រោយវិញ! ផ្លូវលំចូលភូមិក្បែរវត្ត មានស្រះទឹកមួយ ឯងបត់មកស្ដាំ៧គីឡូ! ចាំយើងទាក់ទងទៀត!»

រិទ្ធិសែនសៅហ្មង ចិត្តនឹកភ្នកមុនគេពីសុវត្ថិភាពស្រស់ស្រីតែគេនៅតែសួរបញ្ជាក់៖
«ទាល់តែខ្ញុំនិយាយជាមួយនាងមួយម៉ាត់សិន!»
«និយាយស្អី!??? បើសន្លប់ឈឹងហើយហ្នឹង?»ជនពាលបញ្ចប់ដោយសំណើចក្អាកក្អាយមិនខ្វល់ថា បេះដូងសុភាពបុរសក្តៅរោលរាលដោយក្តីអាណោចអាធ័មស្រីតូចនិងអន្ទះសា។ គេទប់ចិត្តសង្កត់ពាក្យតប៖
«ធ្វើម៉េចឲ្យខ្ញុំជឿសម្តីឯងអញ្ចឹង!?»
«ស្រេចឯងគិតទេ ហួត ខេមរិទ្ធិ! បើឯងយឺតបន្តិច ឯងកុំថាយើងមិនបានប្រាប់! ហើយបើឯងចង់ដឹងសាកលើកទូរសព្ទចុចទៅអ្នកណាមួយភ្លាមទៅ ក្បាលនាងនេះនឹងបែកភ្លាម!»
ទីតៗៗៗ.....
ជនពាលបិទទូរសព្ទបាត់ទៅហើយតែវាបន្សល់នូវភាពតឹងតែងនិងតក្កមា ហ៊ុមព័ទ្ធអ្នកប្រុសទីពីរ។ម្តងនេះលេខាប៉េងគិតត្រូវព្រោះថាមនុស្ស ឆ្លាតបែបណាក៏ដោយ គេនៅតែមិនអាចឆ្លាតបានទៀតឡើយនៅពេលដែលមនុស្សគេស្រលាញ់កំពុងលង់ ទឹកនៅចំពោះមុខ។ ទោះបីលោតចុះទៅត្រូវនាងតោងស្លាប់ ក៏គេនៅតែលោត។

អ្នកប្រុសទីពីរបន្ថយល្បឿន អ្នករវៃភ្នែកសម្លឹងតាមដងផ្លូវ។ អ្នកសួរខ្លួនឯងដោយតក់ក្រហល់៖
«ពួកវាជាអ្នកណា នៅម្តុំៗនេះដែរ? បានជាយើងមិនអាចរំលងភ្នែកវាសូម្បីតែលើកទូរសព្ទមកនិយាយ?»
«យើងគ្មានលុយជាប់ខ្លួនទេ ដូច្នេះវាមិនមែនចង់បានលុយឡើយ អញ្ចឹងតើវាចង់បានអ្វី?»
អ្នកប្រុសដឹងថាគ្រោះថ្នាក់គឺនៅជិតបង្កើយ។
.....អ្នកណាទៅកំពុងលេងល្បែងនេះ? គេហ៊ានដល់ថ្នាក់ចាប់មនុស្សដូច្នេះហើយ បើលុយមិនចង់បានផង តើគេចង់បានអ្វីវិញទៅ?
គេដៀងភ្នែកសម្លឹងទៅរកទូរសព្ទ។
....សូម្បីតែចង់ដឹងឡើងវិញថាអំបាញ់មិញនេះពួកវាយកលេខអីខលមក សូម្បីតែចង់ដឹងថានាងយ៉ាងណាទៅហើយ ឲ្យនាងនិយាយតែបន្តិច ក៏អត់? តើអ្នកគួរធ្វើតាមពួកវាឬជម្នះចិត្តស្វែងរកការពិត? លក្ខខណ្ឌយកអាយុជីវិតស្រីស្រស់មកជាការភ្នាល់បញ្ញាពិតជាមិនអាច ទៅរួចឡើយសម្រាប់បុរសម្នាក់នេះ។ នាយងាកមើលឆ្វេងស្តាំរកគោលដៅសាជាថ្មីដោយអន្ទះសា ហើយភ្លាមនោះ.....ឡានទ្រុងខ្មៅមួយបង្ហាញខ្លួនឡើង។

.....ឬមួយថាពួកវាពិតជាកំពុងនៅ ពីក្រោយអ្នកមែន?
ហួត ខេមរិទ្ធិ ភ្ញាក់ក្រញាង។
អញ្ចឹងហើយបានជាសូម្បីចុចទូរសព្ទរកអ្នកណាក៏មិនកំបាំងពីពួកនេះបាន។
រិទ្ធិបន្ថយល្បឿនរង់ចាំវា ដឹងអីស្រាប់តែវា បោលហួសទៅមុខ តែនៅកញ្ចក់ខាងក្រោយ
មនុស្សពាក់ម៉ាសម្នាក់បានលើកកាបូបយួររបស់ ពៅបញ្ញាបង្ហាញនាយ។
.....រឹតតែច្បាស់ហើយ.....ព្រោះកម្មសិទ្ធិរបស់នាងគេនៅចំណាំបាន។

គេក្តុកក្តួលចិត្តឈប់គិតពីសុវត្ថិភាពខ្លួនឯង បែរជាគិតតែពីស្រីតូចថា តើពេលនេះនាងទៅជាយ៉ាងណាទៅហើយ?
រិទ្ធិរ៉ឺយ៉េឡានបកក្រោយវឹងហ៊ុយដីទ្រលោមឆ្ពោះទៅរកទិសដៅដែលពួកជនពាលបានបង្ហាញមុននេះ។
គេបើកយឺតៗតាមពីក្រោយរថយន្តទ្រុង រហូតដល់ឃ្លាំងចាស់មួយ ដែលទំនងជាត្រូវបានគេទុកចោលជាយូរមកហើយផ្អែកទៅលើស្មៅនិងដើម រុក្ខជាតិដុះបិទបាំងស៊ុបទ្រុប។
....ស្ថានភាពរបស់អ្នកប្រុសទីពីរពេលនេះគឺគ្រោះថ្នាក់ក្នុងភាគរយដ៏ ខ្ពស់។.... តែមនុស្សឆ្លាតប៉ុណ្ណា ក៏ដោយ នៅពេលដែលមនុស្សស្រីដែលខ្លួនស្រលាញ់បានស្ថិតនៅក្នុងដៃគេទៅហើយ គេក្លាយជាភាគីចាញ់ប្រៀបដោយសត្យានុម័ត។
គេចង់ឃើញនាងតែក្នុងរវាងមួយដង្ហើមមិនខ្វល់ថាខ្លួនកំពុងស្ថិតក្នុងសភាពបែបណា ហើយអាចប្រឈមនឹងអ្វីឡើយ។
...អ្នកប្រុសទីពីរឈានចុះពីរថយន្តជាមួយនិងទូរសព្ទក្នុងដៃ....ឯ មនុស្សបីនាក់ទៀតដែលសុទ្ធសឹងពាក់ម៉ាសជិតឈឹងបានចុះមកពីរថយន្ត ទ្រុងរត់សំដៅនាយក្នុងសកម្មភាពយ៉ាងរហ័ស។
«យកទូរសព្ទមកធ្វើអី?»
ម្នាក់មាឌធំបងជាងគេសម្បុរខ្មៅស្ទុះមកទាញទូរសព្ទដៃពីរិទ្ធិ ហើយបោះវាចោលភូសទៅខ្ទាយព្រាតរោយលើគល់ឈើ ក្រោមរង្វង់ភ្នែកមូលក្លុំរបស់នាយ។
«ធ្វើអញ្ចឹងបានលុយពីណាមកឲ្យឯងកើត?»
អ្នកប្រុសសួរក្នុងចេតនាពន្យារពេលដោយប្រើត្រចៀកស្តាប់មើលសូរសព្ទ ទីនេះឲ្យច្បាស់ព្រមទាំងប្រើភ្នែករេពិនិត្យស្ថានការណ៍ជុំវិញ ខ្លួនប្រយ័ត្នប្រយែង។

ក្រៅពីសត្វចម្រិតយំពីគុម្ពស្មៅសូម្បីសត្វពាហនៈដកដង្ហើមមួយ ត្រឹតក៏អត់មានដែរ។ ភូមិអ្នកស្រុកប្រហែលគ្មានក្បែរៗនេះឡើយ។ ចំណែកអាបីនាក់ ទំនងជាដឹងច្បាស់ ពីយុទ្ធសាស្ត្រអ្នកប្រុសទីពីរបានជាអាម្នាក់ផ្សេងទៀតសើចកក្អៀក ឆ្លើយវិញផូង៖

«អាណាថាពួកអញចាប់ជំរិតយកលុយឯង?»

រិទ្ធិសម្លឹងទៅជនទាំងនោះរកចំណាំក្រែងធ្លាប់ស្គាល់ពួកវា ប៉ុន្តែនឹកមិនឃើញ។ នាយពោលឡើងបន្ត៖

«យើងមិនដែលមានបញ្ហាជាមួយគ្នាទេ! ប្រាប់មកថាចង់បានអី? ចាប់ពៅបញ្ញាមកធ្វើអី?»

ពួកបីនាក់ងាកមើលមុខគ្នាសើចកក្អឹក ធ្វើឲ្យរិទ្ធិទៅជាង៉េមង៉ាម។ តាមស្ថានភាពជាក់ស្តែងអ្នកដឹងថា អ្វីៗនៅអាចគ្រប់គ្រងបាន បានជាហ៊ានឈប់ឡានទៅនៅទីនេះពីក្រោយឡានពួកវា ដោយសារជំនាញវាយការពារខ្លួនដែល ហួត ស៊ីវ ឲ្យកូនប្រុសទាំងទ្វេ បង្វឹកជាប់ខ្លួនតាំងពីតូចៗពួកនេះប្រាំនាក់ទៀតក៏រិទ្ធិអាចស៊ូ បាន ដូច្នេះហើយនៅពេលដែលខ្យល់មួយវូផាត់មកពីក្រោយអ្នកប្រុសក្រឡាស់ ខ្លួនទៅសងមួយជើងវិញមុនពេលដែលកណ្តាប់ដៃអនាមិកបោលមកបម្រុងដាល់ នាយចំសៀតផ្កាស្តាំ ប្រាថ្នាឲ្យអ្នកដួលត្មោលសន្លប់ភ្លាមៗនោះ។

ពិនិត្យស្ថានការណ៍បាន អ្នកដឹងថាមនុស្សទាំងអស់មានប្រាំនាក់ហើយពីរនាក់ដែលលបមកពីក្រោយអំបាញ់មិញ ប្រាកដណាស់ដឹងថាអ្នកមិនមែនជំឡូងមូលបានជាគេប្រើវិធីនេះ។ នៅពេលការវាយប្រហារដំកំសាកឃើញថាទៅមិនរួច ពួកវាស៊ីញ៉ូគ្នាចូលម្តងទាំងប្រាំ ធ្វើឲ្យរិទ្ធិទាល់ច្រកគ្មានអ្វីក្រៅពីតបតវិញ ដើម្បីទាមទាររកពេលចរចា។

មធ្យោបាយការពារខ្លួនរបស់មនុស្សប្រុស ដែលក្នុងនាមជាអ្នកប្រុសទីពីរពិតជាមិនធម្មតាដល់ថ្នាក់ជនពាល ត្រូវងាកមើលមុខគ្នា ព្រោះគ្រប់គ្នាសុទ្ធតែត្រូវដំណំរៀងខ្លួន។ ទីបំផុតម្នាក់ក្នុងចំណោមពួកវាស្រែកកាត់៖

«ឈប់!»

រិទ្ធិឈប់សកម្មភាព។

គេវេភ្នែកមើលពួកម្នាក់ហើយម្នាក់ទៀត ដែលកំពុងឡោមព័ទ្ធខ្លួន។ ភ្នែកទាំងគូភ្លឺមុត ហើយកាយវិការប្រុងប្រយ័ត្នខ្ពស់។ មកដល់ពេលនេះហើយបើនាក់ចង់ចាកចេញទៅវិញគឺវានៅតែមានឱកាសបើ សំអាងលើអាពួក៥នាក់នេះ តែគេសួរខ្លួនឯងវិលខ្វាល់ក្នុងអារម្មណ៍៖

«តើយើងត្រូវឬខុសដែលសុខចិត្តចូលមករូងខ្លា? តាមពិតពួកវាមិនចង់បានលុយហើយឲ្យ

យើងមកមានតែយើងជាគោលដៅរបស់ ពួកវា? បើមិនអញ្ចឹងអំបាញ់មិញវាចង់លបវាយយើងមួយដៃឲ្យដួលធ្វើអី?»
គេរវេភ្នែកសម្លឹងរកមើលតើអ្នកណាម្នាក់ទំនងជាមេគេក្នុងចំណោម ពួកវា តែសម្គាល់ក៏មិនចេញព្រោះសកម្មភាពដូចៗគ្នាហើយបិទម៉ាសដូចៗគ្នា ។
អ្នកប្រុសទីពីរបញ្ឈប់ភ្នែកត្រឹមអាម្នាក់ដែលឃាត់ឲ្យពួកគេឈប់វាយអម្បាញ់មិញ ហើយនិយាយសង្កត់ពាក្យទៅកាន់វា៖
«បើខ្ញុំជាមនុស្សដែលពួកឯងចង់បាន!......លែងនាងទៅ!!»
ទាំងប្រាំនាក់មើលមុខគ្នា។ ម្នាក់ផ្សេងទៀតស្រែកមកត្រជាក់ល្ហឹមពីមាត់ទ្វារ៖
«ឯងអាងអីនិយាយលក្ខខណ្ឌ?»
រិទ្ធិងើបមុខងាកទៅរកជននោះ។
គេទើបតែបង្ហាញខ្លួន ក្បែរទ្វារដ៏ធំពណ៌ត្នោត ហើយចាស់ទ្រុឌទ្រោម។ មុននេះរិទ្ធិមិនបានចាប់អារម្មណ៍ថានោះជាច្រកចេញចូលរបស់ឃ្លាំង ដ៏ស្ងាត់នេះទេ ព្រោះទីនោះចោមព័ទ្ធបិទបាំងដោយស្មៅនិងរុក្ខជាតិដុះឯង វែងៗ ពេក។

អ្នកដែលទើបនឹងមកដល់ប្រកបដោយសម្តីក្រអឺតក្រអោងនោះ បិទបាំងមុខ ត្រឹមម៉ាសមួយផ្ទាំង........តាមធម្មតា បើជាមនុស្សធ្លាប់ស្គាល់គ្នា គឺប្រាកដជាអាចចំណាំបាន មិនពិបាកទេ ។ តែនេះរិទ្ធិពិតជានឹកមិនឃើញពីភិនភាគគេ ថាស្ថិតក្នុងចំណោមមនុស្សដែលខ្លួនធ្លាប់ស្គាល់សោះ ទោះបីសំឡេងហាក់ធ្លាប់បានឮពីមុនមកក្តី។
ទោះយ៉ាងណា គេនៅតែរឹងមាំចំពោះការបង្ហាញវត្តមានរបស់ជននោះ។ អ្នកប្រុសទីពីរឆ្លើយភ្លាម៖
«មនុស្សឯងមិនព្រមបង្ហាញ! ស្អីក៏មិនអាចនិយាយគ្នាបាន! តាមមើលមានតែងាប់រស់ម្ខាងៗប៉ុណ្ណឹង!»
ថាចប់កំលោះយើងលូកដៃលើកទូរសព្ទមួយទៀតចេញមក ហើយដៃចាប់ផ្តើមចុចទាំងទឹកមុខនឹងន ឯភ្នែកមិនបានដកចេញពីសត្រូវមួយប៉ប្រិចឡើយ។ សកម្មភាពនេះធ្វើឲ្យបុរសដែលទើបចេញមកក្រោយគេបើកភ្នែកគ្រលួងគំហក ស្ទើរបែកអាកាស។
«ឈប់ភ្លាម! បើមិនចង់ឲ្យស្រីនោះងាប់!»
រិទ្ធិរក្សាជំហរ គេនិយាយវិញដោយមុខស្មើក្នុងពេលដែលបង្អង់ពីប៊ូតុងទូរសព្ទ៖

«បង្ហាញនាងសិនមកអញ្ចឹង!»
បុរសនោះងាកទៅឆ្វេង នាំក្រសែភ្នែកអ្នកប្រុស ទីពីរឲ្យរេទៅកាន់ទីនោះដែរ។
កូនឡានមួយចតស្ងៀមនៅក្បែររបងស៊ុបទ្រុបតាំងពីពេលណាមកមិនដឹង ហើយមុននេះនាយមិនបានចាប់អារម្មណ៍ឃើញដោយសារថាផ្ដោតតក់ស្លុតយ៉ាង អាក្រក់តាំងពីទើបនឹងបត់ឡានចូលមកតាមពួកវាម្ល៉េះ។
ពីត្រង់នេះទៅ អ្នកអាចឃើញរូបរាងស្រីម្នាក់អង្គុយនៅបាំងក្រោយ ក្នុងស្ថានភាពស្ងៀមមិនកម្រើក។បើមិនស្លាប់ក៏សន្លប់ដែរ តែដោយសារពីទីនេះទៅហាក់ឆ្ងាយពេកក្នុងការពិនិត្យឲ្យច្បាស់ ណាមួយនាងអង្គុយបែរខ្នងមកទៀត រិទ្ធិកាន់តែប្រមូលអារម្មណ៍ទាំងមូលផ្ដុំទៅកាន់ទីនោះ។
គេហើបមាត់ដោយទឹកមុខស្មើតែបេះដូងកំពុងលោតះ
«ខ្ញុំត្រូវការមើលសិន ថាពួកឯងលេងប្អូនសន្លឹកអត់?»
ទោះយ៉ាងណាគេប្រាកដក្នុងចិត្តហើយថាស្រីតូចនោះជាពៅបញ្ញា ដោយសារតែពួកនេះនៅសុខៗមានទូរសព្ទដៃនាងខលទៅគេហើយនឹងមានកាបូប យួររបស់នាងទៀត។ គេឈានសន្សឹមៗទៅរកគោលដៅទោះបីភាគីទុច្ចរិតមិនទាន់ផ្ដល់ចម្លើយ ក៏ដោយ។ ពួកប្រាំនាក់មុនស្ទុះស្រចូលតាម ពីក្រោយតែមេខ្លោងវាដែលទើបបង្ហាញខ្លួននៅមាត់ទ្វារធ្វើសញ្ញាឃាត់ ឲ្យនាំគ្នារក្សាទីតាំងដដែលវិញ។

អ្នកប្រុសទីពីរលែងរវល់នឹងពួកនោះ ព្រោះក្នុងចិត្តផ្ដោតតែលើស្ថានភាពរបស់នាង។ នារីអង្គុយផ្ទឹងក្នុងឡានធ្វើឲ្យអ្នកតក់ស្លុតក្នុងចិត្តពន់ពេកទៅ ហើយ មិនដឹងថាតើពួកនេះចាប់នាងមកពីពេលណានាងត្រូវគេធ្វើបាបយ៉ាង ណាខ្លះ? ហើយតើនាយត្រូវធ្វើដូចម្ដេចក្នុងកាលៈទេសៈនេះ។
រិទ្ធិឈានដល់រថយន្ត ក៏បែរក្រោយរកមើលពួក៦នាក់ មុនពេលប្រាកដថាពួកវាមិនបានតាមមកពីក្រោយទេ។
គេបែរមកវិញរកស្រីតូចក្នុងរថយន្ត ដោយឱនតាមទ្វារដើម្បីឃើញមុខនាងតែដោយការរៀបចំរបស់ជនពាល ស្ថានភាពអង្គុយរបស់នាងមិនអាចឲ្យមើលពីក្រៅឃើញងាយឡើយគេចាំបាច់ត្រូវទាញទ្វារឡានបើកសិន.....
គេអន្ទះសាពីស្ថានភាពស្រីស្អាត ហើយឱនចូលទៅ.......ដៃម្ខាងលូកទាញស្មានាង មាត់ក៏

ហៅតិចៗ៖
«អ្នកនាង!!»
ខ្លួនប្រាណនារីបំបែរមកវិញតាមកម្លាំងដៃនាយ។
...រាងកាយនាងទន់ល្វក់មានន័យថានាងមិនទាន់ស្លាប់ទេ តែបើអាចធ្វើបានរិទ្ធិនឹងថយក្រោយវិញបី ជំហានភ្លាម ព្រោះថានាងមិនត្រឹមតែមិនមែនជាមេធាវីតូច តែថែមទាំងមិនដូចជាជនជាតិខ្មែរទៀត ព្រោះស្នាមសាក់លើអាវចំហទ្រូងរបស់នាង សំណើចគ្មានសំឡេងលើបបូរមាត់នាង និង ភ្នែកនាង ដែលសម្លឹងតបមកនរះយើងបានដាស់នាយឲ្យភ្ញាក់មកវិញថានាយកំពុង ជ្រុលកទៅលោអន្ទាក់។ .....តែវាហួសពេលទៅហើយ.... ជើងនាយចាប់ផ្ដើមស្ពឹកបន្ទាប់មកគឺដៃ ហើយភ្នែកក៏ចាប់ស្រវាំង។នាយឈ្វោកសម្លឹងសីរ៉ាំងថ្នាំមួយដែលបុក ឆ្កឹងលើភ្លៅខ្លួន.....សូម្បីកម្លាំងច្រាន ដៃអ្នកចាក់ថ្នាំនោះចេញក៏លែងមានដែរ.....
.....អ្នកប្រុសទីពីរធ្ងន់ក្បាលកណ្ដុកហើយរលំគ្រាំងទៅលើស្រទាប់ស្មៅវែងខ្ចី។
រាងកាយទាំងមូលលែងស្ដាប់បញ្ជា នៅសល់តែចុងម្រាមដៃដែលនៅអាចមានលទ្ធភាពកម្រើកតិចតួចហើយសន្សឹមៗ ក៏ចាប់ផ្ដើមស្ពឹករកកលកាច់ទៅក្រោយដូចមនុស្សឆ្កួតជ្រូក។ អ្វីៗនៅជុំវិញខ្លួន ឈានដល់ដំណាក់កាលលែងអាចគ្រប់គ្រងបាន ប៉ុន្តែគេនៅបង្ខាប់ខ្លួនឯងឲ្យបង្កើនស្មារតីរកសម្គាល់អ្វីៗដែល កំពុងកើតឡើងបន្តទោះបីដឹងថាមិនបានយូរទៀតក៏ដោយ។ ភ្នែកទាំងទ្វេចាប់ផ្ដើមទាញបិទដោយបង្ខំ តែនៅវិនាទីចុងក្រោយ គេឮសូរឃ្លាមួយរសាត់មកប៉ះត្រចៀក៖
«នាំអ្នកប្រុសទីពីរចូលក្នុង!»

## ២៦

## ជម្រៅនៃគម្រោងរបស់លេខាប៉េង

...ការចាប់បានអ្នកប្រុសទីពីរនៅក្នុងកណ្ដាប់ដៃ បន្ថែមពីលើ ប៉ែន ពេជ្រសក្ខណា ជាអ្វីដែលលេខាប៉េង ធូរចិត្តបំផុត ព្រោះថាបុរសចំណាស់ទាំងពីរ សុទ្ធតែមានដួងកែវក្នុងដៃខ្លួនទៅហើយ។ ទោះបីហួត ស៊ីវ និង ប៉ែន ពេជ្រ ខ្លាំងកម្រិតណាក៏គេមិនអាចលះបង់កូនរបស់ខ្លួនដែរ។
«ឯងខលទៅអាកញ្ចាស់ពីរនាក់នោះ ឲ្យម្នាក់យកមួយលានចេញមក! ផ្ញើរូបកូនៗវាឲ្យពួកវាបានឃើញផង!»
គេនិយាយទាំងសើចស្ងួត តែកូនចៅតបវិញភ្លាមព្រោះឆ្ងល់៖

«មួយលាន?? តិចម៉េះ? ឧកញ៉ា ប៉ែន ពេជ្រ ធ្លាប់មានរឿង ត្រូវការដល់ទៅ១១លាននៅតែអាចដោះស្រាយក្នុងពេលតែប៉ុន្មានថ្ងៃអាទ្រា!»
ប៉េងសើចចុងមាត់រហូតលឹបភ្នែក៖
«ព្រោះអញមិនចង់ចាំ! អញចង់ឲ្យពីរនាក់វាមកស្លាប់នៅមុខអាហ៊ាអញ!»
គាត់បង្ហាញភាពជូរចត់បន្ទាប់ពីស្នាមសំណើច។ វាជាគំនុំយ៉ាងជ្រាលជ្រៅមួយដែលគ្មានអ្នកណាដឹងថាព្រោះតែរឿង អ្វី ហើយដំណើរដើមទងដូចម្ដេចឡើយ គឺប៉េងលាក់អ្វីៗគ្រប់យ៉ាងបានល្អជាទីបំផុត។ គាត់ពោលបន្ថែមមួយៗ៖
«ឲ្យវាមកតែម្នាក់ឯង មានសូហ្វ័រម្នាក់មួយមក ក្រៅពីនោះ អត់បាន!»
កូនចៅនោះរិះគិតហើយនិយាយតប៖
«ចុះ ហួត ស៊ីវ???»
«វាក៏ដូចគ្នា? ឯងខ្លាច?»ប៉េងគំហកនឹងភាពទីទើររបស់កូនចៅ។
«អត់ទេ! តែអ្នកប្រុសធំ....នែ៎....ដៃជើងគាត់គ្រប់កន្លែងណ៎ាអាទ្រា!!.»
ប៉េងញញឹមសាហាវ។ គេងៀងភ្នែកមករកបុស្បានារីដែលអង្គុយជ្រប់មុខនៅលើសាឡុងព្រោះភិតភ័យ។
«អស់ពី ហួត ស៊ីវ ទៅ គ្មានអ្នកណាអាចនាំសង្សារឯងទៅការជាមួយកូនស្រីវាទេ! មួយឆាកនេះឯងត្រូវធ្វើឲ្យបាន យប់នេះឡើងយន្តហោះហើយ កុំវិលមកវិញលឿនពេកទោះប្រើវិធីណាក៏ដោយ!»
នារីម៉ូដែលងើបមុខដែលស្លេកស្លាំង នាងនិយាយក្នុងអាកប្បកិរិយាភិតភ័យ៖
«ចាំ!»

ប៉េងសម្លឹងបុស្បានារីត្លែ។
គាត់ដឹងថានាងកំពុងតក់ស្លុតនិងគម្រោងការណ៍ចុងក្រោយនេះ ប៉ុន្តែគាត់នៅតែមានជំនឿថាសម្ដីគាត់អាចធ្វើឲ្យនាងរឹងមាំវិញ បាន។
បុរសមានល្បិចឲ្យសញ្ញាបណ្ដេញកូនចៅទាំងឡាយចេញអស់ហើយសសៀរមក ឱ្យបខៀវក្បែរក្មួយស្រីដ៏ស្រស់ដូចបុប្ផា ត្រូវទឹកសន្សើម។
«ឯងចិត្តមិនដាច់ ធ្វើស្ដេចម៉េចកើត? ឯងចង់ស្រណុកខ្លួនត្រូវតែព្រមលំបាក!??»
តើមាននារីណាដែលស្រលាញ់ប្រុសម្នាក់ហើយចង់ឲ្យសាច់ញាតិគេមានបញ្ហានោះ?

បុស្បាគឺនៅរវាងក្តីងឿងឆ្ងល់ថាតើទំនាក់ទំនងនាងនិងយុត្តនាដើម្បី ពូ? ដើម្បីយសសក្តិសម្ភារៈ? ឬនាងកំពុងស្រលាញ់គេដោយស្មោះ? ដូច្នេះហើយពេលឮថាឪពុកគេមានបញ្ហាធំ យ៉ាងនេះនាងគឺស្លន់ស្លោផង ទាក់ទើរផងភ័យបារម្ភផង។ ទោះជាយ៉ាងណាក៏ដោយមានតែនាងទេ ដែលស្គាល់ចរិតប៉េងជាងគេ។ អ្នកមានគុណម្នាក់នេះ បើថាយ៉ាងណាគឺយ៉ាងនោះ។ នាងមានតែវិធីមួយគត់គឺងក់ក្បាលព្រមតាមគាត់។

«ក្មួយដឹងហើយ!»

នាងឆ្លើយខ្លី ។

បើកឱកាសឲ្យបុរសចិនញញឹម ពេញរង្វះមាត់។

ក្នុងចិត្តប៉េង ចាត់ការអ្នកប្រុសទីពីររួចគឺ ដូចដកបន្លាមួយដើមដ៏ធំចេញពីទ្រូង ចំណែកអ្នកប្រុសទីមួយដែលមានគ្នីគ្នាអ្នកលេងស្នេកស្កុះ នៅតែមិនមានអ្វីគួរឲ្យបារម្ភទេ ព្រោះថាគេមានកម្លាំង តែការពិចារណានិងល្បិចមិនអាចប្រៀបនឹងអ្នកប្រុសទីពីរឡើយ។

ភាពស្មោះត្រង់របស់គេព្រមទាំងបេះដូងដ៏មានកម្តៅនិងទន់ជ្រាយ ត្រូវបានប៉េងយល់ជាចំណុចខ្សោយរបស់យុត្តនា ដែលខ្លួនអាចទុកប្រើបានច្រើនយ៉ាងណាស់ ទៅថ្ងៃខាងមុខ បន្ទាប់ពីលែងមាន ហួត ស៊ីវ លើលោកនេះ។

គាត់និយាយតិចៗទៅកាន់ក្មួយស្រីដ៏ស្រស់ផូរផង់៖

«ត្រូវធ្វើឲ្យអ្នកប្រុសធំយល់ថា ស្រីដែលរៀនសូត្របានច្រើនតែល្ងង់ខ្វះខួរក្បាល ម៉េចនឹងទៅរួចជាមួយស្រីស្អាតហើយឆ្លាតរបស់ពូបានទៅ?»

បុស្បានៅស្ងៀមតែប៉េងសង្កេតឃើញតម្រុយនៃភាពច្រណែននិន្ទាផុសចេញពី ពន្លឺភ្នែករម្យទមរបស់នាង ថ្វីត្បិតតែនាងមិននិយាយវាចេញមកក៏ដោយ។

ការចាក់ដោតឲ្យមនុស្សខឹងគ្នា ចងអាឃាតគ្នាវាមិនពិបាកដូចកាលដែលធ្វើឲ្យមនុស្សមើលគ្នាឃើញដោយ ល្អនិងវិជ្ជមាននោះទេ ដូច្នេះដើម្បីបុរសម្នាក់ នារីបង្ហាញម៉ូត បានទុកដាក់មេធាវីតូចដែលមិនដឹងខ្លួនបន្តិចសោះនោះ ថាជាសត្រូវលេខមួយរបស់ខ្លួនស្រេចទៅហើយ។

……នៅខាងនេះវិញពៅបញ្ញាកំពុងរវល់នឹងរឿងចម្លែកដែលបានកើតឡើង។ នៅសុខៗនាងចេញមកវិញបាត់សក្ខណា ដោយទៅទាំងទូរសព្ទដៃកាបូបធ្វើការ ហើយទាក់ទងលែងចូល។ អ្នកដែលនាងត្រូវទំនាក់ទំនងសួរនាំមុនគេប្រាកដជាជំនួយការរិទ្ធិ តែគេក៏បាត់ស្រមោលឈឹងទៀត។ ស្រីតូចទៅកាន់មន្ទីរពេទ្យក្រែងពួកគេនៅទីនោះប៉ុន្តែ សូម្បីតែឪពុកខ្លួនដែលដើរមិន

ទាន់រួចក៏មិនឃើញ.....អ្វីៗកាន់តែខុស ពីប្រក្រតីនិងគួរឲ្យកើតពិភាល់....
«លោកឧកញ៉ាចាកចេញមុននេះប្រមាណ២០នាទីទេទាន! គឺលោកដូចជាទទួលទូរសព្ទមួយបន្ទាន់!»
គិលានុបដ្ឋាយិកានៅមន្ទីរពេទ្យប្រាប់ស្រីតូចដែលប្រកបដោយភាពសង្ស័យលើផ្ទៃមុខ។
«លោកប៉ាមិនទាន់ដើរបានផងទេមែនទេបង???»នាងសួរវិញទាំងភ្ញាក់ផ្អើលហួសនឹងព័ត៌មាននេះ។
«ជំនួយការលោករុញរទេះ ហើយបើកឡានជូនលោកចេញទៅអ្នកនាង!»
«បងវណ្ណៈ????»ស្រីតូចភ្លាត់មាត់សួរខ្លួនឯងតិចៗទាំងចម្លែកចិត្ត។
នាងងាកទៅរកគិលានុបដ្ឋាយិកាសាជាថ្មី៖
«អរគុណបង! អឺនែ៎ ខ្ញុំអាចសុំទូរសព្ទ មន្ទីរពេទ្យប្រើបន្តិចបានទេ?»
«នេះ! អញ្ជើញអ្នកនាង!»
ស្រីតូចរួសរាន់ទូរសព្ទទៅរកអមរា ដើម្បីដឹងថាតើ នាងបានឃើញសក្ខណា ហើយនិងលោកប៉ាខ្លួនដែរទេ?
«អ្នកបង!!! សក្ខណា នៅចាំខ្ញុំខាងក្រៅ Star Mart តែពេលខ្ញុំចេញមកវិញអត់ឃើញគេទេ ហើយទូរសព្ទដៃខ្ញុំក៏នៅនឹងគេ!»
«អញ្ចឹងបានអ្នកផ្ទះនេះ Call ទៅឯងក៏មិនចូល សក្ខណាក៏មិនចូល! សក្ខណាទៅណាក៏អត់ដំណឹង គឺបាត់មួយយប់ហើយណ៎ាពៅ! » អមរាតបមកពីចុងម្ខាង។
«យប់មិញគេនៅគេងផ្ទះខាងណោះ! ខ្ញុំទើបមកពីខេត្តពេលព្រលឹមស្រាងក៏ចេញមកក្រៅជាមួយគេព្រោះគេ ដូចជាមានរឿងមិនសប្បាយចិត្ត! ប៉ុន្តែមកដល់ហ្គាវ៉ាសសាំង ខ្ញុំសុំគេឲ្យចាំហើយឆ្លៀតចូលទៅលុបមុខ ចេញមកវិញស្រាប់តែបាត់ទាំងមនុស្ស បាត់ទាំងឡាន និយាយគ្នាមួយម៉ាត់ក៏អត់!»ពៅបញ្ញាឆ្លើយតបតាមការពិតទាំង ខ្វល់ខ្វាយ។
សម្រាប់គ្រួសារអភិជនការបាត់មនុស្សជារឿងដ៏ធំ ។
ទោះបីទើបតែទាក់ទងគ្នាលែងបានរវាងប៉ុន្មានម៉ោងក៏ដោយ ការចាប់ជំរិតគឺជាអ្វីដែលពួកគេតែងតែនឹកបារម្ភដូចស្រមោលអន្ទោល តាមប្រាណ។
អមរាបន្លឺមកវិញ៖
«ជំទាវម៉ាក់កំពុងហៅបងប្រាថ្នាមកហើយ! លោកកើតទុក្ខសម្បើមណាស់! តាំងពីយប់មិញម៉េះទូរសព្ទក៏ខលមិនចូល!»

ស្រីវ័យក្មេងទាំងពីរមិនបានដឹងទេថា កាលពីយប់មិញនោះជំទាវកុសុមាបានជួបជាមួយអគ្គទេសាភិបាល ហួត ស៊ីវ ដែលជជីកសួររហូតរបូតធ្លាយការពិតកាលពីជិតម្ភៃឆ្នាំមុនទាក់ទងនឹងគម្រោងការពាណិជ្ជកម្មរតនៈសោភ័ណ។ គាត់បានចាកចេញមកវិញបន្សល់ឲ្យ ហួត ស៊ីវ នូវក្ដីអាម៉ាស់និងខកចិត្តដ៏ធំធេងហើយសុខៗមកដល់ផ្ទះ កូនស្រីម្នាក់បាត់ខ្លួនទាក់ទងមិនបានពេញមួយយប់ រហូតដល់ព្រឹកថ្ងៃបន្ទាប់មកទៀត តើមិនឲ្យលោកជំទាវដ៏មានមន្ដស្នេហ៍កើតទុក្ខម្ដេចនឹងកើត?

«រឹតតែវិវរគឺ លោកប៉ាក៏ចេញពីមន្ទីរពេទ្យស្ងាត់ៗបាត់ទៀត! អត់មានដំណឹងអីបន្តិច! អ្នកនៅទីនេះប្រាប់ថា លោកទៅជាមួយបងវណ្ណៈជំនួយការលោក!»

ពៅបញ្ញាវាចាប្រាប់បងស្រីម្ដាយទីទៃទាំងដឹងថានាងគ្មានផ្លូវលាក់រឿងដ៏ធំនេះ ហើយអាចរ៉ាប់រងវាតែម្នាក់ឯងបានឡើយ។

«វរហើយ????! ប៉ាមានការអីបន្ទាន់ដល់ថ្នាក់ក្រោកពីគ្រែទៅ????»អមរានិយាយមក ទាំងព្រួយបារម្ភធ្វើឲ្យចិត្តមេធាវីតូចរឹងរឹតតែច្របូកច្របល់។

ហេតុអ្វីមនុស្សទាំងបីនាក់ធ្វើសកម្មភាពប្លែកៗក្នុងពេលតំណាល គ្នា??? តើលោកប៉ាដាច់ចិត្តក្រោកទៅទាំងឈឺ មានទាក់ទងអ្វីនឹងការបាត់ខ្លួនរបស់សក្ខណាកូនស្រីលោកដែរ??? តាមទម្លាប់ លោកគួរតែឲ្យព័ត៌មាននាងដឹងដែរ តែនេះ....អាចថាបណ្ដាលមកពីទូរសព្ទនាងទាក់ទងលែងបាន ??? ចុះសក្ខណាយកទូរសព្ទទៅណាបានជាបាត់ស្ងាត់សូន្យផ្ទះទាំងសងខាង? ហើយចុះ.....បងរិទ្ធិ......????

.....កម្ដៅដ៏ក្ដៅជះមកចំលើផ្ទៃមុខជំនួយការដែលធ្លាប់តែ ស្ងប់ស្ងាត់នឹងនជានិច្ចនៅផ្ទះឧកញ៉ាប៉ែនពេជ្រ ក្នុងស្ថានភាពពេលនេះគេដេកស្ទៀមផ្ទាល់ដី ដៃជាប់ចំណងចងទៅក្រោយ។

....អ្នកប្រុសទីពីររើគេចចេញពីចំហាយដ៏ក្ដៅនោះ ហើយទីបំផុតគេដឹងខ្លួនមកវិញសន្សឹមៗ។

....រិទ្ធិបើកភ្នែកសម្លឹង អ្វីៗជុំវិញខ្លួន។ គេនឹកមិនទាន់ឃើញពីស្ថានភាពចុងក្រោយកាលពីមុនពេលបិទភ្នែកនោះទេ  តែគេអាចមើលឃើញមុនគេគឺពន្លឺថ្ងៃក្ដៅគគុកដែលជះចូលមកតាមរយៈ ប្រលោះជញ្ជាំងឈើដែលពុកផុយធ្លុះទំហំប៉ុនប្រហាក់ប្រហែលបាតដៃ មនុស្សធំ។

.....ការចងចាំរបស់គេវិលមកវិញក្នុងពេលដឹងថាកម្រើកមិនរួច ព្រោះគេត្រូវដាក់ឲ្យដេកផ្កាប់មុខទាំងជាប់ចំណងទាំងដៃទាំងជើង។

...ភាពស្វាហាប់វិលមកវិញ ....រិទ្ធិងើបមុខខំអើតករកមើលសភាពការណ៍ជុំវិញខ្លួន តែ

ដោយសារគេនៅទាបនឹងដី គេមិនអាចឃើញអ្វីច្រើនទេក្រៅតែពីសំរាមកខ្វក់ស្អួតគរជាគំនរ មានទាំងកញ្ចប់បារី កំប៉ុងទឹកក្រូចស្រាបៀរ និងអាហារកំប៉ុងផ្សេងៗទៀត។
គេនឹកឃើញភ្លាមដល់ស្ថានភាពនៅខាងក្រៅឃ្លាំងចាស់ ដែលនៅឆ្ងាយពីផ្លូវជាតិប្រមាណ៦-៧គីឡូម៉ែត្រនោះ។
«តើយើងកំពុងត្រូវឃុំនៅកន្លែងនោះឬយ៉ាងណា?»
គេងាកទៅមើលប្រលោះថ្ងៃសាជាថ្មី ដើម្បីសម្គាល់ថាតើនេះជាថ្មើរណាទៅហើយ? ថ្ងៃរះខ្ពស់ដល់ថ្នាក់ក្តៅស្ទើររលាកធ្វើឲ្យនាយត្រូវខំបង្ខិត ខ្លួនគេចចេញពីពន្លឺដ៏វែងមុតនោះ។ គេដឹងថាថ្នាំសន្លប់មានឥទ្ធិពលយូរបំផុតមិនលើសពីពីរម៉ោងទេ ដូច្នេះគេប្រាកដជានៅក្នុងថ្ងៃដដែល។
«អ្នកណាធ្វើរឿងចោលម្សៀតនេះ?»
គេគិតទាំងទោសៈ។ ភ្លាមនោះឃ្លាចុងក្រោយមុនពេលសន្លប់នៅឯក្រៅរបងឃ្លាំងលាន់រំលឹកមកវិញក្នុងខួរក្បាលបុរសស្វាហាប់«នាំអ្នកប្រុសទីពីរចូលក្នុង!»។

.....រិទ្ធិបើកភ្នែកមូលក្លំដែលពោរពេញទៅដោយភាពសៅហ្មងនោះ ត្រិះរិះម្នាក់ឯង....តើអ្នកណាបានជាហៅខ្លួនថាអ្នកប្រុសទីពីរ....??? សមាសភាពខ្លួនជាកូនធម៌របស់ ហួត ស៊ីវ គឺមានមនុស្សមិនច្រើនទេដែលដឹង ហើយបើគេហៅខ្លួនតាមរបៀបនេះ មានតែម្នាក់នោះនឹងបក្ខពួកវាជាមនុស្សចេញចូលផ្ទះធំរបស់ឪពុកធម៌ ខ្លួនជារឿយៗ ?
ចុះហេតុអ្វីគេចាប់ពៅបញ្ញាហើយចាប់ខ្លួនមក???
....សំណួរជាច្រើនលេចចេញ មកក្នុងពេលដែលរាងកាយមិនអាចរើបាន។ រិទ្ធិឆ្ងល់ថាហេតុអ្វីពួកនោះដឹងថាខ្លួនធ្វើដំណើរតាមនេះបើរាល់ ដងដំណើរមករកឪពុកធម៌ខ្លួន គឺស្ងាត់កំបាំងជានិច្ចនោះ?
....គេចាប់នាយមិនចង់បានប្រាក់ មិនទាន់សម្លាប់ តើគេចងបានអ្វីឲ្យប្រាកដ? អ្នកប្រុសនឹកឃើញភ្លាមដល់បុរសចិនដែលមានពុតត្បុត«ចាំមើលសិន! ថា ហួត ស៊ីវ ជឿឯងឬជឿខ្ញុំ!» ....នេះជាសម្តីដែលប៉េងចោលមកជាចុងក្រោយមុនពេលគាត់ចេញទៅ ។
រូបភាពប៉េងក្លាយជាគោលដៅទីមួយនៃការសង្ស័យរបស់នាយ តែម៉េចក៏នៅសុខៗគាត់ហ៊ានចាប់ទាំងពៅបញ្ញាមកទៀត? វាគួរតែឪពុកធម៌ខ្លួនមានចំណែកក្នុងសកម្មភាពនេះដែរទេ?
«ប៉ា! អ្វីដែលគួរធ្វើកូនបានធ្វើអស់ហើយ! កូនបានលួចយកគម្រោងការចុងក្រោយនោះមកបង្ហាញប៉ាដើម្បីស្តា មិត្តភាពរំសាយគំនុំរវាងប៉ានិងមិត្តចាស់ម្នាក់នោះឡើងវិញ បញ្ចប់ការ

យល់ច្រឡំដ៏វែងឆ្ងាយមកនេះ! ឬមួយប៉ាពិតជាមិនជឿកូនហើយជឿលេខាមានល្បិចនោះវិញ? ប៉ាឲ្យគេចាប់ពៅបញ្ញាមកហើយឃុំកូនប្រុសខ្លួនឯង នៅទីនេះព្រោះខ្លាចកូនរារាំងជម្លោះអ្នកទាំងពីរ?»
គេគិតហើយគិតទាំងតូចចិត្តនិងហ្មងសៅ។

រាងកាយខ្សោះព្រោះអស់ជាតិទឹកហើយត្រាំត្រែងក្នុងបរិយាកាសក្ដៅ ហួតហែង រកតែញើសស្រក់កំដរស្បែកក៏មិនបានផង តើយើងអាចរស់បានប៉ុន្មានស្អែកទៀតដើម្បីរកចម្លើយឲ្យសំណួរអស់ នេះ?
អ្នកប្រុសនឹកឃើញភ្លាមដល់ទេពធីតាសំណព្វចិត្ត។ ពេលនេះនាងនៅឯណាហើយនាងស្ថិតក្នុងស្ថានភាពបែបណា? នាងត្រូវចាប់មកមុន ប្រសិនបើនាងស្ថិតក្នុងបរិយាកាសដ៏អាក្រក់បែបនេះដែរ តើនាងជាមនុស្សស្រីទន់ខ្សោយផង អាចទ្រាំទ្របានយូរប៉ុណ្ណាទៅ?។
ទោះអស់មធ្យោបាយយ៉ាងណា គេនៅតែព្យាយាមធ្វើអ្វីម្យ៉ាងជាជាងដេកចាំស្លាប់។
...រិទ្ធិត្រដរជម្នះបង្ខិលខ្លួនពិនិត្យស្ថានការណ៍ឲ្យបានពេញទី តែការជម្នះនេះនាំមកនូវការឈឺផ្សាផ្នែកជាច្រើននៃរាងកាយពិសេស ដៃនិងជើងដែលជាប់ចំណងណែនម៉ឹង គឺពួកដែលចងនោះមានវិធីស្ទាត់និងគ្មានមនុស្សធម៌ផង។
....ណារាងកាយទ្រុឌទ្រោមដោយសារជាតិថ្នាំសន្លប់ ណាការចចេសកម្រើកធ្វើឲ្យគេចុកចាប់ស្ទើរផុតដង្ហើមម្ដងៗ ....គាប់ជួនឮសំរិបជើងមនុស្សតម្រង់មកទៀត គេបានឱកាសបិទភ្នែកផ្កាប់មុខទៅលើដីសាជាថ្មី សំងំយកកម្លាំងនឹងធ្វើពុតជាមិនដឹងខ្លួន។
ស្នូរច្រវាក់សោបង្ហាញថា សូម្បីតែទ្វារខាងក្រៅក៏ត្រូវបានចាក់បង្ខាំងយ៉ាងមាំដែរ។
មនុស្សច្រើនគ្នាឈានចូលមកដល់ធ្វើឲ្យអ្នកប្រុសលែងមានពេលដើម្បីពិចារណា....
«លើកវាទៅអាឡូវហ្អី?»
«អត់ទេ! ចាំមេយងងឹតសិន!»
ម្ចាស់សំណួរមានសំឡេងប្លែកហើយមិនត្រឹមប៉ុណ្ណឹងទេ ដូចជាសំនៀងមនុស្សមកពីសៀមរាប មិនអញ្ចឹងទេក៏បន្ទាយមានជ័យឬឧត្ដរ។ ចំណែកម្ចាស់ចម្លើយវិញគឺប្រហាក់ប្រហែលថាស្គាល់ដែរ តែនឹកមិនឃើញ។
«ពួកវាចង់បញ្ជូនយើងចេញទៅណា? មិនមែនទៅខេត្តឆ្ងាយៗអស់នោះទេដឹង?»
គេគិតទាំងពិបាកចិត្ត។ ស្រាប់តែដង្ហើមមនុស្សម្នាក់បោលមករកច្រមុះគេ។ រិទ្ធិដឹងថាមនុស្ស

ម្នាក់មានក្លិនខ្លួនអាក្រក់កំពុងឱនមកជិតនាយ បង្កើយ ហើយបន្តបន្ទាប់មកនិយាយសើចៗ ៖

«កូនពួកអ្នកមានដឹង? មុខឡូយណាស់រ៉ី!»

សំឡេងម្ចាស់ចម្លើយអម្បាញ់មិញឆ្លើយមកទាំងទើសចិត្ត៖

«កុំបូរបាច់ច្រើន! ប្រយ័ត្នវាដឹងខ្លួនមកឃើញមុខនាំពិបាកទៅ!! ទទួលលុយហើយធ្វើការឲ្យស្អាតទៅបានហើយ! កុំចាំបាច់អី ដឹងរឿងវែងឆ្ងាយ!»

«អញ្ចឹងម៉េចមិនបិទភ្នែកវា?»

ម្នាក់សំនៀងរដឺន និយាយហើយក្រោកឡើងវិញដោយលូកជើងមកឆ្កឹះទាត់ស្មាអ្នកជាប់ចំណងលេងជាល្បែង។

«ចេញទៅវិញទៅ! មើលប៉ុណ្ណឹងបានហើយ!»

មិនដឹងអ្នកនិយាយនោះធុញថប់កាយវិការមនុស្សរដឺនឬយ៉ាងណាទេ តែរិទ្ធិមានអារម្មណ៍ថាគេដូចជាមិនពេញចិត្តដែលម្នាក់នោះប្រមាថ រាងកាយខ្លួនបានជាប្រញាប់បណ្តេញចេញ។ គេមិនមានពេលគិតច្រើនទេ ព្រោះគេរវល់អំពល់ជាមួយសំណួរថា គេគិតបញ្ជូនយើងទៅណា?? ហេតុអ្វីដល់ថ្នាក់ចំណាយលុយកាក់សម្រាប់រឿងនេះ?

មនុស្សចូលមកច្រើនគ្នាដែរ តែមានតែពីរនាក់ប៉ុណ្ណោះដែលឆ្លងឆ្លើយ។ ពេលពួកវានាំគ្នា ចាកចេញវិញ រិទ្ធិលួចបង្ហើបភ្នែកមើលជើងពួកនោះពីក្រោយ។ សុទ្ធតែមនុស្សប្រុសទាំងបួនប្រាំនាក់គ្មានជើងមនុស្សស្រីដែលបាន បន្លំខ្លួនចាក់ថ្នាំក្នុងឡានទេ ហើយក៏មិនអាចស្មានដឹងថាពួកវាជាអ្នកណាដែរ។

សំឡេងដដែលលាន់មកល្វើយៗ៖

«ធ្វើដំណើរ ៧-៨ ម៉ោង ឧស្សាហ៍ឲ្យទឹកផឹកផង ក្រែងមនុស្សដាច់ខ្យល់បាត់ ពួកឯងក៏អត់បានម៉ារៀលដែរ!»

គេងើបមុខសាជាថ្មីពេលទ្វារត្រូវបានចាក់សោទៅវិញលាន់ច្រវាក់ច្រោកច្រាក។

«ពួកវាជាអ្នកណា? មានបំណងអ្វី?.....នៅតែគ្មានចម្លើយ! តែដែលច្បាស់ជាងគេនោះគឺខ្លួននឹងត្រូវបញ្ជូនចេញ ដោយមនុស្សសំនៀងរដឺនដ៏គ្មានមនុស្សធម៌នោះ។

តើទុក្ខលំបាកយ៉ាងណាទៅដែលត្រូវប្រឈម ? ហើយពៅបញ្ញានឹងត្រូវបញ្ជូនទៅជាមួយដែរឬយ៉ាងណា? ហេតុអ្វីគេមិនសម្លាប់អ្នកតែត្រូវការឲ្យអ្នកទៅឆ្ងាយ?

.....ជាច្រើននាទីរំលងទៅ.....រិទ្ធិនៅច្រងាប់ច្រងិលជុំវិញស្ថានភាពដែល គ្មានពន្លឺនឹងមិនអាចសូម្បីតែដកដង្ហើមស្រួល តែអ្នកនៅតែព្យាយាមលើកទឹកចិត្តខ្លួនឯងពង្រឹងស្មារតីនិងមិនអស់សង្ឃឹម។

.....ស្រាប់តែស្នូរជើងមនុស្សវិលមកវិញ....លើកនេះគឺមានស្នូរជើង ស្រាលៗបំផុត....បើខំស្ដាប់ទៅ មានសណ្ឋាន ដូចជាមានមនុស្សតែម្នាក់គត់។ គេនោះដើរលបៗស្រាលៗ តែរិទ្ធិអាចស្ដាប់ឮដោយសារតែខ្លួនគេងផ្ទាល់លើដីប៉ុណ្ណោះ។

....សាជាថ្មី...រិទ្ធិរក្សាភាពមិនដឹងខ្លួននឹងធ្មេចភ្នែកទាំងសង....

.....អ្នកដែលទើបតែមកដល់ អាចបើកសោយ៉ាងជំនាញ ហើយមិនមានឮសូរអ្វីប្រោកប្រាវដូចក្រុមមុនឡើយ។

ទោះបីគេមិនបង្កស្នូររំពងមានសភាពដូចលបចូលមក តែគេមានសោហើយអាចចូលមកបានដោយស្រួល គេគឺជាក្រុមពួកតែមួយប្រាកដណាស់។ រិទ្ធិនៅស្ងៀមស្ងើរមិនហ៊ានដកដង្ហើមឲ្យឮនៅពេលទទួលអារម្មណ៍ថា ជននោះឈរស្ងៀមសម្លឹងខ្លួនហើយមិនចេញស្ដី។

....មិនយូរប៉ុន្មានដង្ហើមមនុស្សលាន់ក្បែរច្រមុះនាយសាជាថ្មី តែខ្លីប៉ុណ្ណោះ ព្រោះគេក្រោកចេញទៅវិញហើយដើរបកក្រោយតម្រង់ទ្វារដោយគ្មាននិយាយ អ្វីទាំងអស់។ រិទ្ធិប្រឹងលបលួចសម្លឹងជើងគេ។ដោយសារគេមានតែម្នាក់ រិទ្ធិអាចផ្ដោតលើស្បែកជើងរបស់គេនិងខោ Jeanពណ៌ខ្មៅចាស់ពត្លក់តែមិនឃើញរាងកាយគេទាំងស្រុងឡើយ។

អ្នកបិទភ្នែកមកសំងំវិញក្នុងពេលជននោះទាញទ្វារបិទ។

រិទ្ធិបែរមកវិញព្រោះកន្ទុយភ្នែកប្រទះនឹងអ្វីម្យ៉ាង។

នោះគឺដែកកេះមួយពណ៌ខៀវ និងកំប៉ុងទឹកក្រូចចាស់កំប៉េងកំប៉ោងនៅចំពីមុខខ្លួន។

ដូចមនុស្សរបួសអស់សង្ឃឹមហៀបសន្លប់ បែរជាឃើញឡានពេទ្យមកដល់ គេបើកភ្នែកធំៗហើយគំនិតវិលខ្វាល់ក្នុងភាពពិចារណា។

«គេនោះជាអ្នកណា? គេលបចូលមកហើយទុកដែកកេះនៅទីនេះ? គេចង់ជួយយើង????»

រិទ្ធិពោរពេញដោយក្ដីសង្ឃឹម។

គេនឹកថាភ្លើងមុខតែអាចជួយគេឲ្យស្រាយចំណងដៃបាន ប៉ុន្តែភ្លាមនោះគេសួរខ្លួនឯង «បើម្ចាស់ដែកកេះពិតជាចង់ជួយយើងម៉េចក៏គេមិនព្រមជួយដុតស្រាយ ខ្សែហ្នឹងតែម្ដងទៅ?»

ទោះយ៉ាងណាគេមិនចង់គិតច្រើនទៀតឲ្យខាតពេលវេលាទេ។ អ្នកប្រុសទីពីរប្រឹងប្រែងប្រមូលអស់កម្លាំងកាយចិត្តបង្វិលទី តាំងខ្លួនឲ្យអាចច្បាមចាប់យកដែកកេះនោះកាន់ក្នុង

ដៃ។...វាមិនមែន ជាការងាយស្រួលតែវាក៏អត់ពិបាកដែរ សម្រាប់មនុស្សដែលពោរពេញដោយក្តីសង្ឃឹមនិងការព្យាយាម។
ទីបំផុតគេបានវាហើយចាប់ផ្តើមដុតបំផ្លាញចំណងលើដៃខ្លួនទាំងរលាក ផងដាច់ឈឺផង តែគេមិនដឹងឈឺចាប់អ្វីទៀតឡើយដឹងតែថាគេត្រូវតែចេញឲ្យបាន ដើម្បីតទៅរកមេធាវីកម្សត់។

.....ចំណងដៃស្រាយរួចតែកដៃនិងប្រអប់ដៃសស្ទើរឆេះឆ្អិនកន្លែង ខ្លះទៅហើយ។ អ្នកប្រុសទីបីបន្តដុតស្រាយចំណងជើងដែលប្រើពេលខ្លីបំផុត។ គេក្រោកឈរវឹង ហើយងាកមករកកំប៉ុងទឹកក្រូចកំប៊ីតកំពាញនោះ។ គេលើកវាមកមើលដោយប្រើដៃដែលរបួសស្ពឹក។ ក្នុងនោះពេញប្រៀបដោយទឹកសថ្លាតែកំប៉ុងគឺចាស់ហួសហេតុ។
រិទ្ធិរវើកពិចារណាក្នុងពេលអ្នកលើកវាក្រេបក្អឹកៗទាំងស្រេកទឹកស្ទើរផុតដង្ហើម។
«គេមានចេតនាដាក់កំប៉ុងចាស់នេះ ព្រោះមិនចង់ឲ្យពួកវាពិនិត្យដឹងថាយើងរួចដោយមានអ្នកជួយហើយដាក់ទឹកឲ្យផឹកទៀត???»
គិតដូច្នោះ ទើបកំលោះយើងឱនបង្កប់កំប៉ុងនោះទៅក្នុងគំនរកាកសំណល់សំរាម ហើយលូកជើងជូតសំអាតគ្មានឲ្យសល់សូម្បីទឹកមួយដំណក់សើមលើដីទេ។
គេលូកដៃមករកទ្វារហើយសាកល្បងរុញ ។
ច្រវាក់ត្រូវបានផ្តាច់ហើយមេសោក៏ធ្លាក់រប៉ាយលើដីក្បែរនោះ ស្រេចដូចត្រូវទឹកអន្សាស៊ី។ រិទ្ធិដឹងថាគឺម្នាក់ដែលទុកដែកកេះឲ្យគេជាអ្នករៀបចំវា។
ឥតរវល់គិតច្រើន អ្នកប្រុសស្រវាពិនិត្យរំពៃជុំវិញខ្លួន រកគោលដៅត្រូវរំដោះខ្លួនចេញពីទីនេះ។ ចាកចេញពីក្នុងមកហើយក៏ដោយនេះគឺជាបន្ទប់ថ្មីមួយទៀត។
បរិយាកាសគឺស្រអាប់ជាងមុនព្រោះថាវាគ្មានចន្លោះ សម្រាប់ថ្ងៃជះចូលមកធំដូចបន្ទប់ឃុំខ្លួននាយអម្បាញ់មិញឡើយ គឺមានតែស្លាបព្រិលនៅខ្ពស់ៗផុតពេក ធ្វើឲ្យពន្លឺថ្ងៃជះមកចាំងបំភ្លឺបានតែខាងលើតែប៉ុណ្ណោះ។
ជាមួយនោះគេអាចមើលឃើញមនុស្សស្រីម្នាក់កំពុងអង្គុយលើកៅអីបែរ មុខទៅជញ្ជាំង។ គេមិនអាចមើលមុខនាងឃើញឡើយ ប៉ុន្តែស្ថានភាពនាងហាក់បីដូចជាសន្លប់មិនដឹងខ្លួន ឯដៃទាំងពីរចងទៅក្រោយជាប់នឹងបង្អែកកៅអី។
តាមរយៈសំលៀកបំពាក់របស់នាង រិទ្ធិភ្លេចអស់នារីក្លែងក្លាយ និងល្បិចចាក់ថ្នាំសន្លប់នៅឯរថយន្តតូចក្រៅរបងឃ្លាំង ព្រោះនាយនៅចំណាំបានថាស្រីម្នាក់នេះគឺជានារីដែលស្រែកឈ្លោះ

ជាមួយខ្លួនកាលពីនៅផ្ទះ ប៉ែន ពេជ្រ ដោយសារនាយមិនដឹងនាងគេងនៅលើគ្រែហើយធាក់នាងទម្លាក់តដ្ឋ។
«អ្នកនាងសក្ខណា???»

អ្នកប្រុសទីពីរកាន់តែស្លុតចិត្តពេលឃើញវត្តមានស្រីតូចដែល ទើបតែត្រលប់មកពីអាមេរិកក្នុងស្ថានភាពរបៀបនេះ។ ទោះបីមិនដឹងថាឥឡូវនេះពៅបញ្ហានៅឯណា ប៉ុន្តែគេដឹងថាគេត្រូវតែជួយនាងសិន។
រិទ្ធិងាករកច្រកចេញជុំវិញខ្លួន គេឃើញទ្វារមួយតែគ្មានបង្អួចឡើយ។ ប្រការដែលសំខាន់គឺត្រូវឲ្យនាងដឹងខ្លួន ទើបអាចផ្សងព្រេងចាកចេញជាមួយគ្នាបាន។
គេស្ទុះទៅស្រាយចំណងនាង តែខ្សែនោះជាប់ម៉ឺងហើយជាប្រភេទខ្សែធំក្រាស់ដែលមិនងាយសូម្បីតែកាត់ផ្តាច់ដោយកាំបិត។
អ្នកប្រុសប្រើដែកកេះរបស់មនុស្សចិត្តធម៌នោះសាជាថ្មីតែបារម្ភ ខ្លាចការក្តៅរលាកធ្វើឲ្យនាងភ័យរឹតតែខ្លាំងព្រោះមិនដឹងរឿង។ គេក៏ចាប់ផ្តើមបង្វែរនាងមកហើយដាស់នាងឲ្យដឹងខ្លួនជាមុនសិន។
....គេកាន់តែស្រណោះអាណោចអធម៌ នារីអភិជនព្រោះពេលបំបែរកៅអីមកនាងស្ថិតក្នុងស្ថានភាពត្រូវបិទ មាត់ជិត ដោយស្កុតពណ៌ក្រមៅ។
គេយល់ថានាងប្រហែលជាត្រូវចាប់មកមុន ដោយបានដឹងខ្លួនម្តងពីរដងរួចហើយ ប៉ុន្តែនាងស្រែកពេកទៅទើបត្រូវពួកវាប្រើវិធីនេះ។ ដែលនាងសន្លប់នេះអាចថាអស់កម្លាំងនិងអស់សង្ឃឹមពេកដូច្នេះការ ដាស់មកវិញមកមិនពិបាកដូចត្រូវថ្នាំសណ្តំឡើយ។
អ្នកប្រុសទីពីរចាប់ផ្តើមស្រាយស្កុតចេញ ហើយដាស់នាងតិចៗក្បែរត្រចៀក៖
«អ្នកនាងសក្ខណា! អ្នកនាងសក្ខណា!»
នារីប្រែតិចៗជាសញ្ញាថានាងឮគេហៅ។ តែនាងមើលទៅទន់ខ្សោយនៅឡើយ។ រិទ្ធិក្រឡេកទៅឃើញដបទឹកសុទ្ធមួយនៅសល់ខ្លះក្បែរជើងនាងគេយល់ ថាតាមមើលពួកជនពាលបានប្រើទឹកនេះឲ្យនាងបន្តជីវិតគេក៏ចាប់វា មកដាក់ក្បែរបបូរមាត់នាង ស្រាប់តែនាងត្រដរមកក្រេបហាក់ស្រេកជាខ្លាំង។ អស់ទឹកកាលណានាងគេហៅសាជាថ្មី៖
«អ្នកនាងសក្ខណា!??»
នារីបើកភ្នែកព្រឹមៗព្រោះប្រសិទ្ធភាពនៃទឹកត្រជាក់។

នាងគួរណាស់តែត្រេកអរពេលឃើញជំនួយការដែលប្អូនស្រីពៅនាងគោរពទុក ចិត្តបំផុត ហើយរង់ចាំគេជួយនាំនាងចេញពីទីនេះ ដឹងអីសភាពការណ៍ទៅជាផ្ទុយស្រលះ ស្រីតូចរបស់ជំទាវកុសុមាបែរជាបើកភ្នែកធំៗដោយតក់ស្លុតហើយស្រែក សន្ធាប់៖
«អត់ទេ! ចេញទៅ! ចេញ!»

នាងរើខ្លួនមួយទំហឹងទាំងស្ថិតនៅក្នុងចំណង ចំណែករិទ្ធិខំលើកដៃផ្ទប់មាត់នាងហើយពន្យល់ញាប់ស្មេរ៖
«កុំ! កុំស្រែក! ប្រយ័ត្នគេឮ!»
គេនិយាយច្រំដែលៗរហូតដល់នាងនៅស្ងៀមញ័រមាត់ដៃជើងចំប្រប់ ទើបគេឱនជាប្រញាប់មកចាត់ការបំផ្លាញខ្សែចំណង។
មាត់អ្នកប្រុសខំពន្យល់៖
«នៅឲ្យស្ងៀមណា៎! ខ្ញុំស្រាយដៃជើងឲ្យ!»
សក្ខណាបើកភ្នែកធំៗដោយភិតភ័យ ព្រោះនេះជាហេតុការណ៍ដ៏គួរឲ្យតក់ស្លុតបំផុតទើបតែជួបប្រទះជា លើកដំបូងក្នុងជីវិត។ រិទ្ធិស្មានថានាងយល់ការណ៍ហើយទើបព្រមស្ដាប់សម្ដីគេនៅស្ងៀមដឹង អីថាពេលបានរួចពីចំណងកាលណាស្រីតូចស្ទុះរោកពីកៅអីស្រែកមួយទំហឹងខ្ទរបន្ទប់៖
«ជួយផងៗៗៗៗៗ! មានអ្នកណានៅទីនេះទេ! ជួយខ្ញុំផងៗ!»
ប្រតិកម្មខុសរឿងរបស់នាងធ្វើ ឲ្យរិទ្ធិហួសចិត្តទៅជាស្រលាំងកាំង។
គេមិនដឹងទេថាដោយសារតែនាងសន្លប់នៅពេលតាមដាននាយឃើញនាយនៅជាមួយ ហួតស៊ីវ ស្ងាត់ៗហើយពេលដឹងខ្លួនមកវិញ ក៏ស្រាប់តែឃើញមុខនាយនៅក្បែរ ដូច្នេះនាងគឺគិតថានាយនេះហើយជាអ្នកចាប់នាងមក ហើយកំពុងមានបំណងអាក្រក់ធ្វើបាបនាងដូចដែលនាងមានអគតិទៅលើនាយ ដែរ។
ក្នុងពេលអ្នកប្រុសទីពីរចំហមាត់ផ្លុងមិនដឹងត្រូវពន្យល់យ៉ាងណា នាងគិតពីរត់គេចចេញទៅម្ខាង ហើយស្រែកសន្ធាប់៖
«មនុស្សអាក្រក់! ចេញឲ្យឆ្ងាយ! ចេញទៅ»
រិទ្ធិយល់ថាស្ថានការណ៍គ្រោះថ្នាក់នៅបង្កើយ។
សម្រេកនាងលាន់ដល់ថ្នាក់នេះរឿងអីថាមិនឮសូរដល់ពួកជនអន្ធពាល? គេរេភ្នែករកទ្វារ

ហើយរិះគិតពីជម្រើសថា តើបន្តពន្យល់នាង ឬក៏គួរតែគេចខ្លួនទៅរកពៅបញ្ញាសិន? តែអ្វីៗមិនអំណោយផលដល់នាយទេ ព្រោះមនុស្សជាច្រើនរត់ព្រូមកពីក្រៅទ្វារធ្វើឲ្យអ្នកប្រុស ថ្លោះទឹកមុខ។ គេនិយាយលែងចេញព្រោះភាគីខាងស្រីគិតពីផ្ទប់ត្រចៀកស្រែកមិនព្រម ស្ដាប់ហេតុផលអ្វីទាំងអស់។

ពួកមនុស្សប្រុសមាឌធំមាំបីបួននាក់បង្ហាញខ្លួន។
លើកនេះពួកវាគ្មានម៉ាសបាំងមុខទេ ដូច្នេះរិទ្ធិដឹងថាពួកវានឹងមេខ្លោងវាជានរណាស្រេចទៅហើយ។ គេនឹកឃើញភ្លាមដល់ព្រឹកព្រហាមមួយដែលគេចូលទៅលេងឪពុកស្ងាត់ៗបាន លបប្រទះឃើញប៉េងកំពុងហុចលុយមួយចំនួនឲ្យទៅពួកអស់នេះ បន្ទាប់ពីប្រើពួកគេឲ្យដេញតាមបង្អើលយុត្តនារួចមក។
ទោះមិនដឹងថាគេធ្វើលើកនេះដោយបញ្ជាឪពុកខ្លួនឬគ្រាន់តែជាបញ្ជា ប៉េង តែរិទ្ធិក្ដុកក្ដួលចិត្ត។ គេមិនសូវនៅផ្ទះឪពុកធម៌ខ្លួនស្រាប់ហើយ មិនដែលមានទំនាក់ទំនងជាមួយក្មេងៗដែជើងក្នុងផ្ទះគាត់ច្រើនទេ ដូច្នេះពេលនេះចែកមិនដាច់ថាពួកគេកំពុងបម្រើអ្នកណាឲ្យប្រាកដឡើយរឹតតែមិនដឹងទៅទៀតថាប៉េងក្បត់គ្រួសារខ្លួនមែន បានជាកើតរឿងចាប់បង្ខាំងនេះឡើង? ឬក៏ឪពុកខ្លួនកំពុងជឿពាក្យចាក់រុករបស់តានោះលេងកូនប្រុសខ្លួន ឯង?
ទោះមួយណាក្នុងចំណោមទាំងពីរយ៉ាងនេះក៏អ្នកយល់ថាខ្លួនកំពុងស្ថិតនៅក្នុងស្ថានការណ៍គួរឲ្យបារម្ភដែរ។

បើពុកធម៌ខ្លួនជាអ្នកធ្វើយ៉ាងច្រើនខ្លួននាយនឹងចប់ទៅតាមការ ចង់បានរបស់គាត់ ប៉ុន្តែលោតែប៉េងជាអ្នកប្រព្រឹត្តិដោយឧបាយកលអ្វីម្យ៉ាងវិញ តើឪពុកខ្លួននៅឯណោះកំពុងមានគ្រោះថ្នាក់យ៉ាងណា?
គេបន្លឺសួរទាំងពន្លឺភ្នែកមុតៈ
«អ្នកណាប្រើពួកឯងធ្វើរឿងអស់នេះ?»
ពួកនោះងាកមើលមុខគ្នា។ វាទំនងជាដឹងសមាសភាពនាយច្បាស់ តែវាទុកចិត្តថាវាជាក្មេងដែលប៉េងចិញ្ចឹមមកទុកប្រើប្រាកដជា អ្នកប្រុសទីពីរមិនដែលស្គាល់ឡើយ បានជាវានៅខែងរ៉ែងមិនឆ្លើយធ្វើមិនដឹងមិនឮហើយម្នាក់ក្នុងចំណោម នោះ ញាក់មុខរកគ្នាជាសញ្ញាចាប់អ្នកប្រុសឲ្យបានមកវិញ។
រិទ្ធិរេភ្នែកសម្លឹងគូបដិបក្ខម្ដងម្នាក់ដើម្បីឲ្យដឹងថាស្ថានភាព នេះខ្លួនអាចប្រើកម្លាំងបាយតទល់

នឹងពួកវាដែរឬយ៉ាងណា?
គេពន្យារពេលជាមួយសំណួរទីពីរ៖
«ពួកឯងចង់បានអី?»
នៅតែគ្មានអ្នកណាឆ្លើយចំពេលដែលក្រសែភ្នែកអ្នកប្រុសទីពីររេទៅប៉ះម្នាក់មួយឈរក្រោយគេ។
គេនោះស្រាប់តែគេចភ្នែកចេញពេលអ្នកប្រុសសម្លឹងទៅចំ។ ឫកពាដូចជាស្ទាក់ស្ទើរមិនហ៊ានប្រឈមមុខនឹងនាយឡើយ។ រិទ្ធិចោលភ្នែកទៅរកខោរបស់គេនឹងស្បែកជើងដែលមុននេះគេនៅចាំ បាន។
«ម្នាក់នេះឬ ដែលមានចេតនាជួយយើងជាសម្ងាត់?»

អ្នករិះគិតក្នុងចិត្ត តែក៏មិនមានសម្ដែងកាយវិការណាមួយឲ្យអ្នកផងចាប់ថ្នាក់ឡើយ។ ទោះយ៉ាងណាហេតុអ្វីគេចង់ជួយនាក់ហើយគេជាអ្នកណាអ្នកក៏នៅតែរក នឹកមិនឃើញ។
ស្នូរគំហកមួយលាន់មកពីស្ដាំដៃហើយការប្រើកម្លាំងបាយបាន ចាប់ផ្ដើមពីខាងភាគីជនល្មើសបង្ខំឲ្យរិទ្ធិតដៃវិញការពារខ្លួន ញាប់រន្ថើន ក្នុងពេលធីតាអភិជនភាន់ភាំងព្រោះនាងទើបតែយល់ថាគេមិនមែនជា អ្នកចាប់នាងមកសោះ ហើយពេលនេះទៀតនាងបាននាំទុក្ខដល់គេ។
«តាមពិតគេមកជួយយើងឬចាប់យើងមក???? ឆ្កួតមែនហើយ! ស្ថានភាពគេគឺ គេមកជួយយើងហើយត្រូវយើងបំផ្លាញគម្រោងការគេហើយអាចនឹងនាំគេឲ្យ គ្រោះថ្នាក់ទៀត!?»
នៅពេលដែលកណ្ដាប់ដៃរបស់រិទ្ធិសឹងថាអាចធ្វើឲ្យពួកជនពាលបារម្ភ នាងចាប់ផ្ដើមអរភ័យហើយបន់ក្នុងចិត្តឲ្យគេឈ្នះដើម្បីនាងបានឱកាស និយាយសុំទោសគេ។
នាងលើកដៃទាំងពីរប្រណមឡើងត្រឹមទ្រូងទាំងញ័ររាងកាយចំប្រប់។ ដោយសារខ្លួនមានប្រវត្តិជាអ្នកប្រុសទីពីររបស់ ហួត ស៊ីវ អំណាចរបស់នាយធ្វើឲ្យពួកនោះបាក់ខ្លបខ្លះទៅហើយ ប៉ះចំពេលនេះ នាយគ្មានចំណង ឬថ្នាំសន្លប់ហើយកណ្ដាប់ដៃត្រូវបានបង្ហឹករឹងដូចដែកទៀត ពួកនោះដែលគ្មានកាំភ្លើងក្នុងដៃ សឹងថាបះសក់មួយសាៗដែរពេលប៉ះគ្នាជាមួយអ្នកប្រុសម្ដងៗ។
ដូច្នោះហើយស្ថានភាពនេះ រិទ្ធិបានសម្លឹងទៅរកអ្នកដែលទំនងមានអំណាចជាងគេក្នុងចំណោមពួក វាហើយចាត់ការទាញជននោះ មកក្រៀកជាប់ក្នុងហត្ថាខាងស្ដាំ។
ឆ្អឹងករបស់ម្នាក់នោះអាចនឹងបាក់បាន ប្រសិនបើគេកាច់តែមួយឃឹប។ ដូច្នេះមួយស្នៀតនេះ

ធ្វើឲ្យ ប្អូននាក់ផ្សេងទៀតនៅឈប់ស្ងៀមទ្រឹងដោយស្វ័យប្រវត្តិ។
«ពួកឯងនៅមានពេលបកក្រោយ! ប្រាប់មក!! អ្នកណាប្រើឯងមក?»
ជនពាលម្នាក់ទៀតដែលធ្វើភ្នែកក្រឡឹបក្រឡាប់ ងាករឹងតម្រង់ទៅរកសក្ខណា ចាប់ទាញនាងទៅក្នុងដៃ ហើយដៃវាម្ខាងទៀត ទាញកូនកាំបិតតូចសស្វាច ដាក់តម្រឹមបំពង់កសម៉ត់របស់នាង។
«លែងអាបងអញមកភ្លាម!»

រិទ្ធិទើបតែចាប់អារម្មណ៍ថាជនពាលម្នាក់នេះចិត្តស្លុយជាងគេ ដោយសារវាមានមុខមាត់ដូចគ្នាបេះបិទនឹងម្នាក់ដែលកំពុងត្រូវគេ ក្រៀកជាប់។ ដើម្បីការពារជីវិតបងវា វាបានហក់ទៅចាប់នារីអភិជនមកជាចំណាប់ខ្មាំងវិញគឺជាមធ្យោបាយដ៏ មានប្រសិទ្ធភាពព្រោះរិទ្ធិបានថ្លោះទឹកមុខ។
ស្ថានភាពកូនកាំបិតនោះគឺអាចរហ័សជាងក្បាច់កាច់បំបាក់ករបស់ខ្លួន ដូច្នេះគេសង្កត់ចិត្តនិយាយតិចៗ៖
«លែងនាង!»
ដឹងថាខ្លួនមានគ្រាប់អុកល្អក្នុងដៃហើយ ជនពាលជាកូនភ្លោះនោះផ្ទុះសំណើចក្អាកក្អាយវានិយាយផ្ចង់៖
«អញរាប់ដល់បី! បើឯងមិនព្រមលែង! ស្រីនេះដាច់ក!.....មួយ.....ពីរ.....»

វាបម្រុងហាមាត់រាប់បង្គ្រប់ពាក្យ«បី» ជាមួយនឹងគ្រាប់ភ្នែកចាប់បើកធំក្រឡោត តែអ្នកប្រុសបានត្រៀមស្រេចហើយក្នុងការរុញបងភ្លោះវាសងទៅឲ្យវា វិញ។
.....សក្ខណាតក់ស្លុតចំពោះផ្លូវមច្ចុរាជ នាងមិនស្រែកទៀតទេព្រោះស្អកកអស់ទៅហើយតែទឹកភ្នែកនាងហូរមកព្រោះ ខឹងចិត្តខ្លួនឯងរហូតដល់ស្ទើរងងឹតមុខមើលអ្វីលែងឃើញ។ នាងដឹងត្រឹមថាបើកុំនាងស្អប់នាយហើយមានះស្រែក ស្ថានភាពមិនទៅជាអាក្រក់ដល់ថ្នាក់នេះទេ ប៉ុន្តែការពិតគឺស្ថានភាពជាក់ស្តែងកំពុងផុងជ្រៅជាងកាលដែលនាង យល់ទៅទៀតព្រោះថាទោះពេលនេះបងភ្លោះវាបានរួចពីកណ្ដាប់ដៃអ្នកប្រុសហើយ ក៏វានៅមិនលែងនាងពីមុតកាំបិតដែរ។
រិទ្ធិដឹងថាគេត្រូវតែចូលទៅក្នុងចំណងវិញជាលើកទីពីរដែលលើកនេះគឺថាគ្មានផ្លូវចេញសង្ឃឹមចេញរួចវិញឡើយ។

យ៉ាងណាក៏ដោយគេនៅតែព្យាយាមនិយាយ៖
«បើខ្ញុំជាមនុស្សដែលពួកឯងចង់បាន! លែងស្រីៗចេញទៅ!»
ជនពាលជាបង ដែលទើបរួចពីកណ្តាប់ដៃអ្នកប្រុសនោះ ពត់សម្រួលស្មាខ្លួនឯងបណ្តើរ និយាយគ្រោតគ្រាតតបមកវិញបណ្តើរ៖
«កុំមកនិយាយអត់ប្រយោជន៍! អ្នកប្រុសដឹងហើយ ពួកខ្ញុំធ្វើតាមបញ្ជាគេទេ! ស៊ីបាយគេ គេឲ្យធ្វើអីធ្វើហ្នឹងហើយ!»

ម្នាក់នេះដូចជាមានសម្តីយល់ការជាងប្អូនកូនភ្លោះដ៏ពាលរបស់ គេ ធ្វើឲ្យរិទ្ធិមានសង្ឃឹមក្នុងការនិយាយជាមួយ ណាមួយគេបានហៅខ្លួនថាអ្នកប្រុសទៀត? នាយខំព្យាយាម៖
«លេខាប៉េង ប្រើពួកឯងឲ្យធ្វើរឿងអស់នេះ?»
ម្នាក់នោះហាក់ដឹងខ្លួនមកវិញលែងតបឆ្លើយបែរជាឲ្យសញ្ញាទៅគ្នីគ្នាយកចំណងថ្មីមកហើយដើរសំដៅរករិទ្ធិ។
«អ្នកប្រុសមិនបាច់ប្រឹងពន្យារពេលទេ! ប្អូនខ្ញុំវាកាចណាស់វាភ្លង់ពីណាហើយ អ្នកហ្នឹងកម្រស់បំផុតព្រោះវាឆេវឆាវ ហើយមិនគ្រប់ទឹកទៀត! ស្រីនេះមិនទាន់ត្រូវស្លាប់ទេអ្នកប្រុសកុំចង់ឲ្យនាងស្លាប់មុន ពេលវេលា! ឲ្យពួកខ្ញុំចងតាមសម្រួលទៅ!»
ផ្ទៃកាំបិតសស្វាចនិងទឹកមុខកូនភ្លោះប្អូនបង្ហាញថា គ្រោះថ្នាក់ពិតជាមិនខុសពីសម្តីព្រមានរបស់បងប្រុសវាមែន។ រិទ្ធិទម្លាក់ដៃបណ្តោយឲ្យចំណងរឹតរួតសាជាថ្មីទាំងតឹងតែងក្នុង ចិត្ត។ សំណួរចុងក្រោយរបស់គេគឺគ្រាន់តែចង់ដឹងថាតើពិតជាលេខាប៉េងដែល ចិញ្ចឹមពួកគេឲ្យមកធ្វើរឿងឧក្រិដ្ឋនេះឬយ៉ាងណា។ ភាពគ្មានចម្លើយរបស់គេនៅតែធ្វើឲ្យអ្នកយល់ថាអ្វីដែលអ្នកសន្និដ្ឋានអាចថាត្រូវក្នុងភាគរយច្រើនព្រោះគេមិនទទួលតែក៏មិន បដិសេធ ។
រិទ្ធិលបលួចដៀងភ្នែកទៅរកបុរសដែលខំកាត់គ្រោះថ្នាក់យកដែកកេះមក ផ្លុងឲ្យខ្លួន ប៉ុន្តែគេនោះមិនបានងាកមើលមកនាយឡើយប្រហែលគេកំពុងភិតភ័យ ឯនាយវិញគឺសោកស្តាយណាស់ ដែលគេខំជួយប៉ុណ្ណឹងហើយយើងខ្លួនឯងនៅតែចោលម្សៀតគ្មានកើតការ។

ប្រុសស្រីទាំងទ្វេត្រូវជាប់ចំណងវិញដូចដើមហើយរុញទៅទុកក្នុង បន្ទប់ផ្សេងមួយទៀតនៅក្បែរនោះប្រកបដោយទ្វារដែកពីរជាន់យ៉ាងមាំ មានសណ្ឋានដូចជាមិនមែនទៅឃុំមនុស្សទេ តែជាកន្លែងសម្រាករបស់អ្នក ណាម្នាក់។ ស្ថានភាពបន្ទឹងលើសុវត្ថិភាពហើយមានទាំងគ្រែ មានទាំងទូទឹកកកមាន ទាំងកង្ហារ និងសម្ភារៈប្រើប្រាស់នៅរាយប៉ាយ។ ប្រហែលទីនេះតែ

មួយគត់ដែលពួកគេយល់ថារឹងមាំជាងបន្ទប់ពីមុនហើយ ទើបបានគេរើសយកវាជាកន្លែងឃុំឃាំងថ្មីនៃប្រុសស្រីទាំងទ្វេ។
...ដែលរឹតតែចប់ទៀតនោះគឺម្តងនេះសូម្បីតែមាត់អ្នកប្រុសទីពីរក៏ ត្រូវបិទស្កុតដូចលំនាំរបស់សក្ខណាដែរ....ពួកគេត្រូវចងដៃក្រពាត់ ក្រោយខ្នង ហើយអង្គុយសណ្តូកជើងផ្ទាល់ទៅនឹងតដ្ឋ។ កជើងទាំងឆ្វេងនិងស្តាំ ត្រូវចងភ្ជាប់គ្នាសឹងរលាយដល់ឆ្អឹង។

## ២៧

អតីតកាលរបស់ប៉េង

.....ប៉េងត្រូវបាន ហ្គូត ស៊ីវ ហៅមកជាប្រញាប់ទោះបីនេះជារសៀលជ្រេហើយក៏ដោយ។ នៅចប់តាមផ្លូវ ជនមានល្បិចអាចកាត់យល់ខ្លះពីកម្មវត្ថុរបស់ ហ្គូត ស៊ីវ ថ្ងៃនេះថាប្រាកដជារឿងអ្នកប្រុសទីពីរដែលបាត់ខ្លួន ព្រោះគេខ្លួនឯង ជាអ្នករៀបចំសេណារីយ៉ូនេះឡើង ប៉ុន្តែក្តីសង្ឃឹមទីពីរគឺប៉េងនៅតែយល់ថា អគ្គទេសាភិបាលដែលគេធ្លាប់ឱនក្បាលបម្រើរាប់ឆ្នាំមកហើយនោះនិងអាច បង្ហើបឡើងពីអ្វីដែលគាត់និងកូនប្រុសទីពីររបស់គាត់បានជជែកគ្នា មុនពេលដែលគេបានបាត់ខ្លួន គឺការជួបដ៏សម្ងាត់នៅឯទីលានវាយកូនគោលនោះ។
«ប៉េង! រិទ្ធិមានរឿងហើយ!»
ហ្គូត ស៊ីវ ពោលឡើងសូម្បីតែប៉េងអង្គុយមិនទាន់បាននឹងស្រួលបួល។
«អ្នកប្រុសទីពីរមានរឿងអីលោកអគ្គ?»គេធ្វើពើតាមទម្លាប់។
ហ្គូត ស៊ីវ ឆ្លើយតបវិញក្នុងភាពខ្វល់ខ្វាយ៖
«ពួកវាទើបតែខលមក! ត្រូវការមួយលានបានព្រមលែងកូនខ្ញុំមកវិញ!»
ប៉េងថ្លោះទឹកមុខ ហើយហើបគូទពីកៅអី។ គឺគេសម្តែងវាយ៉ាងប៉ិនប្រសប់៖
«ពួកចាប់ជំរិត?»
ហ្គូត ស៊ីវ មិនឆ្លើយនឹងភាពភ្ញាក់ផ្អើលរបស់ប៉េងទេគាត់ពោលបន្ថែមដោយទឹកមុខស្មើ៖
«ឯងជូនខ្ញុំទៅរៀបចំលុយទៅ!»
ប៉េងលួចអរក្នុងចិត្ត។ ស្ថានភាពស៊ីវហាក់បង្ហាញថាគាត់ជឿលើរឿងនេះនេះ ១០០ ភាគរយ។ នៅជិតគាត់យូរហើយ ហ្គូត ស៊ីវ កម្រើកតែដៃប៉េងដឹងថាគាត់បាននិងកំពុងគិតអ្វី។
គេដឹងថាឆាកចុងក្រោយ របស់គេកំពុងចូលមកដល់ព្រោះមុននេះ ប៉ែន ពេជ្រ ដែលដើរមិនទាន់រួចក៏សុខចិត្តចេញពីមន្ទីរពេទ្យទៅតាមបញ្ជា អនាមិកក្នុងទូរសព្ទដែរ ដោយសារគាត់បាន

ឃើញស្ថានភាពដ៏អាណោចអាធ័មរបស់កូនស្រីផ្ទះទីមួយ ប៉ែន ពេជ្រ សក្ខណា ដែលជាប់ក្នុងដៃគេ។
លើកនេះទៀត ហួត ស៊ីវ ព្រោះតែកូនធម៌ទីពីរក៏សុខចិត្តបញ្ចេញលុយមួយលានភ្លាមៗដែរ។

នៅលើរថយន្តសំដៅទៅធនាគារដែលមានប៉េងជាអ្នកបើកបរជូន ហួត ស៊ីវ ផ្ទាល់ គេកាន់ចង្កូតបណ្តើរលួចសម្លឹងចៅហ្វាយតាមកញ្ចក់បណ្តើរ។
ឯចិត្តក៏លួចពេបជ្រាយស្ងាត់ៗ៖
«ពួកឯងក៏មានថ្ងៃភ្លើយ៉ាងនេះដែរអាពីរនាក់?»
ប៉េងគិតផ្សេង តែមាត់ពោលផ្សេងទៅកាន់អគ្គទេសាភិបាល៖
«តែ....លោកអគ្គក៏គួរតែស៊ើបមើលដែរ! អាចថាពិតឬអត់?»
ហួត ស៊ីវ និយាយដោយទឹកមុខមាំ៖
«ទូរសព្ទរិទ្ធិ ទាក់ទងលែងចូលហើយ! គ្រាន់តែលុយមួយលានប៉ុណ្ណោះ! តែកូនខ្ញុំ មិនអាចមានរឿងទេ!»
ប៉េងសប្បាយចិត្ត តែគាត់កាន់តែធ្វើទឹកមុខខ្វល់ខ្វាយ ៖
«ចុះ....យកទៅឲ្យពួកវានៅពេលណា? នៅកន្លែងណាទាន?»
«វាឲ្យខ្ញុំទៅផ្ទាល់! សំណង់ Java !»
«ការដ្ឋានសំណង់ Java??? ឆ្ងាយណាស់! ខ្ញុំសុំទៅជាមួយលោកអគ្គ!»
ហួត ស៊ីវ នៅស្ងៀម តែដៃគាត់ទាំងពីរលើកមកបំបែរម្រាមរកគ្នាតិចៗចុះឡើង។ គាត់ហាក់ប្រឹងរក្សាភាពនឹងនប៉ុណ្ណាក៏ដោយ ប៉េងក៏អាចមើលឃើញសេចក្តីបារម្ភបង្កប់ក្នុងកាយវិការរបស់គាត់។ ដំបូងគេពិតជាមិននឹកស្មានថា ហួត ស៊ីវ មានមនោសញ្ចេតនារឹងមាំដល់ម្លឹងជាមួយ ហួត ខេមរិទ្ធិ ឡើយ ប៉ុន្តែពេលនេះទើបនឹងដឹងក៏មិនអាក្រក់អ្វីដែរ ព្រោះខ្លួនកំពុងមានកូនជាទីស្រលាញ់របស់គាត់ក្នុងកណ្តាប់ដៃទៅ ហើយ។
«ចុះអ្នកប្រុសទីមួយ?» ប៉េងសួរស្ទាបស្ទង់ក្នុងន័យថាតើ ហួត ស៊ីវ បានឲ្យដំណឹងនេះទៅគេដែរទេ?
បុរសមានទ្រព្យតបវិញភ្លាម៖
«ឯងជាមនុស្សទីមួយដែលដឹងពីរឿងនេះ! បើមានអ្នកដឹងទៀតហើយឮដល់ពួកប៉ូលិស កូនរិទ្ធិនឹងមានគ្រោះថ្នាក់! យុត្តនាចេញទៅជប៉ុនហើយ ទាក់ទងមិនបានទេ ថ្មើរណេះដូចជានៅលើ

យន្តហោះហើយមិនដឹង!»
ប៉េងនឹកឃើញដល់ក្មួយស្រីសំណព្វដែលកំពុងដើរតួមួយផ្នែកក្នុងការបង្អាក់អ្នកប្រុសធំចេញផុតពីរង្វង់សង្គ្រាមនេះ។
«ឯងគ្រាន់បើបុស្បា!»
គាត់ជាន់ហ្គាចេញយ៉ាងលឿនឆ្ពោះទៅរកគោលដៅ។

.....ការដ្ឋានសំណង់ Javaជាការដ្ឋានសំណង់ Apartment ធំមួយស្ថិតនៅប្រមាណ២០គីឡូម៉ែត្រដែលត្រូវបានបោះបង់ចោលការ សាងសង់កណ្ដាលទីដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោកកាលពីបួនឆ្នាំមុន។
ក្នុងរយៈចម្ងាយប៉ុណ្ណេះ ហួត ស៊ីវ យល់ថាវាឆ្ងាយពេកណាស់សម្រាប់ចិត្តដ៏អន្ទះសារបស់គាត់។ នៅចប់តាមផ្លូវគាត់សួរខ្លួនឯងហើយសួរទៀតថាហេតុអ្វីគាត់ធ្លាប់ តែម៉ឹងម៉ាត់ រឹងត្អឹង នឹងនមួយជាតិមកហើយ ពេលនេះចិត្តឆាប់ស្លុតហើយមានពិភាល់អាក្រក់ៗច្រើនម្ល៉េះ?។
«ហេតុអីយើងទើបតែដឹងថា បេះដូងយើងមានចំណែកអាល្អិតនោះច្រើនដល់ម្ល៉ឹង? កាលពីម្ភៃឆ្នាំមុននៅពេលដែលស្រីអ្នកបម្រើម្នាក់របស់កុសុមាមិន អាចមានលទ្ធភាពចិញ្ចឹមកូនគ្មានឪពុករបស់នាង យើងបានជួបអាល្អិតសម្បុរខ្មៅរសុទ្ធនេះជាលើកដំបូង ហើយក៏គិតភ្លាមថាវាត្រូវតែជាជនបង្កប់របស់យើងនៅផ្ទះអាពេជ្រ គឺគ្មានអ្វីលើសពីនេះឡើយ! ហេតុអ្វីពេលនេះជីវិតប្រផឹតប្រផើយរបស់វាធ្វើឲ្យយើងលែងមើលឃើញ ពន្លឺភ្លឺថ្លានៃពិភពលោកនេះ? ហួត ស៊ីវ!!! ឯងពិតជាចិត្តទន់ដូចស្រីខុសពីអ្វីដែលអ្នកផងឃើញ? ឬមួយថាក្មេងប្រុសនោះពិតជាសមតម្លៃឲ្យឯងស្រលាញ់គេ? ឯងអាណិតគេដែលគេខំឈ្មុសឈ្មុលស្វែងរកការពិតនៅ ពីក្រោយគម្រោងការស្រមោលនោះមកបង្ហាញឯងកាលពីព្រឹកមិញឬមួយចិត្ត ឯងមានគេយូរណាស់ហើយគ្រាន់តែឯងមិនទទួលស្គាល់? កូនប្រុស!! ឯងធ្វើការងារជាច្រើនដើម្បីពុក!!! ទោះបីជាការងារផ្ទុយពីចរិតលក្ខណៈរបស់ឯងក៏ឯងមិនដែលត្អូញត្អែរហើយ តវ៉ាអ្វីទាំងអស់! ឯងមិនដែលស្គាល់ភាពសុខដុមក្នុងនាមជាអ្នកប្រុសទីពីររបស់ ហួត ស៊ីវ ហើយក៏មិនដែលទាមទារអ្វីមួយដែលធ្វើឲ្យពុកម្នាក់នេះត្រូវពិបាក ខ្វល់ខ្វាយ យើងក៏មិនដែលសូម្បីតែប្រគល់រង្វាន់អ្វីមួយដល់ឯងក្នុងនាមជា ឪពុកម្នាក់ដូចគ្នា! ចុះបើបន្តិចទៀតនេះពុកបានឃើញតែរូបរាងដែលគ្មានដង្ហើមរបស់ឯង តើពុកទទួលយកបានដោយរបៀបណា?»
គាត់មិនស្រក់ទឹកភ្នែកទេ ប៉ុន្តែចិត្តគាត់កំពុងខ្ទេចខ្ទាំ។

សម្រាប់មនុស្សម្នាក់ដែលទើបតែនឹកឃើញអំពើល្អរបស់អ្នកដទៃក្នុង គ្រាសឹងថាយឺតហួសទៅហើយនោះ វិប្បដិសារីនៅអែបក្បែរខាង ហើយស្ថានភាពគឺពិបាកក្នុងការអត់ទោសឲ្យខ្លួនឯងជាទីបំផុត។
«កូនប្រុសប៉ា! ប៉ាមិនព្រមបាត់បង់ឯងទេ! ក្នុងតម្លៃណាក៏ដោយ! ហួត ខេមរិទ្ធិ!» គាត់កម្លាខ្លួនឯង។ វិបត្តិពេញបន្ទុកនេះបានធ្វើឲ្យប្រាជ្ញាមនុស្សថយចុះ ហើយអ្នកលេងល្បិចលើគាត់កាន់តែមានឱកាសទ្វេឡើង។
ប៉េងរវេក្មែកសម្លឹងវ៉ាលីស៍ប្រាក់ដែលនៅកៅអីខាងស្តាំដៃគេ។
ប្រាក់នេះនឹងបានមកជារបស់គេ ហើយជីវិត ប៉ែន ពេជ្រ និង ហួត ស៊ីវ ក៏កំពុងត្រូវបានគេគូសវាសផ្លូវឲ្យដើរតាមអំពើចិត្តដែរ។
ការសង្ឃឹមថាអ្នកប្រុសទីពីរនិងសក្ខណាអាចវិលត្រលប់ទៅផ្ទះវិញជារឿងដែលប៉េងអស់សំណើច។ហេតុអ្វី???

ដោយសារថាមុននេះគេបានទាក់ទងចោរទល់ដែនមួយក្រុមឲ្យកំណត់វាសនា អ្នកទាំងពីរទៅហើយ។ ក្នុងល្បិចថាជាកិច្ចសហការទុច្ចរិតចែករំលែកផលប្រយោជន៍គ្នាប៉េង ប្រាប់ពួកនោះឲ្យនាំស្រីប្រុសទាំងទ្វេចាកចេញទៅឆ្ងាយពីភ្នំពេញ ជាទីបំផុតនៅត្រឹមយប់នេះហើយដរាបណាគាត់រកប្រាក់ពីគ្រួសារទាំង សងមែនគាត់នឹងវេរពាក់កណ្តាលទៅ។ បើមិនឃើញលុយគឺបានន័យថាអ្វីៗបរាជ័យចូរសម្លាប់ស្រីប្រុសនោះចោល ភ្លាម។
ធាតុពិតទោះជាបានលុយក្តីក៏ប៉េងមិនដែលគិតថាពួកនៅទល់ដែនមាន ចំណែកដែរ!។ គាត់នឹងប្រលេះស៊ី ហើយខ្ចីដៃពួកគេសម្លាប់ប្រុសស្រីទាំងទ្វេប៉ុណ្ណោះ។

…..ឡានឈប់ង៉ឹតក្នុងបរិវេណមហាសំណង់ Java ដែលត្រូវបានគេបំភ្លេចក្នុងភាពស្ងាត់ជ្រងំនិងកខ្វក់។
ប៉េងរីករាយហើយភ័យអរផង ចំណែក ហួត ស៊ីវ គឺហេងហាងចិត្តនិងក្រៀមក្រំ។
ពេលឃើញវត្តមានកូនចៅមួយចំនួនដែលលាក់ខ្លួននៅចំណុចនានាក្នុង បរិវេណដ៏ដាច់ឆ្ងាយពីពិភពលោកខាងក្រៅ នោះប៉េងផ្ទុះចេញនូវភាពក្រអឺត។ គេបង្ហាញភាពសាហាវនឹងអំនួតតាមពន្លឺចក្ខុព្រោះថាពេលនេះ នាទីនេះ ជាពេលដែល ហួត ស៊ីវ នៅទីនេះម្នាក់ឯងគត់ ហើយស្ថានភាពពិតគឺគាត់ជាកូនចៀមក្នុងដៃគេ។
«ឯណាពួកវា??»

ហួត ស៊ីវ សួរឡើងបន្ទាប់ពីស្ងប់ស្ងាត់ជាយូរមកហើយ។ គាត់វេភ្នែកងាកមើលឆ្វេងស្តាំ ស្រាប់តែប៉េងឆ្លើយមកផ្ទួងពីបាំងរថយន្តខាងមុខ៖
«មិនបាច់ទេទាន!....ពួកវាឲ្យខ្ញុំជាអ្នកយកជំនួស!?»
ហួត ស៊ីវ ជ្រួញចិញ្ចើមតិចៗ។ គាត់ងើបមុខសម្លឹងមនុស្សដែលធ្លាប់តែឱនតក្រុកបម្រើគាត់ជាងម្ភៃឆ្នាំមកហើយ។
ម្នាក់នេះពេលណាក៏ទន់ភ្លន់និងរញីរញ៉ូវ .....ចុះហេតុអ្វីពេលនេះសំឡេងគេប្តូរទៅជាចម្លែក? សោះកក្រោះហើយត្រជាក់ស្រេប?
តាមផ្ទាំងកញ្ចក់រថយន្តតូចពីមុខ ហួត ស៊ីវ ប៉េងបង្ហាញសំណើចជ្រីវជ្រួញ ដែលជាចម្លើយតបច្បាស់ៗទៅ នឹងចម្ងល់របស់ ហួត ស៊ីវ។
អគ្គទេសាភិបាលរក្សាទឹកមុខស្មើ ហើយប្រែជាស្លាំង ជាទម្លាប់របស់គាត់ក្នុងពេលខឹង។ តែគាត់មិនស្រែកនិងមិនកោលាហលទេ។ ភ្នែកគាត់សម្លឹងទៅដៃប៉េងដែលលូកទៅគោះលើវ៉ាលីស៍លុយប៉ូកៗឌី គាត់។

គាត់នឹកឃើញដល់ពេលមួយដែលប៉េង បានមករកគាត់ទាំងយប់ ហើយជំរុញគាត់ឲ្យដកការទុកចិត្តនិងចាត់ការកូនប្រុសទីពីរ។ បន្ទាប់មកមនុស្សមួយចំនួនបានឲ្យគាត់ដឹងថាលេខាប៉េងមានចេតនា រៀបចំក្មួយស្រីគេ ឲ្យទៅកូនច្បងរបស់ខ្លួនទៀត តែគាត់គ្រាន់តែយល់ថា ម្នាក់នេះមានពូជត្រកូលក្រីក្រគេប្រាថ្នាចង់បានក្មួយប្រសាជា នាយកធនាគារក៏គ្មានរឿងអីត្រូវបន្ទោសដែរ ព្រោះគាត់ដើរតាមខ្លួនយូរមកហើយណាមួយយល់ចិត្តកូនប្រុសថាគេមិន ក្បត់សន្យាជាមួយឪពុករើសយកស្រីផ្សេងក្រៅពីអមរាដាច់ខាត ដូច្នេះក៏ចេះតែវាហីទៅ។ ទើបតែថ្ងៃនេះ.....
.....សំណួរគាត់ លាន់មកមួយៗពីក្រោយខ្នងអ្នកបើកបរដែលសើចស្ងួតយ៉ាងវែងដូចមនុស្សឆ្កួត៖
«ហេតុអីឯងក្បត់ខ្ញុំ?»
ប៉េងសើចរលាក់ស្មាទាំងសងខាង។ គេមិនបែរក្រោយហើយថែមទាំងឆ្លើយមកភ្លាមដោយមិនព្រឺព្រួច៖
«និយាយខុសហើយ ហួត ស៊ីវ! ខ្ញុំមិនបានក្បត់ទេ ព្រោះមិនដែលបានស្មោះនឹងឯង!»
គេស៊ីផ្លេហើយប្រុសៗបួនប្រាំនាក់បានបង្ហាញខ្លួនពីមុខរថយន្ត។ ហួត ស៊ីវ ហួសចិត្ត។

មនុស្សទាំងនោះជាក្មេងដែលប៉េងរើសយកមកចិញ្ចឹមក្នុងគោលដៅបម្រើ គាត់។ ពួកវាស៊ីបាយគាត់តែពេលនេះបម្រើប៉េងក្បត់គាត់ព្រោះគាត់មិន ស្និទ្ធជាមួយពួកវាដូចប៉េងឡើយ។
«គ្រាន់តែដើម្បីលុយមួយលាននេះ?»
គាត់សួរវិញទាំងសើចខឹកមួយក្នុងក។
ហ្គួត ស៊ីវ មិនស្មានថា ប៉េងដែលជាមនុស្សឆ្លាតមានអំណោយទានល្អមានសម្ដីសំដៅសមជាអ្នកចេះ គិតគូរ ទីបំផុតបានចំណាយពេលជាងម្ភៃឆ្នាំមកហើយដើម្បីគ្រាន់តែចិញ្ចឹមនឹង ពង្វក់ក្មេងៗរបស់ខ្លួនក្នុងគម្រោងការចាប់ជំរិតនៅថ្ងៃនេះ។
ប៉េងឈោងដៃបើកទ្វារឡាន ហើយឆ្លើយ៖
«គិតមើលខ្លួនឯងទៅ! បើគិតមិនឃើញទេ!....ឯងចាស់ពេកហើយ ហ្គួត ស៊ីវ!»
មនុស្សក្បត់ចាកចេញទៅជាមួយវ៉ាលីស័ប្រាក់ធ្ងន់កណ្ដុកក្នុងដៃ។
នៅទីនេះបានបន្សល់ទុកតែការប្រឹងប្រែង ដ៏តឹងតែងក្នុងចិត្ត ហ្គួត ស៊ីវ ប្រឆាំងរំងាប់សេចក្ដីក្រោធដែលកំពុងកើតឡើង។

ទ្វារឡានគាត់ត្រូវគេកន្ត្រាក់បើក ហើយក្មេងប្រុសជំទង់ពីរនាក់ឱនមកចាប់ក្រៀកគាត់ចេញទៅតាមពីក្រោយ លេខាក្បត់របស់គាត់។
បុរសចំណាស់ត្រូវបានបង្ខំនាំឡើងទម្រាំដល់ជាន់ទី៥នៃអគារខ្ពស់ សន្លឹមក្នុងគម្រោងការថាគ្មានអ្នកក្រៅណាម្នាក់ដែលអាចមើលឃើញឬ ស្ដាប់ឮពីជោគវាសនាចុងក្រោយរបស់គេឡើយ។
.....នៅទីនោះ ហ្គួត ស៊ីវ បានឃើញសត្រូវដ៏ចំណាស់របស់គាត់ក៏ស្ថិតនៅក្នុងចំណងមុនគាត់ទៅទៀត។ នោះគឺឧកញ៉ា ប៉ែន ពេជ្រ។
ចំណែកជំនួយការដ៏ឆេវឆាវរបស់គាត់ស្ថិតនៅក្នុងស្ថានភាពសន្លប់ឈឹងចង ជាប់នឹងកៅអីតាំងពីនៅឯជាន់ផ្ទាល់ដី ប៉ុន្តែ ហ្គួត ស៊ីវ មិនបានចាប់អារម្មណ៍ព្រោះមិនស្គាល់ចំណាំគេបាន។
....ផ្ទៃមុខ ប៉ែន ពេជ្រ នៅតែស្ងួតស្ងប់ដូចដែល ហ្គួត ស៊ីវ ធ្លាប់ស្គាល់គេច្បាស់។ គេសម្លឹងមកមិត្តវ័យចំណាស់របស់ខ្លួនដែលត្រូវអូសបង្ខំនាំមកនោះ ក្នុងក្រសែភ្នែកសោកស្ដាយ។
«ឯងក៏មានវាសនាមិនខុសពីខ្ញុំដែរអា ប៉ែន ពេជ្រ?»
ហ្គួត ស៊ីវ និយាយក្នុងពេលក្មេងៗប្រុសៗកំពុងចងគាត់ភ្ជាប់ទៅលើកៅអីក្នុងស្ថានភាពអង្គុយទល់មុខនឹងអតីតមិត្តរបស់គាត់។

ចំណងនោះមិនជាប់ដូចគេចងវណ្ណៈ ក៏មិនដូចការចងរិទ្ធិនិងសក្ខណាដែរ។ គ្រាន់តែតែភ្ជាប់ជើងពួកគាត់និងកៅអីដៃទាំងសងនៅទំនេរចោលក្នុង សេរីភាព។ ប៉េងច្បាស់ជាគិតថា បុរសចាស់ពីរនាក់នេះមានស្លាបក៏ហើរមិនរួចដែរ។
«យើងគ្រាន់ជាងឯងបន្តិចអាស៊ីវ! ព្រោះថាយើងមិនបានចិញ្ចឹមចោរ!»
ហួត ស៊ីវ សើចក្អាកក្អាយ។ គាត់សើចព្រោះ ប៉ែន ពេជ្រ នៅតែដៀមដាមរឿងលេខាគាត់ក្បត់គាត់ តែគេខ្លួនឯងមិនដឹងទេថា ខ្លួនគេក៏បានចិញ្ចឹមជាកូនប្រុសធម៌ទីពីរដែលបានបញ្ជូនទៅដូច គ្នា។
«ពួកឯងជិតចូលរណ្តៅអស់ហើយនៅតែឈ្លោះគ្នាល្អមើលម្លឹងៗហ្ន៎!»
សំឡេងលេខាប៉េងលាន់មកពីជណ្តើរ។

រាត្រីកាលចាប់ឈានចូលសន្សឹមៗគ្របដណ្តប់លើបរិវេណសំណង់ដែលប្រៀបបាននឹងទីរហោស្ថាន។
ប៉េងឡើងមកដល់ក្រោយគេដោយមានបរិវារ ចាក់តែនិងទាញកៅអីជូនដូចជាលោកម្ចាស់ធំ។ គេនិយាយបន្តក្នុងពេលបុរសចំណាស់ទាំងពីររក្សាឫកពាខែងរ៉ែងធ្វើមិនដឹង៖
«ម៉េចមិនបន្តសួរសុខទុក្ខគ្នាតាមស្ទីលរបស់ពួកឯងទៀតទៅ? ឲ្យអញបានមើលសើចលេងផងវ៉ឺ!»
គេញញឹមដូចមនុស្សឆ្កួតគឺញញឹមហួសចិត្តនឹងជោគជ័យរបស់ខ្លួនឯង ដែលបានមកផុយៗពេកដូចជាការជ្រោមជ្រែងពីព្រហ្មលិខិតដូច្នោះដែរ។
«យើងវេទនាយូរហើយ! តែយើងតែងយល់ថាថ្ងៃណាមួយ ជាវេនរបស់យើងវិញម្តង! ហើយឥឡូវ....ហាសហា!....វាពិតជាបានមកដល់មែន!»
«និយាយទៅ! ឯងចង់បានអី?»ប៉ែន ពេជ្រ វាចាតិចៗកាត់ផ្តាច់ចង្វាក់សំណើចដ៏សង្អៀរត្រចៀករបស់ប៉េងធ្វើឲ្យ ជនមានល្បិចឈប់សើចហើយជញ្ជក់មាត់៖
«ឱកញ៉ាអើ្វយឱកញ៉ា! ឯងជាខ្លាបាក់ចង្កូមហើយនៅធ្វើគ្រាន់អីគ្រាន់ម៉េះ? ឯងមានស្ទីយកមកនិយាយ? អញមិនទាន់ប្រាប់ឯងប្រញាប់ចង់ដឹងម៉េះ? អ្វីដែលមកដល់គង់តែមកដល់ទេឯងអន្ទះសាធ្វើអី? អញចាំជាងសាមសិបឆ្នាំក៏ចេះចាំបាន? យប់នេះផុតម៉ោង១១ទៅដល់វេលាដែលពីរនាក់ឯងដឹងហើយ! អត់ធ្មត់ទៅឱកញ៉ា!»
ប៉ែន ពេជ្រ សើចមួយឃឹះ ហើយនិយាយតបទាំងទឹកមុខស្មើ៖

«អាចិនកញ្ចាស់! បើថាឯងឆ្កួតលីលាទេប្រញាប់ទៅរកពេទ្យមើលទៅ! ម៉ោងដប់មួយដប់ពីរស្អី ឯង??»
ប៉េងក្រោកដើរទៅរក ប៉ែន ពេជ្រ គេលូកដៃទៅលើចង្កាគាត់មកក្ដាប់ហើយខាំមាត់សើចចំអក សឹងថាខ្ទាត ទឹកមាត់ទាំងខ្មែនមកលើមុខឪពុកមេធាវីយើង។
សម្ដីគ្រោតគ្រាតតែក្នុងតុងចិនស្រុកខ្មែរនិយាយបន្តទាំងសង្រ្កឹតធ្មេញ៖
«មុនក្រោយគង់តែងាប់អ្វែងកុំចង់ប្រើវិធីនេះឲ្យអញខឹង ឲ្យអញទ្រាំមិនបាន បញ្ជូនឯងទៅមុន ស្រួលៗ! ឆាកសប្បាយមិនទាន់ដល់ទេអាឌកញ៉ា!! ចាំបន្តិច! អត់ធ្មត់បន្តិច!!! ព្ទ???»
គេលែងស្មាគាត់មកវិញហើយបែរមកញញឹមស្វាញដាក់ ហួត ស៊ីវ ។
«អគ្គទេសាភិបាល ហួត ស៊ីវ! ខកចិត្តមែនអត់? ឯងស្អប់វាមួយជាតិហើយទីបំផុតត្រូវមកងាប់ជុំវាទៀត? អាណិតដែរលោកអគ្គ តែជួយមិនបានមកពីពីរនាក់ឯងមាននិស្ស័យនឹងគ្នាពេក!»
ហួត ស៊ីវ ឆ្លើយតបមួយៗ៖
«ងាប់រស់គ្មានអ្នកណាគេចរួចទេប៉េង! វាអត់អីត្រូវព្រួយពេកទេ! សំខាន់ក្មេងៗវាអត់ដឹងរឿងហើយឯងចង់បានអីក៏និយាយមក! បើឯងនៅមានចិត្តជាមនុស្សនៅនឹកឃើញថាច្រើនឆ្នាំមកនេះឯងរស់នៅ ដោយសុខស្រួល មានគេហៅពូ ឯងកុំធ្វើអីរាលដាលដល់កូនៗអញ! អ្នកប្រុសទីពីរមិនដែលអាក្រក់ចំពោះឯងទេ! លែងគេទៅ!»

....ឆ្វើយ...!
ប៉េងប្ដូរទឹកមុខទៅជាក្រហម ស្ដោះទឹកមាត់ទៅលើឥដ្ឋជាការស្អប់ខ្ពើមនឹងទាត់ចោលហេតុផលលើកឡើងរបស់ ហួត ស៊ីវ។
«ច្រើនឆ្នាំមកនេះ រស់នៅដោយសុខស្រួល ???? អស់សំណើចបំផុតអ្ហា! ពួកអាឯងទេ ដែលសុខស្រួល តែបងអញនិងអញ គឺត្រដរខ្យល់ចាំថ្ងៃនេះ!»
ប៉េងងាកមករកឧកញ៉ា ប៉ែន ពេជ្រ បន្តិចហើយបែរទៅរក ហួត ស៊ីវ វិញក្នុងពេលបុរសចំណាស់ទាំងទ្វេសម្ដែងភាពងឿងឆ្ងល់ប្រហែលគ្នា។
ប៉េងបូញមាត់ប្រែទឹកមុខកាន់តែអាក្រក់។ កំហឹងនឹងការអត់ធ្មត់ច្រើនឆ្នាំមកនេះបានធ្វើឲ្យសំណើចគេទៅជា សាហាវនិងរឹងត្អឹង។ គេនិយាយតិចៗ៖
«សាមសិបពីរឆ្នាំមុន!.....គឺសាមសិបពីរឆ្នាំ.....ខ្វះតែប៉ុន្មានម៉ោងទៀត ទេវាគឺគ្រប់សាមសិបពីរឆ្នាំគត់....! អាក្មេងលក់ទឹកត្រជាក់ម្នាក់ឈ្មោះអាប៉េង គ្មានឪម៉ែនឹងគេ វាមានអាយុត្រឹម១៧

ឆ្នាំ វារង់ចាំបងប្រុសតែមួយគត់របស់វាដល់យប់អធ្រាត្រ….! មេឃភ្លៀងក៏ភ្លៀង…..ផ្គរក៏ផ្គរ…. ម៉ោង១១យប់….បងវាត្រលប់មកវិញ ប្រឡាក់ខោអាវជោគ….មិនដែលមានអ្នកណាទៅការពារគម្រោងជាមួយក្រុមហ៊ុន យូរយ៉ាងនេះ…..ហើយមកវិញក្នុងស្ថានភាពបែបហ្នឹងទេ! យើងដឹងហើយថាគាត់បរាជ័យ….តែយើងមិនដឹងទេថា៥០នាទីក្រោយមក….គាត់ បានចាកចោលយើងជារៀងរហូត!»
ហួត ស៊ីវ ជ្រួញចិញ្ចើមងាកមើលមុខ ប៉ែន ពេជ្រ។

អគ្គទេសាភិបាល ជាប់ក្នុងចំណងប្រឹងរិះគិតសម្ដីរបស់លេខាក្បត់។
អតីតកាលយូរយ៉ាងនេះ តែលេខាប៉េងចងចាំវាបានច្បាស់ទាំងថ្ងៃ….ខែ…ម៉ោង???
តើវាជារឿងពិតដ៏សោកសៅរបស់គេមែនឬយ៉ាងណា?
ភ្លាមនោះ គាត់ឃើញ ប៉ែន ពេជ្រ បើកភ្នែកធំៗហាក់ចងចាំរឿងអ្វីមួយ………
ហួត ស៊ីវ ក៏ប្រែប្រួលទឹកមុខដំណាលគ្នា….គាត់ក៏មិនចាស់ពេកដែរព្រោះថា អតីតកាលជាច្រើនគាត់នៅបន្តរស់ជាមួយវា ហេតុអ្វីគាត់អាចភ្លេចចោលរឿងដ៏កម្សត់របស់បងប្អូនកំព្រាក្រីក្រ ដែលរកស៊ីលក់ទឹកត្រជាក់ក្បែររបងសាលារៀននោះកើត?

«ឯងជាពីរនាក់បងប្អូនដែលពួកអញប្អូននាក់ទៅជជែកលេងក្បែរនោះ ហើយជួយទិញទឹកត្រជាក់រាល់ដងនោះមែនអត់?» ប៉ែន ពេជ្រ សួរឡើងហើយ ហួត ស៊ីវ ងាករឹងទៅមើលមុខលេខាប៉េង។
….គេនោះឬ?…..គេមែនទេ? ជាក្មេងចិនសំគមស្លូតបូតតែងតែរុញរទេះទឹកត្រជាក់មកដាក់ក្បែរ របងសាលាកាលពីជាងសាមសិបឆ្នាំមុន?….
គេនោះឬដែលក្រោយមកត្រូវបានក្លាយជាប្រធានបទជជែកវែកវរពេញសាលា ដោយសារគេបានបាត់ខ្លួនក្រោយពីបងប្រុសតែម្នាក់គត់របស់គេបាន ធ្វើអត្តឃាត?
….អគ្គទេសាភិបាល ហួត ស៊ីវ ស្ងាត់មាត់ដូចគេចុក….ហើយគាត់ចាប់ផ្ដើមនឹកសើរើឡើងវិញពីពេល ដំបូងៗថាតើប៉េងបានចូលមកនៅក្បែរគាត់ដោយរបៀបណា?
….បន្ទាប់មកគាត់គិតពីកូនប្រុសទីពីរ….ហួត ខេមរិទ្ធិ….សញ្ញារបស់ប៉េងនៅពេលនេះគឺថាសូម្បីតែកូនប្រុសដ៏ល្អ នោះក៏គេមិនឱ្យរស់ជីវិតដែរ…..។
ហួត ស៊ីវ កាន់តែគិតធ្លាក់ថ្លើមក្ដុក….។

បេះដូងឪពុកកំពុងវិប្បយោគព្រោះថា ចង់មិនចង់ ហួត ស៊ីវ យល់ថានេះជាបញ្ហាបង្កឡើងដោយខ្លួនគាត់ចំណែករិទ្ធិគឺជាអ្នក រងគ្រោះព្រោះគាត់ជាឪពុកដែលទុកចិត្តលេខាពេកស្ដាប់គេពេកមើល ស្រាលគេពេក ទោះសង្ស័យទម្ងើគេខ្លះក៏មិនដែលគិតថាគេមានល្បិចនិងគំនុំជ្រៅ ថ្នាក់នេះដែរ។

ទីបំផុតមិនត្រឹមស្លាប់ខ្លួនឥតន័យសូម្បីកូនប្រុសមិនដឹងរឿង ក៏គេមិនលើកលែង។សភាពអស់សង្ឃឹម រីតត្បិតបេះដូងជនចំណាស់ដែលធ្លាប់តែរឹងមាំនិងមានអំណាច.....ប៉ុន្តែ ប្រសិនបើ ហួត ស៊ីវ ធ្លាប់យកចិត្តទុកដាក់នឹងកូនប្រុសទីពីរឱ្យច្រើនជាង ប៉ែន ពេជ្រប្រាថ្នា ឬអ្នកប្រុសទីមួយ ហួត យុត្តនា នោះ គាត់ប្រហែលជាអាចស្គាល់ចរិតគេច្បាស់ថាសម្រាប់ ហួត ខេមរិទ្ធិគឺគេមិនចេះអស់សង្ឃឹមងាយៗឡើយ។

....នោះគឺអាស្រ័យទៅលើចរិតធម្មជាតិស្លូតបូតនិងបើកទូលាយរបស់គេ។

តួយ៉ាងពេលនេះ....នៅក្នុងការត្រឡប់ទៅជាប់ឃុំជាលើកទីពីរ...ក៏អ្នក ប្រុសនៅតែឱបជាប់នូវក្ដីសង្ឃឹមក្នុងការឃើញច្រកចេញពីឧបសគ្គ គ្រានេះម្ដង។

មេឃជិតងងឹតហើយ....បើយប់ចូលមកដល់មែនបន្ទប់នេះមុខតែគ្មាន សូម្បីតែពន្លឺប៉ុនមួយសរសៃសក់ដើម្បីឱ្យប្រុសស្រីដែលជាប់ឃុំ អាចសម្លឹងមុខគ្នាឃើញឡើយ។មុននេះប៉ែន ពេជ្រសក្ខណានាងបានត្រឹមសម្លឹងរិទ្ធិ ដែលអង្គុយជ្រប់នៅពីមុខខ្លួនដោយអស់សង្ឃឹម។

នាងគឺចង់និយាយសុំទោសគេ តែសូម្បីតែបំណងចុងក្រោយនេះក៏នាងមិនសង្ឃឹមថាខ្លួនឱកាសធ្វើវាដែរ។

សក្ខណាហូរទឹកភ្នែកងើបមុខសម្លឹងខាងលើដំបូលលែងសម្លឹងរិទ្ធិព្រោះថាពេលនេះនាងមិនចង់ឱ្យគេឃើញនាងយំទៀតឡើយ។

សម្រិបជើងអ្នកណាម្នាក់លាន់រសឹបក្បែរទ្វាររិទ្ធិងើបមុខសម្លឹង ទីនោះបន្ទាន់ហើយងាកមករក្បាលឱ្យសញ្ញាឱ្យនាងធ្វើជាដេកលក់។

....មិនដឹងចាប់យល់ចិត្តគ្នាតាំងពីពេលណាទេសក្ខណាស្រាប់តែយល់កាយវិការនាយហើយធ្វើតាមគ្មានចន្លោះ។

ល្មមពេលនោះទ្វារចាប់របើក។

ដូចបានរស់ម្ដងទៀត....ព្រោះរិទ្ធិស្គាល់រូបរាងអ្នកដែលទើបតែចូល មកដល់នោះ.....។ គេគឺជាអ្នកដដែល ដែលមុននេះបានទុកដែកកេះមួយឱ្យខ្លួន។

ពេលនេះគេចូលមកដោយមានបិទម៉ាស់។ រិទ្ធិគឺចង់និយាយជាមួយគេដូច្នេះនាយមិនធ្វើជាដេកលក់ទេ បែរជាបើកភ្នែកក្រឡេតចង់ឱ្យគេជួយបើកមាត់ខ្លួនដើម្បីសួរនាំ ប៉ុន្តែមិនដឹងយ៉ាងម៉េចម្នាក់នោះមិនត្រឹមតែមិនធ្វើអញ្ចឹងទេ គេថែមទាំងមិនខ្វីនិយាយស្ដីអ្វីទាំងអស់។ គេឃ្លាំមើល សក្ខណាឃើញនាងមិនដឹងស្មារតីទើបដើរមកក្រោយរិទ្ធិចាប់ផ្ដើម ស្រាយចំណងឱ្យអ្នកប្រុសទីពីរ។ មាត់គេខ្សឹបតិចៗធ្វើការបណ្ដើរៈ

«អ្នកប្រុសរត់ពីទីនេះមិនរួចទេ! ចាប់តាំងពីរឿងល្ងាចមិញ គេដាក់គ្នាយាមនៅក្រៅព្រាត! តិចទៀតអី មានគេមកនាំអ្នកប្រុសឡើងឡានទៅខេត្តហើយ! ដំណើរនេះគឺទៅទល់ដែនតែមិនដឹងទល់ដែនណាទេគេមិនប្រាប់! ផ្លូវឆ្ងាយគួរសម! នៅតាមផ្លូវ ត្រូវរកឱកាសរត់កុំឱ្យគេនាំចេញពីស្រុកខ្មែរទាន់! ស្រីនេះកាចណាស់កុំរវល់នឹងនាងទៀតនាំតែមានគ្រោះថ្នាក់ដល់ ខ្លួន! ដៃនេះរបូតហើយតែកុំធ្វើអីផ្ដេសផ្ដាស ក្រែងធ្លោយទៀត! ពេលអាពួកទល់ដែនមកខ្ញុំនឹងធ្វើឱ្យខូចភ្លើងម៉ូនោះ ដៃអ្នកប្រុសរបូតមិនរបូតប្រហែលអាចបន្លំពួកវាបានព្រោះងងឹតគេ ចាប់ថ្នាក់បាន!»

រិទ្ធិមានសំណួរជាច្រើនចង់សួរពិសេសគឺសួរថាគេបញ្ជូនទៅខេត្ត ណា? អ្នកបញ្ជូនជាអ្នកណា? ពៅបញ្ញានៅឯណា? ហើយមនុស្សនៅក្រៅមានគ្នាប៉ុន្មាននាក់ជាដើម។ ពិសេសតើគេខ្លួនឯងនេះជាអ្នកណាហេតុអ្វីគេជួយនាយម្ដងជាពីរដង?

អ្នកប្រុសរើខ្លួនបម្រុងស្រាយមាត់ដើម្បីសួរតែគេនោះលើកដៃធ្វើសញ្ញាឱ្យស្ងាត់ហើយបន្តខ្សាវៗ៖

«ចង់រួចជីវិតអ្នកប្រុសត្រូវចាំសម្ដីខ្ញុំហើយធ្វើតាមខ្ញុំ!នៅខាងក្រៅកាំភ្លើងក៏មានដែរ! អ្នកប្រុសកុំចចេសទៀត!»

គេថយចេញទៅវិញតែស៊ីញ៉ូចង្អុលទៅទូទឹកកកក្បែរនោះ។ គេដឹងថារិទ្ធិប្រាកដជាត្រូវការចម្អែតក្រពះមុនពេលអាចគ្រប់គ្រង ស្ថានការណ៍អាក្រក់នេះបាន។ ប៉ុន្តែពេលគេចេញទៅវិញបាត់រិទ្ធិចាប់ផ្ដើមស្រាយចំណងជើងហើយ ស្ទុះទៅលើកូនតុរកមើលអ្វីម្យ៉ាងក្រោមខ្សែភ្នែកស្លន់ស្លោរបស់ សក្ខណា។ នាងតូចដែលសំងំដេកស្មៀមពេលម្នាក់នោះចូលមកអម្បាញ់មិញពិតជាឮ សម្ដីដាស់តឿនគេគ្រប់យ៉ាង។

ដែលនាងកំពុងគិតក្នុងពេលនេះគឺថា តើរិទ្ធិពិតជាដាច់ចិត្តស្ដាប់តាមការទូន្មានរបស់អ្នកជួយគេនោះ ដោយបោះបង់នាងចោលពិតមែន?

....ជំនួយការរិទ្ធិវិញមិនត្រឹមតែមិនខ្វល់នឹងភាពអន្ទះសាក្នុង ក្រសែភ្នែកនាងទេ ប៉ុន្តែគេបែរជាបង្កើន ការរំពៃរកសព្ទទិសទីព្រោះពេលវេលាកាន់តែខើច។
សក្ខណាតាមសម្លឹងជាប់ មាត់និយាយមិនបាន ដៃជើងសុទ្ធតែជាប់ចំណង។ នាងដឹងតែម្យ៉ាងថាបើគេពិតជាទៅមែននាងមានតែផ្លូវស្លាប់មួយ ប៉ុណ្ណោះ។
រំពេចនោះនាងឃើញរិទ្ធិស្រវាបានកាបូបរបស់ពៅបញ្ញាមកក្នុងដៃពី ជ្រុងណាមកមិនដឹង។ គេបើកវាយ៉ាងរហ័សហើយរាវខាងក្នុងផ្ទៃកាបូបយ៉ាងញាប់ហាក់អន្ទះសា ចង់បានអ្វីម្យ៉ាង។
...នាងក៏អន្ទះសាទៅតាមកាយវិការគេ នាងយល់ថាបើគេស្រាយមាត់ឱ្យនាងសិនគេនឹងអាចបានព័ត៌មានខ្លះ ពីនាងដែលគេចង់រកនោះ។ ស្រាប់តែរិទ្ធិចាប់បានទូរសព្ទមួយពីក្នុងនោះចេញមក។សក្ខណាអរ ផើត។ នាងចាប់ផ្តើមយល់ហើយថាជំនួយការរិទ្ធិគឺកំពុងស្វែងរកមធ្យោបាយ អាចទាក់ទងចេញក្រៅរកជំនួយ។
នាងមានកម្លាំងព្រឹសហើយសង្ឃឹមទាំងភ័យអរថាពួកនោះមិនចូលមក ទាន់មុនពេលគេទាក់ទងអ្នកនៅក្រៅបាននោះទេ។ អ្នកដែលអ្នកប្រុសទីពីរទុកចិត្តនិងដឹងថាអាចជួយគេបានក្នុង ពេលនេះច្បាស់ជាគ្មានអ្នកណាក្រៅពីយុត្តនាឡើយ។ គេលើកទូរសព្ទចុចបើកដោយស៊ីពេលរង់ចាំយ៉ាងអន្ទះសាក្នុងវេលាដ៏ គ្រោះថ្នាក់នេះ។

ទោះយ៉ាងណាវាមិនទាន់អស់ថ្មទាំងស្រុងទេគឺនៅអាចប្រើបាន ចំណែកសេវាគឺមានពេញទំហឹង។ សក្ខណាពីដំបូងមានសង្ឃឹមតែក្រោយមកនាងធ្លាក់ថ្លើមក្តុកក្នុង ពេលតាមមើលសកម្មភាពរបស់គេដែលចុចម្តងហើយម្តងទៀតមិនឈប់។
.....វាជាសញ្ញាថាគ្មានអ្នកទទួល។
នាងទើសចិត្តណាស់បើសិនជានាងវិញ នាងនឹងខលទៅបងប្រុសប្រាថ្នានិងអ្នកផ្ទះនាងភ្លាម។
រិទ្ធិមិនដឹងទេថាពេលនេះយុត្តនាកំពុងត្រូវបានបុស្បានាំចាកចេញ។ គេប្រហែលជាកំពុងនៅលើយន្តហោះឬអាចថាចេញដំណើរផុតហើយក៏មិន ដឹងបានជាទូរសព្ទលែងដំណើរការ។

អ្នកប្រុសចាប់ផ្តើមដាច់ចិត្តខលទៅរកឪពុកធម៌ទោះមិនប្រាកដ ថាគាត់ឬប៉េងដែលនៅពីក្រោយការចាប់ខ្លួនអ្នកក៏ដោយ។ ទូរសព្ទហួត ស៊ីវ រឹតតែគ្មានការឆ្លើយតប។ គេខកចិត្តស្ទើរធ្លាក់បេះដូងចេញពីទ្រូង។
....រំពេចនោះសំណើចក្អាកក្អាយមួយលាន់រសាត់តាមខ្យល់មកល្វើយៗ។ សក្ខណាបើកភ្នែក

ធំៗ ចំណែករិទ្ធិក៏រឹតតែមានអារម្មណ៍អាក្រក់ព្រោះគេចំណាំសំណើចនេះ បានថាវាជាមនុស្ស រដឹនដែលកាលពីក្នុងទីឃុំមុនវាបានលើកជើង ធាក់ស្មានាយ។
«ម៉េចក៏ឆាប់យ៉ាងនេះ?»
នាយគិតទាំងទោមនស្ស។
ទោះយ៉ាងណាសំឡេងនោះគឺនៅឆ្ងាយនៅឡើយ។ រិទ្ធិស្មានដឹង។
គេក្រឡាប់គ្រាប់ភ្នែកត្រិះរិះដោយអន្ទះសា។ ដូច្នេះការទាក់ទងតាមទូរសព្ទគឺមិនបានការទៅ ហើយក៏ប៉ុន្តែក្តី សង្ឃឹមចុងក្រោយត្រូវតែមាន។ ថេរវេលាខ្លីចង្អៀតរិទ្ធិភ្លេចគិតថានេះមិនមែន ជាទូរសព្ទរបស់ ខ្លួន គេចាប់ផ្តើមSMSខ្លីៗប៉ុន្មានពាក្យជាភាសាអង់គ្លេសថា«ជួយ! ខ្ញុំត្រូវគេ ចាប់! បញ្ជូនចេញទៅទល់ដែន! តាមដានលេខាប៉េង!»។
ស្នូរជើងមនុស្សមកកាន់តែជិតចំពេលទូរសព្ទពៅបញ្ញាស៊ីញ៉ូអស់ថ្ម គេមិនអាចនឹងសរសេរអ្វី ឱ្យលើសពីនេះឡើយព្រោះតែអារម្មណ៍ បាចសាចក៏ប្រញាប់សរសេរបញ្ជូន។
ទម្រាំសារផ្ញើចេញបានសម្រេច១០០%គេដកដង្ហើមយូរ។
ឯស្នូរជើងដែលកាន់តែចូលមកជិតគឺហាក់មានគ្នាច្រើនគ្មានផង។ រិទ្ធិរកបិទទូរសព្ទចល័តតែ គេនឹកឃើញមិនទុកចិត្តក៏លុបទាំង SMSនោះទៀតរួចទើបញាត់វាទៅក្នុងកាបូបវិញ។ បន្ទាប់ មកក៏ថយដល់កន្លែងដើម រុំកជើងខ្លួនឯងនិងដាក់ដៃទៅក្រោយរុំខ្សែមកវិញធ្វើដូចជាប់ ចំណ ង។
ប្រអប់ដៃនៅក្តាប់ដែកកេះនោះជាប់មឹង។ គេងាកមុខទៅមើលសក្ខណាហាក់ចង់ប្រាប់ថាឱ្យ នាងធ្វើដូចគ្មាន អ្វីកើតឡើងដោយងក់ក្បាលផងមិចភ្នែកផងទម្រាំនាងយល់ហើយងក់ក្បាល មកវិញដោយ យំសស្រាក់។

.....ស្នូរបើកទ្វារជ្រែកកាត់ចង្វាក់បេះដូងប្រុសស្រីទាំង ពីរ.....ម្តងនេះរិទ្ធិបើកភ្នែកមើលពួកវា ព្រោះសភាពការណ៍មិនសម ទំនងនឹងធ្វើពុតជាដេកលក់ឡើយ។ អ្នកឃើញបុរសខ្មៅមាឌធំ មាំពីរបីនាក់ដើរចូលមកសភាពរបស់ពួកគេ ដូចជាមនុស្សមកពីទីឆ្ងាយគឺអ្នកចុងកាត់មាត់ញក ពិតប្រាកដ។
«ប្រហែលពួកចោរព្រៃអស់ហ្នឹងហើយ!»
គេគិតទាំងបារម្ភក្នុងចិត្តព្រោះពួកវាដៀងភ្នែកទៅមើលសក្ខណាពីលើដល់ក្រោម។
នៅក្រោយខ្នងជនប្លែកមុខទាំងពីរគឺពួកអន្ធពាល៥នាក់កាលពីរសៀល ដែលមានពីរនាក់មុខ

ដូចគ្នាបេះបិទត្បិតជាកូនភ្លោះ។ ចំណែកអ្នកដែលជួយឱ្យដែកកេះគេពេលនេះមិនឃើញទៀតទេ។ គេទំនងជាទៅបិទកុងតាក់ភ្លើងមែនក៏ថាបាន។
រិទ្ធិខំសម្គាល់មើលឫកពាជនមាឌធំទាំងបីដើម្បីចំណាំឱ្យបានថាគេ មកពីតំបន់ណាខេត្តណា តែគ្មានតម្រុយអ្វីទាំងអស់។ដែលរឹតតែវិវរ គឺពួកវាមិនមែននាំអ្នកទាំងពីរចេញទៅទាំងអញ្ចឹងទេគឺវាលើកបាវធំ មួយមកគ្របអ្នកប្រុសពីក្បាលដល់ចុងជើង។ហើយចុងក្រោយគឺចង ភ្ជាប់មាត់បាវជិត។
«អ្វែងចោះរន្ធឱ្យវាដកដង្ហើមផង! កុំឱ្យវាងាប់មុនពេលយើងបានលុយវ៉ី!»
ដែលត្រូវភ័យនោះគឺមិនមែនសុវត្ថិភាពទៀតទេ។ រិទ្ធិទទួលស្គាល់ថាម្នាក់ដែលតាមជួយគេរហូតនោះគិតបានត្រឹម ត្រូវវែងឆ្ងាយ។ ការពិតដៃរិទ្ធិរួចចំណងពេលនេះគឺអាចថាបានរួចជីវិតពាក់កណ្តាល ទៅហើយ។ ក្នុងដំណើរដ៏វែងឆ្ងាយគឺមានឱកាសច្រើនក្នុងការរត់គេច។ ប៉ុន្តែដែលជាក្តីបារម្ភក្នុងពេលនេះគឺស្រីតូចមេធាវីនិងសក្ខណា ដែលនៅចំពោះមុខ។ តើពៅបញ្ញានៅឯណាចំណែកសក្ខណាគេឱ្យនាងមកដែរអត់?

តាមប្រលោះខ្យល់ដង្ហើមធំប៉ុនចុងមេជើងពីរបីកន្លែងដែលពួកវា ហែកទុកឱ្យដកដង្ហើមរិទ្ធិខំប្រឹងតាមដានសភាពការណ៍ខាងក្រៅខ្លួន មិនហ៊ានរំលង។
គេត្រូវបានពួកវាលើកមកដល់ឡានដែលមិនដឹងជាពណ៌អ្វីប្រភេទ អ្វី ប៉ុន្តែជាឡានកំបាំងកាត់ខាងក្រោយគ្មានដំបូលទេ។ ពួកអ្នករកស៊ីចាប់មនុស្សលើកបញ្ជូនអ្នកប្រុសទីពីរឡើងទម្លាក់លើឡានហើយបន្ទាប់មករិទ្ធិឃើញគេបញ្ជូនបាវទីពីរមកដល់។
គេធូរទ្រូងព្រោះដឹងថាអ្នកដែលកំពុងបម្រះក្នុងបាវខ្ញើកៗនោះ គឺសក្ខណា។ គេលែងសូវគិតពីនាង ហើយរិះរកមធ្យោបាយសម្រាប់រំដោះខ្លួនវិញដោយប្រឹងរំពៃពិនិត្យគ្រប់ អ្វីៗដែលអាចចំណាំបាន រហូតដល់តែរថយន្តចាប់បញ្ឆេះចេញដំណើរ.....ស្នូរជើងមនុស្សម្នាក់ លោតឡើងមកលើឡាននេះដែរ។
រិទ្ធិតាមពិនិត្យទាំងលំបាកណាប្រហោងតូចពេកណាយប់ក៏ងងឹតហើយ ដង្ហើមពិបាកដកផង។ គេឃើញមនុស្សបីនាក់នោះ ចូលឡានខាងមុខពីរនាក់ម្នាក់ទៀតឡើងមកលើនេះអង្គុយយាមពួក ខ្លួន។
សម្រេចទៅរិទ្ធិដឹងថាគ្នាវាពិតជាមានតែបីនាក់មែន។
«មុនពេលយុត្តនាអាចរកយើងឃើញ យើងពីរនាក់អាចស្លាប់ផងក៏ថាបាន! ជួយខ្លួនឯងទើប

ជាមធ្យោបាយ!»
គេប្រាប់ខ្លួនឯងហើយក្តាប់ដែកកេះពេញក្នុងដៃ....
ឡានចាប់ចេញដំណើរទៅហើយ។

ជំនួយការវិទ្ធិពិបាកមើលប៉ុណ្ណាក៏គង់អាចដឹងបានថាខ្លួនបាន ចាកចេញពីរបងឃ្លាំងនោះបណ្តើរៗហើយ។ .....ក្នុងពេលនេះប្រសិនបើលូកដៃមកបកស្កុតចេញពីមាត់ក៏ប្រហែលអត់បញ្ហាដែរថែមទាំងអាចជួយសម្រួលដង្ហើមបានកាន់តែប្រសើរប៉ុន្តែ គេឃើញអាម្នាក់ដែលមានតួនាទីឡើងមកជិះយាមបាវដាក់មនុស្សជាប់ ចំណងទាំងពីរនេះវាមានភាពវាងវៃតាមសម្លឹងប្រតិកម្មអ្នកមិនឱ្យ ប្រហែសសោះដូច្នោះកុំថាតែហែកបាវចេញ សូម្បីកម្រើកដៃនៅក្រោយខ្នងមកខាងមុខវិញក៏គួរតែត្រូវវាមើល ដឹងមិនខាន។
អ្នកមិនមែនខ្លាចថាចេញមកក្រៅនេះហើយក៏ស៊ូបីនាក់វាមិនឈ្នះនោះ ទេ ប៉ុន្តែសំខាន់អ្នកស្ម័គ្រមកជាប់ក្នុងរូងខ្លាក៏ដោយសារតែវា មានពៅបញ្ញាក្នុងដៃ ពេលនេះទៀតសោតនាងនៅតែបាត់ដំណឹងប្រសិនអ្នកវាយឈ្នះអាបីនាក់ នេះមែន ពៅបញ្ញាគង់តែជួបគ្រោះថ្នាក់ដដែលព្រោះវានឹងឱ្យដំណឹងទៅពួកនៅឯ ឃ្លាំងវិញដាច់ខាត។
....ការរង់ចាំជាមធ្យោបាយដែលអ្នកប្រុសទីពីរសម្រេចជ្រើសរើសក្នុងពេលនេះ....
គេរវេ្ទកទៅសម្លឹងបាវដែលស្រីតូចនិស្សិតអាមេរិកកំពុងនៅស្ងៀម ឈឹង....អ្នកដឹងថានាងកំពុងវេទនា...ដៃជាប់ចំណង...មាត់បិទជិត...ហើយជាប់ ក្នុងបាវទៀត....។
គេគិតម្នាក់ឯងទាំងអាណោចអាធ័ម
«ប៉ែន ពេជ្រសក្ខណា! នាងត្រូវរឹងមាំត្រូវស៊ូឱ្យបាន! ពេលវេលាជិតដល់ហើយ! នាងត្រូវតែស៊ូបាន!»

.........................................

.....នៅពេលដែលរថយន្តជនទុច្ចរិតបង្វិលកង់បញ្ជូនប្រុសស្រីអភិជន ទាំងទ្វេចាកចេញទៅនៅឯណោះ បក្សីយន្តក៏កំពុងរោទ៍ម៉ាស៊ីនដែរ។
អ្នកប្រុសទីមួយដៀងភ្នែកមកមើលស្រីស្អាតបុស្បាដែលកំពុងញញឹមស្រទន់សម្លឹងអ្នកដំណើរនានា។

ចិត្តនាងគឺកាន់តែមានសុវត្ថិភាពក្នុងពេលដែលបក្សីយន្តឱ្យសញ្ញារំកិលកង់តម្រង់រកផ្លូវហោះឡើង។
យុត្តនាគ្មានពេលច្រើនទៀតទេ វាក៏ជាពេលចុងក្រោយរបស់នាយដែរ ប្រសិនបើរង់ចាំឱ្យយាននេះរត់សូម្បីតែមួយក្រឹកដំបូងក៏នាយ នឹងត្រូវហោះទៅលើមេឃតែម្ដង។
«អូ! វិកទ័រ ???»គេធ្វើជាភ្លាត់មាត់។
បុស្បាសម្លឹងតាមអ្នកប្រុសទីមួយដែលស្ទុះក្រោកចាកចេញទៅ គេហាក់មានគោលដៅទៅរាក់ទាក់បុរសបរទេសម្នាក់ដែលទើបតែចេញពីបន្ទប់ ទឹកហើយអង្គុយនៅជួរ First Class។ ហេតុតែទីតាំងនោះបាំងដោយស្រទាប់វាំងននក្រាស់ បុស្បាតាមមើលនាយដោយអន្ទះសា។ ទោះយ៉ាងណាថ្មើរណេះយន្តហោះបិទផ្លូវចេញចូលទៅហើយ នាងក៏ទុកចិត្តថាគេលែងទៅណាបានទៀតដែរ។

….នាងគិតខុស…ព្រោះសម្រាប់អ្នកប្រុសទីមួយ….ពេលវេលាខ្លីបំផុត គ្រោះថ្នាក់បំផុតនេះហើយដែលគេតែងតែល្បងខ្លួនឯង។ នាយចាកចេញពីបន្ទប់ First Class ហើយប្រាប់ហេតុផលកុហកទៅការីអាកាសចរហូតដល់គេគ្មានលេសឃាត់អ្នក ប្រុសបានឡើយ។ ត្រឹមមួយនាទីប៉ុណ្ណោះគេបានចុះដល់ដីវិញដោយសុវត្ថិភាព ហើយរឹតតែល្អទៅទៀតនោះគឺបក្សីយន្តបានបិទទ្វារទាំងស្រុងព្រម ទាំងរំកិលខ្លួនចេញទៅវាលយន្តហោះនាំទៅជាមួយទាំងទេពធីតាស្រស់ទងវង របស់លេខាប៉េងដែលខំរចនាមកជាចំណងស្នេហ៍ក្រៀកនាយឱ្យទៅឆ្ងាយពី ភ្នំពេញ។ យុត្តានាយញញឹមបកក្រោយដោយជំហានវែងៗមករកផ្លូវចេញ។ គេរង់ចាំអត់ធ្មត់លើយន្តហោះដល់ពេលនេះព្រោះចង់ឱ្យដល់នាទីចុង ក្រោយដែលបុស្បាចុះមកវិញលែងបាន។ គេដើរផងលើកទូរសព្ទមកចុចបើកវិញផង។

…SMS របស់ពៅបញ្ញាធ្វើឱ្យគេជ្រួញចិញ្ចើមគិតហើយជំហាននីមួយៗទៅជារង្វើលជាងមុនព្រោះរវល់ចុចបើកពិនិត្យមើល។
គេមិនដឹងទេថាអ្នកដែលផ្ញើសារមកអ្នកប្រុសទីពីរដែលកំពុងនៅកៀកនឹងសង្វៀនគ្រោះថ្នាក់។
ពាក្យខ្លីកំបុតៗក្នុងសារនោះធ្វើឱ្យយុត្តនារិះគិតដោយពិភាល់។
«ស្រីឆ្មាសនេះមានរឿងអីអ៊ីចេះ?»
ទោះយ៉ាងណាអ្នកប្រុសទីមួយកំពុងបុកពោះ។ ដែលពិបាកចិត្តគឺស្រីតូចសរសេរពាក្យឱ្យជួយ

ដែលការពិតផ្ទុយពី ចរិតលក្ខណៈរបស់នាង។ ស្មានយ៉ាងណាក៏ស្មានមិនដល់ថានាងនឹកឃើញរកអ្នកឱ្យជួយនោះដែរ។ ចំណែកពាក្យថាចេញទៅទល់ដែន ក៏រឹតតែធ្វើឱ្យចិត្តទេសាភិបាលវ័យក្មេងដាច់ដោច។

បើអ្វីៗជាការពិតនាងមិនស្ថិតនៅក្នុងគ្រោះថ្នាក់?។

អ្នកគិតពីស្រីតូចពេក រហូតដល់មិនបានពិចារណាឃ្លាចុងក្រោយដែលសរសេរពីលេខាប៉េងទេថា តើវាទាក់ទងដែរទេដែលក្មួយតានោះកំពុងចង់នាំយុត្តនាឱ្យចេញទៅ ជប៉ុន??

អ្នកចុចទូរសព្ទទៅរកស្រីតូចសម្បុរស្រអែម តែលែងទាក់ទងបានទៅហើយ។ គេបន្ទោសខ្លួនភ្លាមដែលមុននេះឡើងទៅអង្គុយលើយន្តហោះហើយសុខចិត្ត បិទទូរសព្ទតាមពាក្យណែនាំរបស់ពួកអូតេស។

អ្នកប្រុសរត់តម្រង់រថយន្តដែលចតចោលជាស្រេច ហើយបើកបញ្ចោលឿនស្ទើរបកមកកាន់ទីក្រុង។

មានអ្វីកើតឡើងបើមនុស្សសំខាន់ៗសុទ្ធតែបាត់ខ្លួន???

....នៅតាមផ្លូវយុត្តនាចុចរកស្រីស្អាតរាប់ដងភ្លេច តែនៅមិនអាចទាក់ទងបានដដែល។ គេចាប់ផ្ដើមចុចទៅរកប្អូនធម៌ ហួត ខេមរិទ្ធិ តែក៏ស្ងាត់សូន្យទៀត។ .....បំណាច់ចិត្តស្នេហ៍ស្ទើរតែលេបបាន....ដូចបទចម្រៀងមរតករបស់អធិរាជ សំឡេងមាស «ខឹងព្រោះស្រលាញ់»...

អ្នកប្រុសធនាគារបត់ឡានវ៉េរសំដៅទៅផ្ទះប៉ែន ពេជ្រតែម្ដងមិនរវល់ថា អ្នកណាថាអ្វីឡើយ ព្រោះពាក្យខ្លីៗរបស់ស្រីស្រស់ក្នុង SMS ល្មមឱ្យអ្នកកំលោះដេកមិនលក់បក់មិនល្ហើយទេ បើមិនបានដឹងច្បាស់ពីហេតុផលនៅពីក្រោយនេះ។

«នាងមានរឿងអីពៅបញ្ញា??? នាងបាត់ទៅណាស្រីឡប់អើយ!!!»

នៅច្រកផ្លូវតូចប្រមាណជា១គីឡូម៉ែត្រពីផ្ទះឧកញ៉ាដែលកំពុងជាប់ ចំណាងនៅក្រៅក្រុង គេស្រាប់តែឃើញពៅបញ្ញា និងបងស្រី នាង ប៉ែន ពេជ្រអមរា ចុះពីលើរថយន្តមួយ។

នោះគឺហ្គារ៉ាសសាំង ដែលកាលពីព្រឹកមេធាវីយើងបាននៅជាមួយសក្ខណាមុនពេលនាងបាត់ខ្លួន។

«គឺគេចាំខ្ញុំនៅទីនេះ! ខ្ញុំចូលទៅបន្ទប់ទឹកនោះលុបមុខ!»

នាងនិយាយពន្យល់បងស្រីទាំងខ្វល់ខ្វាយ។

ប៉ែន ពេជ្រអមរា ក៏មិនស្រណុកចិត្តដូចគ្នា នាងស្ដីដោយអន្ទះសាះ

«បងប្រាថ្នាអត់នៅទេ! គាត់ទៅថៃថ្ងៃស្អែកបានមក! ព្រោះមានប្រជុំសំខាន់ជាមួយដៃគូរកស៊ីនៅបាងកក! គិតយ៉ាងម៉េចទៅ?»
រថយន្តដ៏ទំនើបមួយ បោលមកខ្ទាច់ហើយឈប់ង៉ឹតក្បែរស្រីស្អាតទាំងទ្វេធ្វើឱ្យយុត្តនា ដែលលួចមើលតាមបើកកញ្ចក់ឡានហើយលបស្តាប់ផង ខំតាមដានទាំងបើកភ្នែកធំៗ។ តាមពិតគេចង់ចុះទៅ សួរថាហេតុអ្វីពៅបញ្ញាផ្ញើ SMSលេងសើចនឹងគេ? ឱ្យគេកើតទុក្ខអង្គុយមិននឹងព្រមទាំងបិទទូរសព្ទហើយបែរជាមកឈរ ជជែកលេងជាមួយបងស្រីធ្វើព្រងើយតែអ្នកដែលចុះពីឡានទំនើបនេះជា ស្ត្រីដ៏មានយសស័ក្តិក្នុងសង្គមគឺជំទាវកុសុមាដែលនាយស្អប់តាំងពីក្មេងៗមក ម្ល៉ោះហើយនាយទច់ដៃដែលប្រុងថាបើកទ្វារនោះវិញទាំងមុខក្រញូវ។

«ជំទាវម៉ាក់?»អមរាហៅម្តាយក្នុងទឹកមុខសៅហ្មង។
«ម៉ាក់ធំ!»ពៅបញ្ញាហៅតិចៗតាមទម្លាប់ដែលប៉ានាងចង់ឱ្យនាងគោរព ស្ត្រីនោះទោះនាងដឹងថាគាត់សូម្បីតែមុខនាងក៏មិនចង់ឃើញក្តី។
អតីតជំទាវ ប៉ែន ពេជ្រ ងើយមើលមេឃមិនចង់ប៉ះភ្នែកនឹងវង្សក្រូមេធាវីដាច់ខាត ព្រោះថានាងជាសក្ខីស្នេហ៍នៃអតីតប្តីពេញច្បាប់ខ្លួននិងភរិយា ក្រោយ។
គាត់និយាយមួយៗទៅកាន់បុត្រីខ្លួន ដែលជាកូនឥតខានស្លាជាមួយ ហួត ស៊ីវះ
«អមរា! ប្អូនបាត់យូរប៉ុណ្ណឹងហើយកូននៅមានពេលមកស្តាប់រឿងដោះសាអត់បាន ការអី? ឆាប់ប្តឹងប៉ូលិសភ្លាម! តោះ!ទៅជាមួយម៉ាក់! បើអ្នកណាពាក់ព័ន្ធរឿងសក្ខណាបាត់ខ្លួន ម៉ាក់ត្រូវរកមុខវាឱ្យឃើញ ឱ្យស្គាល់គុកគ្រប់គ្នា! »
ពៅបញ្ញាលើកចិញ្ចើមមិនយល់ការណ៍។....
សម្តីគាត់ដូចចង់និយាយថា នាងមានទាក់ទងនឹងការបាត់ខ្លួនរបស់កូនពៅគាត់? នាងដកដង្ហើមយូរបន្ធូរការតឹងចិត្ត តែទម្លាប់មិនទន់ខ្សោយជាចរិតពៅបញ្ញានាងខំពន្យល់តបវិញទោះដឹងថា គាត់មិនឱ្យតម្លៃសម្តីនាងក្តី។
«ម៉ាក់ធំ!....គឺ...»
«ខ្ញុំមានកូនស្រីតែពីរប៉ុណ្ណោះ....!»
ជំទាវនិយាយកាត់ម៉ាត់ៗធ្វើឱ្យអមរាលើកដៃផ្ទប់ទ្រូងព្រោះភ័យ ក្នុងខណៈពៅបញ្ញាត្រូវបាក់មុខដូចត្រូវគេជះទឹកមួយផ្តិលកណ្តាល ចំណោម។

នាងបាត់មាត់ដូចគេចុក.....ឯយុត្តនាលើកម្រាមដៃមួយមកខាំ បិទបាំងភាពទោមនស្សលើបបូរមាត់គេ។

«ហើយបើខ្ញុំមិនសួរនាងកុំមកលូកមាត់! ចាស់ទុំផ្ទះនាងគួរចេះប្រដៅប្រដៅកូនដែរមែនទេ?....»

ជំទាវថាស្ដីឱ្យនាងមុតៗដោយមិនប៉ប្រិចភ្នែកនិងមិនយោគយល់ដល់ ក្មេងស្រីម្នាក់ដែលជាឈាមជ័រស្វាមីនាងបន្តិចក៏គ្មាន។

កុសុមាងាកចេញពេលភក្ត្រពៅបញ្ញាទៅជាស្លេកព្រោះអាម៉ាស់។

«អមរា!!! ឮអត់?? ឡើងឡានជូនម៉ាក់ទៅស្នងការ! ឡានកូនឯងឱ្យសូហ្វ័រទៅផ្ទះវិញភ្លាម!»

សម្ដីគាត់គឺមានចេតនាឱ្យអមរាបោះបង់ចោលពៅបញ្ញាដែលជិះដោយសារមកនៅត្រឹមនេះ។ លោកជំទាវបែរខ្នងត្រឡប់ឡើងរថយន្តវិញ។ ពៅបញ្ញាតាមសម្លឹងគាត់ នាងដឹងថាគំនុំស្នេហ៍ចាស់ ដែលធ្វើឱ្យស្ត្រីនេះក្លាយជាគ្មានហេតុផលនិងគ្រោតគ្រាត តែនាងនៅតែមិនចុះចាញ់ភាពគ្រោតគ្រាតអស់នេះឡើយ។

នាងចចេសនិយាយមួយៗ៖

«លោកជំទាវក៏គួរស្ដាប់ហេតុផលមុនក្រោយឱ្យបានច្បាស់សិនដែរទើបអាច រកប៉ូលិសឱ្យជួយបាន! ខ្ញុំជាអ្នកនៅជាមួយសក្ខណាចុងក្រោយបង្អស់! ប៉ូលិសមិនអាចជួយអីលោកជំទាវបានទេ ប្រសិនបើគ្មានព័ត៌មានគ្រប់!»

ស្ត្រីនោះឡើងដល់ឡានខាងក្រោយដែលមានសូហ្វ័រត្រងត្រាប់ផ្ដាប់ផ្ដុន បើកទ្វារជូន។ គាត់រក្សាទឹកមុខស្មើ ត្រូវនឹងផ្ទៃមុខក្មេងជាងវ័យហើយមើលទៅរាសីក៏ខ្ពស់លើសពីស្ត្រី ធម្មតា។ ប៉ុន្តែវាចាដែលបង្ហើរបន្តមកទៀតនៅតែគ្រោតគ្រាតផ្ទុយស្រលះនឹង សម្រស់របស់គាត់៖

«មិនបាច់ភ័យទេ! ខ្ញុំនឹងប្រាប់គេថានាងជាជនសង្ស័យដែលនៅជាមួយកូនស្រីខ្ញុំ ក្រោយគេ! ប៉ូលិសគេដឹងធ្វើយ៉ាងណាហើយ! គេនឹងទៅរកនាងដល់ផ្ទះមិនខាន! ចាំជិះឡានប៉ូលិសទៅ!»

គាត់ងាកមកសម្លក់អមរាបន្តិចជាការតឿនបង្ខំនាងឱ្យមកតាមគាត់ ហើយរវៃកញ្ចក់បិទភ្លាមធ្វើឱ្យស្រីកូនភ្លោះមិនដឹងធ្វើយ៉ាង ណាបើម្ដាយកំពុងខឹងដល់ម្លឹង នាងក៏បង្ខំចិត្តចាកចោលពៅបញ្ញាទាំងទុក្ខព្រួយ។

រថយន្តទាំងទ្វេបំបោលចេញទៅ ទុកនៅមេធាវីតូចឱ្យនៅឈរហួសចិត្តម្នាក់ឯងទាំងមុខស្រពោន។

ឪពុកក៏បាត់ ជំនួយការក៏សូន្យ បងស្រីក៏គ្មានដំណឹងអ្នកផ្ទះក៏ខឹងមិននិយាយហេតុផល ....
នាងគិតអ្វីមិនចេញមានតែដើរយឺតៗ ទៅរកផ្លូវថ្នល់វិញ។ ដៃស្រីកាន់ទូរសព្ទមួយក៏មិនត្រូវចុចទៅអ្នកណា ធ្វើឲ្យបុរសសង្ហានៅឯណេះយល់ថា នាងមានចេតនាអ្វីបានជាមានទូរសព្ទនឹងដៃប៉ុន្តែបិទមិនឱ្យគេវាយ មកសួរនាំវិញបាន???
....រថយន្តដដែលដែលធ្លាប់ចតប្របេះកែងជើងនាងនៅកម្ពុហោស៍ ពេលនេះបោលមកឈប់ង៉ឹតក្បែរជើងនាងដែលដើរយឺតៗព្រោះចង់បន្លាយ ពេលវេលាឱ្យខ្លួនឯងបានរកឃើញមធ្យោបាយ។
នាងងើបមុខសម្លឹងគេ ដោយខ្សែភ្នែកល្ងើយនិងស្រពោន។
យុត្តនាអាណិតនាង តែគេនៅរក្សាទម្លាប់ផ្គើនចិត្តៈ
«ម៉េចដែរ? អារម្មណ៍ដែលត្រូវគេចោទ?»
នាងស្រាប់តែអរណាស់ពេលឃើញគេ ទោះបីគិតថាគេកំពុងបញ្ចោះបន្ទោកនាងដែលធ្លាប់ចោទគេមុតៗនៅទី ស្នូគ័រនោះក៏ដោយពេលនេះប៉ានាងទើបតែនិយាយរួចនាងបានដឹងថាអ្វីដែលនាងប្រកាន់គេគឺខុសព្រោះអគតិលើគេប៉ុណ្ណោះនាងចង់សុំទោសគេ ដែរ តែគ្មានឱកាស
។
ណាមួយ មួយរយៈពេលនេះនាងឃើញមានព័ត៌មានទាក់ទាមច្រើននឹងបុស្បានារីនាងក៏ កើតចិត្តច្រណែន និងក្នាញ់ស្អប់ក៏ធ្វើហីៗទៅ។

ពេលនេះឃើញគេដំបូងនាងអរ ព្រោះនាងគ្មានអ្នកណា ក្នុងកាលៈទេសៈដ៏លំបាកនេះ ដឹងអីពេលគេលេងសម្តីដៀមដាម នាងស្រាប់តែនឹកឃើញដល់រូបភាពសុភាពបុរសរបស់គេនៅឯភោជនីយដ្ឋាន ជាមួយបុស្បា នាងយល់ថាគេនេះជួបនារីនោះដោយភាពទន់ភ្លន់តែជួបនាងពេលណា វាចាចោលដឹងទាំងដងគួរឱ្យតូចចិត្តបំផុត ទើបស្រីតូចនិយាយទាំងងាកមុខចេញៈ
«ខ្ញុំអត់មានពេលឈ្លោះគ្នាទេយុត្តនា!»
«នាងស្លាប់បន្តិចទៀតនេះហ្អី?»
គេសួរវិញផង ធ្វើឱ្យស្រីតូចសែនមួហ្មង។ នាងជ្រួញចិញ្ចើមដើរចេញវិញលែងរវល់តប ធ្វើឱ្យអ្នកប្រុសចុះរឹងពីឡានបោះជំហានវែងៗតាមពីក្រោយនាងហើយ ចាប់ដៃទាញមកវិញ។
ធីតាអ្នកច្បាប់ ងាកមកវិញហើយសម្លក់គេភ្លែ ឯភ្នែកគេស្រទន់ដូចវាចេះញញឹមដែរ។
ភ្នែកនឹងភ្នែកប៉ះគ្នានារីបែរជាយល់ថា នាងរកឃើញហើយអ្នកដែលនាងអាចបញ្ចេញទុក្ខព្រួយ

បានក្នុងពេលនេះ។
ស្រីស្អាតដែលគ្មានកម្លាំងសេសសល់ចាប់បញ្ចេញទុក្ខព្រួយផ្ទួនៗរបស់នាងទៅកាន់នរៈយើង
៖
«ប៉ាខ្ញុំបាត់ហើយ!»
ទឹកភ្នែកមួយតំណក់វែងអន្លាយធ្លាក់ខ្ទាកមកលើថ្ពាល់ឆ្វេងបើកផ្លូវ ឱ្យមួយតំណក់ផ្សេងទៀត ស្រក់មកឆ្វាចកំដរថ្ពាល់សស្លេកខាងស្តាំ។ នាងមិនដឹងទេថាទឹកភ្នែកដ៏កម្រពីរដំណក់នេះ កំពុងកាប់ចិញ្ច្រាំ ដួងចិត្តយុត្តនា។ ជាច្រើនពេលមកហើយដែលគេរុញនាងឱ្យតឹងតែងនិង ទាល់ច្រក ព្រោះក្នាញ់និងភាពរឹងមាំរបស់នាង គេជួនកាលចង់ឃើញនាងយំ ហើយឃើញ នាងចេះនិយាយអង្វរចិត្តគេចង់ឱ្យនាងទន់ភ្លន់ទន់ខ្សោយចេះ ពឹងពាក់គេឱ្យសមជាមនុស្ស ស្រីខ្លះដែរ តែមិនដែលបានសម្រេចឡើយ។គេកាន់តែធ្វើបាប នាងកាន់តែរឹងមាំ។ ជលនេត្រលើកដំបូងនេះបញ្ជាក់ស្រេចហើយថា នាងកំពុងស្ថិតក្នុងស្ថានភាពលំបាកបំផុត មួយ ដែលនាងលែងជាស្រីចរិតប្រុសបានទៀតហើយ។
«ប៉ានាងបាត់ មានអីទាក់ទងនឹងខ្ញុំ? ឬនាងគិតថាខ្ញុំអ្នកធ្វើទៀតហើយ?»
ឃ្លានេះលេចពីក្នុងចរិតចូលចិត្តឌឺដងរបស់អ្នកប្រុសទីមួយមកទើរ នៅបំពង់ក តែគេមិនដាច់ ចិត្ត បង្ហើបវាចេញក្នុងពេលនេះឡើយព្រោះមិនសមកាលៈទេសៈ។

គេលូកដៃម្ខាងទៅស្ទើនឹងថ្ពាល់នាងហើយចង់ប្រើម្រាមដៃដើម្បី ជូតទឹកភ្នែកដ៏គួរឱ្យពិបាកចិត្ត នោះចេញ តែនាងឯណាព្រមឱ្យប្រុសកំលោះមកប៉ះថ្ពាល់ខ្លួន កណ្តាលផ្លូវដោយងាយដូច្នេះ។ ស្រីស្អាតគៀសដៃគេចេញហើយដើរតម្រង់មកឡើងឡាន រួចអង្គុយផ្លុក។
ឫកពានាងធ្វើឲ្យយុត្តនាទៅជាង៉េមង៉ាម។ ស្រីៗពិតជាមិនអាចយល់អស់មែន....
នរៈបកក្រោយតម្រង់យាន ហើយឡើងមកអង្គុយក្បែរចង្កូត។ នាយងាកមើលនាងបន្តិចមុន ពេលដកក្រដាសជូតមាត់ហុចមក។
រថយន្តរំកិលកង់ គេនិយាយមួយៗដោយសម្លឹងទៅផ្លូវខាងមុខ៖
«បងរិទ្ធិជំនួយការពិសេសនោះបាត់ទៅណា? ម៉េចមិនឱ្យគេទៅចាត់ការរកប៉ានាងមក វិញ????»
ធីតាដកដង្ហើមធំលើកដៃជូតទឹកភ្នែក៖
«បងរិទ្ធិក៏ខលមិនចូលបាត់ទៅទីណាក៏គ្មានដំណឹង! គាត់មិនដែលអញ្ចឹងទេ! សក្ខណាក៏ចាំខ្ញុំ

នៅមុខនេះព្រឹកមិញសុខៗក៏បាត់លែងឃើញដល់ឥឡូវ!»
អ្វីៗហាក់ដូចមិនប្រក្រតីព្រោះខ្លួនគេនេះក៏មិនអាចទាក់ទង ខេមរិទ្ធិដូចគ្នា។ យុត្តនាវរ៉េត្នកវិរៈគិតដៃគេរវើចង្កូតឡាន តែទឹកមុខនៅស្រស់ស្រាយបែបមនុស្សគ្មានទុក្ខព្រួយអ្វីទាំងអស់។ ត្រចៀកគេផ្ទៀងស្ដាប់សម្ដីនាងបន្ត៖
«អ្នកនៅពេទ្យប្រាប់ថាលោកប៉ាទទួលទូរសព្ទមួយហើយប្រញាប់ឱ្យបង វណ្ណៈគ្រាចាកចេញទៅជាបន្ទាន់! លោកមិនដែលទៅណាគ្មានដំណឹងអញ្ចឹងទេលោកនៅដើរមិនទាន់រួចផង!»
ជំនួយការវណ្ណៈជាមនុស្សឆេវឆាវដែលត្រូវនាយប្រដៅក្រោកលែងរួចនៅឯ បន្ទប់ស្នូក័រនោះ តែនាយមិនបានរវល់ គិតពីរឿងហួសទៅ ទេមានតែសួរនាងបកវិញ៖
«ឥឡូវអាគាត់នោះនៅឯណា!»
«គាត់ក៏បាត់ដែរទូរសព្ទបិទអស់!»
យុត្តនាសើចឪចុងមាត់៖
«ល្ងង់ម៉េះ! វាចាប់ជំរិតប៉ានាងហើយ! បើកទូរសព្ទចាំស្ដាប់វាទារលុយទៅ!»
ពៅបញ្ញាក្ដុកក្ដួលក្នុងចិត្ត។ នាងបានគិតពីរឿងចាប់ជំរិតតែមនុស្សបាត់ស្ងាត់សូន្យដល់ទៅប្អូននាក់ នាងក៏មិនដែលសង្ស័យថាជំនួយការទាំងទ្វេណាម្នាក់ទាក់ទងនឹងការ បាត់ខ្លួននេះនោះដែរ។នាងតបនឹងគេតម្អូញតិចៗ៖
«ទូរសព្ទខ្ញុំក៏បាត់ដែរ! ព្រឹកមិញខ្ញុំទុកនៅនឹងសក្ខណា! ពេលគេចេញទៅ គេយករបស់ខ្ញុំទៅជាមួយទាំងអស់!»
យុត្តានាងាកមុខមករកនាងជាបន្ទាន់។
អ្នកប្រុសសម្លឹងទៅកែវភ្នែកស្រពោនដែលស្រីស្អាតកំពុងមើលមកក្នុងភាពថានាងទាល់គំនិតហើយ។
គេជ្រួញចិញ្ចើម ៖
«ម៉ោងប៉ុន្មាន? សក្ខណាបាត់ទៅនៅម៉ោងប៉ុន្មាន??»
«ពីព្រហាមស្រាងៗម៉ោងមិនដល់៦ព្រឹកផងយ៉ាង!»
យុត្តនាវរ៉េត្នកគិតគេលូកយកទូរសព្ទហើយចុច SMS ដែលគេទទួលបាននោះបង្ហាញនាង៖
«ចុះនេះ??? នេះស្អីគេ???.....ជួយផង!!!! គេបញ្ជូនទៅខេត្ត! ប្រយ័ត្នលេខាប៉េង.....»
ដំបូង អ្នកគឺគ្រាន់តែចង់រំលឹកឡើងវិញពី SMS របស់នាងប៉ុណ្ណោះ ប៉ុន្តែពេលអានដល់ឃ្លាចុង

ក្រោយគេអាក់មកវិញ ព្រោះទើបនឹងចាប់អារម្មណ៍អ្វីមួយ។ គេបង្ហាញភាពសញ្ជឹងគិតប្រយ័ត្ន ប្រយែងលើផ្ទៃមុខ។

...តើអាចថាសក្ខណាជាអ្នកខលមកទេ....? អញ្ចឹងមានតែនាងត្រូវគេចាប់ ហើយខំផ្ញើសារមកឱ្យអ្នកជួយ? តែបើជានាងម៉េចក៏នាងផ្ញើមកលេខខ្លួនទៅវិញ...មនុស្សមិនដែលមានទំនាក់ទំនង អ្វីផង?....ចំណែកឃ្លាចុងក្រោយនេះទៀត....? ចុះនាងទៅស្គាល់លេខាប៉េងពីពេលណាមក?

ពៅបញ្ញាប្រញាប់ទាញទូរសព្ទទៅមើល ហើយនាងងាកមកវិញទាំងបើកភ្នែកធំៗជាមួយការភ្លាត់មាត់សួរ៖

«សក្ខណាសរសេរមក???»

នាងកាន់តែភ័យកាន់តែញ័រដៃ ឯយុត្តនានៅតែរភ្នែកគិតចុះឡើង។

នៅមិននៅមានទាក់ទងអីជាមួយលេខាប៉េង ?

គេនឹកឃើញសម្ដីរិទ្ធមួយរយៈចុងក្រោយនេះ ដែលតែងតែរំលឹកគេពីសកម្មភាពផ្សេងៗរបស់តាចាស់នៅក្បែរឪពុកធម៌ ខ្លួនជានិច្ច។ បើថា SMS នេះជារបស់រិទ្ធទើបសមទំនងជាង?

គេងាកសួរនាងតិចៗ៖

«មានSaveលេខខ្ញុំអត់?»

ស្រីតូចតបវិញទាំងងាកមុខចេញព្រោះទើសទាល់៖

«អត់....អត់ទេ!»

យុត្តនាសើច៖

«មកពីនាងចាំលេខខ្ញុំស្ទាត់មែនអត់មេធាវី???»

ស្រីស្អាតអៀនហើយស្អុតស្អាញផងក៏ថាឱ្យគេវិញ៖

«ឈប់និយាយរឿងអត់បានការទៅ!»

«សម័យឥឡូវគេមិនសូវចូលចិត្តការទេ!»

«យុត្តនា.....?»

នាងងាកមកសម្លក់គេទាំងក្នាញ់ព្រោះមិនចង់ឱ្យគេបន្តទៀត។ នាងដឹងថាបើនាងចង់ឌឺគេតបមានអូសក្រឡាគេឱ្យមានឱកាសវែងឆ្ងាយ ជាងនេះ ព្រោះថាគេនេះមិនចេះទាល់ទេថាទៅមួយម៉ាត់មកវិញ១០ដង។

យុត្តនាតបធ្វើហឺះ
«លេងតិចតួចប្តូរបរិយាកាសផងមិនបាន? តិចឈប់ជួយគិតអាឡូវ!»
ស្រីតូចដកដង្ហើមធំ។ នាងសម្លឹងទៅទឹកមុខគេដែលនិយាយលេងសើចតែបង្ហាញសញ្ញារិះគិតតឹងតែង តាមពន្លឺភ្នែកហើយមុខសម្លឹងត្រង់ទៅមុខ។
នាងទើបតែចាប់អារម្មណ៍ថាម្នាក់នៅខាងឆ្វេងដៃនាងនេះពិតជាជួន កាលប៉ប្លែកប៉ប្លូចហួសមែន តែគេក៏មើលទៅមានបញ្ញាមិនធម្មតាដែរ។ បើមិនអញ្ចឹងកាលណោះគេម៉េចអាចរកឃើញអ្នកនៅពីក្រោយលុយ១១លាន ហើយអាចរក Mr Johanឃើញ?
មិនដឹងយ៉ាងម៉េចនាងទទួលអារម្មណ៍ថាឱ្យតែពេលជួបរឿងលំបាកៗ នាងទុកចិត្តនិងមានជំនឿចិត្តលើសមត្ថភាពគេយ៉ាងនេះ? លក្ខណៈពិសេសរបស់គេគឺទោះក្នុងកាលៈទេសៈចិត្តគេកំពុងគិតការសំខាន់ យ៉ាងណាក៏គេនៅតែអាចធ្វើអារម្មណ៍ងាកមកនិយាយលេងសើចបាន????
សំឡេងគេលាន់មកកាត់ផ្តាច់ការគិតរបស់នាង៖
«រិទ្ធិនៅក្បែរសក្ខណាទេដឹងព្រោះសក្ខណាមានដែលស្គាល់ខ្ញុំឯណា? មនុស្សយើងពេលជួបគ្រោះថ្នាក់គេមិនដែលcall រកមនុស្សមិនស្គាល់គ្នាទេ!»
ក្នុងភាពង៉េមង៉ាមមិនដឹងគិតយ៉ាងណា ពៅបញ្ញាមិនបានចាប់អារម្មណ៍ទេថាហេតុអ្វីគេហៅឈ្មោះជំនួយការប៉ានាង ស្និទ្ធស្នាលម្ល៉េះ នាងតបទាំងញ័រមាត់ពេលនឹកឃើញដល់បងស្រីឧសម្តាយ៖
«បងរិទ្ធិអ្ហេស់? តែ....គាត់ក៏....អត់ស្គាល់លេខលោកដែរ? គាត់គ្មានរឿងអីត្រូវខលរកលោកទេហើយព្រឹកមិញសក្ខណានៅក្នុងឡាន ម្នាក់ឯងតែប៉ុណ្ណោះ?»
នារីឆ្លើយតាមជាក់ស្តែង ប៉ុន្តែយុត្តនាគិតពីរឿងផ្សេង។ ប្រសិនបើអ្នកដែល SMS នោះមិនមែនជាសក្ខណាហើយក៏មិនមែនរិទ្ធិ តើគេជានរណា? ហើយគេមានចេតនាអ្វី? បើគេគ្រាន់តែរាវលេខ មានរឿងអីត្រូវរាវអ្នកកំលោះស្រាប់តែបើកភ្នែកធំៗ ព្រោះគេទើបនឹកឃើញដល់រឿងសំខាន់មួយ ។
«ម្នាក់នោះដឹងថាយើងស្រលាញ់ស្រីឆ្នាសនេះ ហើយប្រើលេខនាងព្រោះចង់ពង្វាងយើងឱ្យចូលអន្ទាក់វាដឹង? អញ្ចឹងវាជាអ្នកណា? វាប្រើវិធីនេះដូចគ្នាទៅលើរិទ្ធិ ដែរបានជាគេបាត់ខ្លួន? អញ្ចឹងមានតែវាជាមនុស្សនៅក្បែរៗពីរនាក់បងប្អូនយើង?»

អ្នកនឹកឃើញភ្លាមដល់ឈ្មោះលេខាប៉េងនៅចុងបញ្ចប់នៃ SMS ។
«ចុះម៉េចវាឱ្យយើងប្រយ័ត្នលេខាប៉េង? បុស្បាជាក្នុយគាត់ក៏មានចេតនានាំយើងចេញទៅក្រៅស្រុកទៀត តាលេខាហ្នឹងមានទាក់ទងអីជាមួយរឿងអស់នេះដែរអត់?»
«ប៉ា????»
អ្នកប្រុសទីមួយគិតដល់ ហួត ស៊ីវ ។ គេលូករកទូរសព្ទ ស្របនារីសួរមកតិចៗ៖
«យុត្តនា! លោកគិតឃើញអីខ្លះហើយ?»
គេមិនមាត់ព្រោះមិនអាចប្រាប់នាងឱ្យដឹងថាគេកំពុងគិតដល់ប៉ាធម៌គេឡើយ។
ប្រសិនបើ ហួត ស៊ីវ ពិតជានៅក្រោយការបាត់ខ្លួនរបស់សក្ខណា និង ប៉ែន ពេជ្រ តើគេអាចជួយនាងដោយវិធីណា?
សំណួរជាច្រើននេះមិនបានបង្អាក់សកម្មភាពដ៏សកម្មរបស់យុត្តនាឡើយ។ អ្នកប្រុសងាកមករកស្រីស្នេហ៍ហើយលើកដៃមួយជាសញ្ញាឱ្យនាងទុកពេល ឱ្យអ្នកបាននិយាយទូរសព្ទសិនហើយគេខលទៅរកឪពុកក្រោមភាពងឿងឆ្ងល់របស់នាង។ តែ .....ទូរសព្ទ ហួត ស៊ីវ គឺមិនអាចទាក់ទងបាន។
គេបន្តទៅរកលេខាប៉េងលទ្ធផលក៏ដូចគ្នា។
....ជាលើកទីមួយដែលពៅបញ្ញាសម្គាល់ឃើញថាបុរសអ្នកលេងហាក់លោតម្នាក់នេះជ្រួញចិញ្ចើមបញ្ចេញភាពតឹងតែងលើផ្ទៃមុខ។
ដៃគេចុចទៅអ្នកទីបីទៀតព្រោះពីរនាក់មុនចុចមិនចូលទៅហើយ។
«ពិភពលោកនេះរលាយហើយមែនអត់? ម្នាក់ៗសុទ្ធតែបិទទូរសព្ទ???»
គេរអ៊ូបណ្ដើរ ត្រចៀកឮសូរស្នូរចុចទទួលពីចុងម្ខាងធ្វើឱ្យគេមានអារម្មណ៍ថាអរ ចម្លែក។
យុត្តនាប្រញាប់ចាក់សំណួរទៅភ្លាម៖
«Hi! Mrs. Margaret , my dad had to work today? អ្នកស្រីម៉ាហ្គារ៉េត ប៉ាខ្ញុំមានទៅធ្វើការទេថ្ងៃនេះ?»
«sir, he had left more than 1hour ago ! ចំាទាន! តែលោកអគ្គត្រលប់ទៅវិញជាងមួយម៉ោងមុននេះហើយ!»
«oh! So he´d been there . o.k and how about Mr. Peng ? អូ! អញ្ចឹង? ចុះនែ់លេខាប៉េង?»
«Yep, he came along and process 1 milion USD in cash sir ! ចំា គាត់បានមក

ជាមួយលោកអគ្គហើយរៀបឯកសារបើកលុយ សុទ្ធមួយលានដុល្លារ!»
«What ?????1 million ? ស្អីគេ???? មួយលានដុល្លារ?!»
«sure sir! ចាំ គឺមួយលានដុល្លារទាន!»
«Thank you Mrs. Margaret!»

គេដាក់ទូរសព្ទចុះក្នុងពេលដែលពៅបញ្ញាងាកមុខចេញតែនាងលបពិចារណាពីគេ។ ម្នាក់នេះជាអ្នកលេងហក់លោតមិនទាន់អីផង បានឡើងជានាយកធនាគារដូចគេជប់។ សំអាងតែលើអតីតកាលរបស់គេជាកូនរបស់អ៊ំយុទ្ធហើយ ហួត ស៊ីវ យល់ថាជាកូនមិត្តគាត់ហើយឱ្យតំណែងធំយ៉ាងនេះទៅគេកើតដែរ? ឬមួយគេពិតជាមានសមត្ថភាពពិសេសអ្វីមួយមែន?.....ពិនិត្យយ៉ាងណាក៏មិន ទំនងដែរមនុស្សដូចគេនេះ? សម្ដីចោលដឹងទាំងដងធ្វើមេគេរបៀបណាទៅ?....ទេមិញនេះគេនិយាយជាមួយ កូនចៅគេអីក៏ថ្លៃថ្នូរម៉េះ ប្រើភាសាអង់គ្លេសស្ទាត់ទៀត តើគេជាអ្នកណាឱ្យប្រាកដ?
....ទម្លាប់គេគឺនិយាយច្រើនពេលនៅជិតនាងចុះម៉េចពេលនេះនាងងាកមុខ ចេញយូរហើយនៅតែមិនឮគេនិយាយអ្វី....នាងងាកត្រលប់ទៅវិញសម្លឹងផ្ទៃ មុខដ៏តឹងតែងរបស់គេ។.....យុត្តនាកំពុងមើលត្រង់ទៅដងផ្លូវ គេបើកបរនឹងនប៉ុន្តែទឹកមុខគេប្រែប្រួលចុះឡើងទៅតាមការគិតរបស់ គេ។
«ក្រែងលោកអ៊ំខូចទៅយូរហើយ! មិញនេះលោកហៅពីណាថាប៉ា?»
គេងាកមកខ្វាច់ជាមួយស្នាមញញឹមបន្លប់ពីលើទឹកមុខខ្វល់ខ្វាយ៖
«ប៉ាក្មេក! បានអត់អញ្ចឹង?»
ពៅបញ្ញាក្ដាប់មាត់របៀបក្នាញ់....នាងដឹងថាគេនិយាយលេងតែមិនដឹងយ៉ាង ម៉េចពាក្យនេះធ្វើឱ្យនាងនឹកឃើញដល់ស្រីស្អាតដ៏ល្បីឈ្មោះ«បុស្បា នារី»។
«អញ្ចឹងប្រញាប់ទៅរកប្រពន្ធនិងប៉ាក្មេកលោកចុះ! ខ្ញុំចុះទីនេះបានហើយ!»
«អ្នកច្បាប់ចេះងរង៉ក់ដែរ?»
«ពីណាងរង៉ក់!»
«ដឹងហ្អ៎ាគេ?»
«សម្បូររឿងស្រមៃណាស់! គ្មានពេលកំដរទេ! សូមឈប់ឡានទៅនាយកធនាគារ!»
ជាលើកទីមួយដែលគេឮនាងប្ដូរមកហៅងាររអាជីពរបស់គេ គេមមីភ្នែកសើចៈ

«ទៅណា?»
«ហើយខ្ញុំខ្ចីទូរសព្ទលោកទៅផងបានអត់?»
«យកធ្វើអី?»
«ប្ដឹងប៉ូលិស! គឺទូរសព្ទខ្ញុំបាត់ទៅ ខ្ញុំចង់ឱ្យគេរកហេតុផលពីក្រោយSMSនេះ!»
«ទូរសព្ទក៏មិនឱ្យខ្ចី! មនុស្សក៏មិនឱ្យចុះ!»
នាងចងចិញ្ចើមងាកមើលគេវិញដោយហួសចិត្តៈ
«លោកយ៉ាប់ហើយ!»
«យ៉ាប់ស្អី?? ប៉ូលិសអស់នោះគ្មានស្អីគួរឱ្យទុកចិត្តទេ!»
«លោកទេដែលមិនគួរឱ្យទុកចិត្ត!»
«ខ្ញុំគ្មានពេលកំដរនាងបឺតមាត់ទេមេធាវី!»គេនិយាយដោយធ្វើមុខឌឺ ហើយសម្លឹងនាងដោយភ្នែកស្រទន់។ នាងព្រិចភ្នែកព្រោះគ្រឹតៈ
«លោក…..????»

គេដឹងថានាងមិនសុខចិត្ត ដែលនិយាយមិនចេះឈ្នះតែគ្មានសញ្ញាបង្ហាញមកថានាងស្អប់អ្នកឱ្យ ជ្រាលជ្រៅដូចកាលនៅកន្លែងវាយស្នូគ័រទេ។ គេលេងសើចអស់ចិត្ត ក៏បន្ថយល្បឿនបត់ឡានចូលផ្ទះនាងហើយទម្លាក់សំឡេងនិយាយស្មើៗៈ
«សភាពការណ៍ដូចមិនសូវល្អទេ! ទៅណាក៏កុំទាន់ទៅទាំងអស់ សំងំក្នុងផ្ទះចាំដំណឹងពីខ្ញុំ!»
នារីបើកភ្នែកមូលក្លុំសម្លឹងអ្នកប្រុសទីមួយ គេនិយាយបន្តៈ
«អគ្គទេសាភិបាល ហួត ស៊ីវ ក៏បាត់ខ្លួនដែរ! ខ្ញុំសង្ស័យថារឿងទាំងអស់នេះទាក់ទងគ្នា! ម្នាក់នោះប្រហែលប្រើទូរសព្ទនាងខលមកប៉ានាង ឬក៏យកករណីសក្ខណាបង្ខំប៉ានាងឱ្យចេញទៅ! គេក៏អាចប្រើវិធីនេះដូចគ្នាទៅលើបងវិទ្ធិរបស់នាងដែរ! មិនដឹងមួយណាឱ្យប្រាកទេ ខ្ញុំគ្រាន់តែសង្ស័យប៉ុណ្ណោះ! ចាំខ្ញុំឱ្យគេតាមមើលសិន!»
នាងមិនដឹងថា គេជាឪពុកនិងកូនធម៌ជាមួយ ហួត ស៊ីវ ទេ តែដឹងថាគេប្រាកដជាមានទំនាក់ទំនងពិសេសជាមួយបុរសមិត្តចាស់របស់ ប៉ាខ្លួនបានជានៅមិននៅគេអាចទទួលបានតំណែងកំពូលនៅគ្រឹះស្ថាន ហិរញ្ញវត្ថុរបស់គាត់។
ទោះនាងមិនរវល់ពីការបាត់ខ្លួនរបស់បុរសចំណាស់ នោះតែគាត់និងប៉ានាងជាមិត្តនឹងគ្នា ប្រសិនបើពេលនេះពិតជាបាត់ទៅដំណាលគ្នា តើមិនឱ្យនាងរំជើបរំជួលម៉េចបាន?

«អ្នកណាទៅកំពុងធ្វើរឿងអស់នេះ? ទល់ដែនណាមួយដែលម្ចាស់ SMSនេះចង់និយាយ! ស្ថានភាពគេប្រហែលគ្មានពេលសរសេរវែង?»សំឡេងអ្នកប្រុសទីមួយលាន់មក ខ្សោយៗ ហាក់ដូចជាគេកំពុងពិចារណាដោយប្រយ័ត្នប្រយែងលើសភាពការណ៍ ចុងក្រោយនេះ។ តរុណីកាន់តែមិនស្រួលចិត្តនាងនិយាយតឿនគេភ្លាម៖

«អញ្ចឹងយើងរឹតតែត្រូវប្រញាប់ប្ដឹងប៉ូលិសទៀតហើយ!»នាងនិយាយមកវិញទាំងមុខស្លេក។

«អត់ទេ! បើធ្វើអញ្ចឹងបានផលប៉ានាងគាត់ធ្វើហើយ! គាត់មិនមែនសុខចិត្តចាកចេញពីពេទ្យស្ងាត់ៗទេពៅបញ្ញា!»

នាងបង្អង់សម្ដីតែភ្នែកក្រឡឹតក្រឡាប់ព្រោះបារម្ភពីឪពុក។

«បានយុត្តនា! ខ្ញុំអត់ទៅប្ដឹងប៉ូលិសតែលោកត្រូវឱ្យខ្ញុំទៅជាមួយលោក!»

គេងាកមកមើលមុខនាងទាំងញញឹមចុងមាត់។

«នឹកខ្ញុំដល់ម្លឹងមេធាវី?»

នាងគ្មានពេលលេងសើចក៏និយាយវិញភ្លាម៖

«លោកដឹងហើយខ្ញុំដេកមិនលក់ទេ!»

«តែខ្ញុំមានការសំខាន់ត្រូវធ្វើ! ចាំថ្ងៃក្រោយទៅ...»

ដឹងថាគេឱលេងនាងនិយាយពន្យល់៖

«ខ្ញុំចង់ប្រាប់លោកថាលោកប៉ាជាជីវិតខ្ញុំ សក្ខណាជាបងនិងជាមិត្តល្អរបស់ខ្ញុំ បងរិទ្ធិ បងវណ្ណៈ គ្រប់គ្នាសុទ្ធតែបាត់ទៅណាមិនដឹង! លោកឱ្យខ្ញុំត្រលប់ទៅវិញគេងលក់កើតដែរ?»

អ្នកប្រុសដកដង្ហើមយូរ គេសើច៖

«ទៅបានតើ! តែប្រយ័ត្នពិបាកខ្លួន!»

គេបត់ឡានបកក្រោយវេរទាំងទទឹងទិសព្រោះតែចិត្តអន្ទះសាពី បញ្ហាចម្លែកៗក្នុងថ្ងៃនេះឬក៏បានស្រីស្អាតមកអង្គុយលើកទឹក ចិត្តបានជាមានកម្លាំងចិត្តបោលឡានយ៉ាងនេះក៏មិនដឹង។ តាមធម្មតា ពៅបញ្ញាប្រាកដជាថាឱ្យគេនូវវិធីបើករថយន្តដ៏យ៉ាប់នេះ ប៉ុន្តែថ្ងៃនេះនាងបែរជាអន្ទះសាមិនខុសពីគេដែរ។

...រថយន្តបោះពួយទៅទិសខាងលិចក្រុងភ្នំពេញ នាំទៅទាំងស្រីប្រុសគួរឱ្យគ្នាន់ក្នាញ់ទាំងទ្វេ ទៅជាមួយក្រោម ស្រមោលថ្ងៃបាក់រសៀល។

«យើងទៅណា?»នាងសួរគេស្រាលៗព្រោះគេហាក់ដូចជាកំពុងរិះគិតអ្វីម្យ៉ាងជ្រៅៗ មិនមាត់

មិនកមិននិយាយចេញមកសោះ។
«ទៅដល់គង់តែដឹងទេ!»

១០នាទីក្រោយ គេឈប់រថយន្តង៉ក់ក្រោមផ្ទះលេខាប៉េង។
«តោះយើង!»
គេបើកទ្វារចេញហើយហៅនាងឱ្យចុះមកតាម។
ស្រីតូចឈានចេញមកទាំងចម្ងល់ហើយងើបមុខសម្លឹងអាគារខ្ពស់បីជាន់ នៅពីមុខខ្លួន។ វាជាពពួកសំណង់ចាស់ៗសល់តាំងពីសម័យអាណានិគមបារាំង ហើយនាងមិនដែលស្គាល់អ្នកណារស់នៅទីនេះទេ។
«យើងរកពីណាគេនៅទីនេះ?»
គេមិនមាត់ហើយលូកដៃមកចាប់កដៃនាងទាញទៅរកជណ្ដើរថ្មើរជើងមួយតូចចង្អៀតនៅផ្នែកចុងខាងឆ្វេងបង្អស់នៃអាគារ។
...មកដល់ជាន់ទីពីរនៃអាគារចាស់ដែលស្ងាត់ជ្រងំហើយងងឹត ស្រពិចស្រពិល យុត្តនាលើកដៃស្ទាបពិនិត្យស្ថានភាព សោផ្ទះដែលចាក់ពីក្រៅពីរបីត្រួត។ គេរវៃភ្នែកឆ្វេងស្ដាំ ហើយប្រទះឃើញបន្ទះដែកមួយមាំគួរសមទុកចោលនៅឯបង្កាន់ដៃខាងក្រៅ។
គេឱនទៅយករបស់នោះក្នុងពេលដែលនារីអ្នកច្បាប់បើកភ្នែកធំៗ។ ទេសាភិបាលស្រស់សង្ហាចាប់ ផ្ដើមគាស់ផ្ដាច់ច្រវាក់សោយ៉ាងស្ទាត់ជំនាញ តែសំឡេងស្រីតូចលាន់មកតិចៗទាំងភិតភ័យ៖
«យុត្តនា! ធ្វើអញ្ចឹងខុសច្បាប់ណ៎ា!»
គេហួសចិត្ត..... ក៏បញ្ឈប់ដៃហើយងាកមកធ្វើសញ្ញាឱ្យនាងរក្សាការស្ងាត់ស្ងៀមទើប ចាប់ផ្ដើមចាត់ការបន្តទៀតក្នុងពេលដែលភាគីខាងនារីរនេត្រា ក្រឡឹបក្រឡាប់មើលផ្លូវឱ្យទាំងភ្នែកនៅកញ្ចឹងក។

...ឆឹង...មិនដល់មួយនាទីច្រវាក់របូតធ្លាក់អស់ ហើយគេចាប់ផ្ដើមងាកមកសើចស្ញាញដាក់នាង។
«ចូលអត់មេធាវី?»
គេសួរឌឺហើយរុញទ្វារដែករបើកទៅខាងលាន់សូរក្រឹង!
...យុត្តនាលូកមកចាប់កដៃស្រីតូចសាជាថ្មីហើយអូសនាងដើរយឺតៗចូលទៅខាងក្នុង។

....គេចុចបើកភ្លើងបំភ្លឺដូចធ្លាប់ស្គាល់ផ្ទះនេះពីមុនមក....
....ផ្ទះលេខាប៉េងតូចចង្អៀតមិនដល់៦ម៉ែត្រផង តែអីវ៉ាន់រៀបចំស្អុកណាស់ តាមរបៀបរស់នៅរបស់ជនជាតិចិន។
.....តុធ្វើការ....តុទឹកតែ គ្រែដេក ទូខោអាវ។ល។ អ្វីៗស្ថិតនៅក្នុងបន្ទប់នេះទាំងអស់។ គេលែងដៃពីនាងសន្សឹមៗហើយឈានទៅរកតុធ្វើការរបស់បុរសនោះ។ គេឆែកឆេរអ្វីៗលើតុគាត់ហើយថតតុនិងក្រោមតុទៀត។
«ផ្ទះអ្នកណាគេ? ហើយលោកមានសិទ្ធិអីធ្វើអញ្ចឹងយុត្តនា?»
គេមិនខឹងនិងភាពចលាចលរបស់នាងហើយក៏គ្មានពេលពន្យល់ដែរ តែគេនិយាយខ្សឹបៗតិចៗតបនឹងសំណួរនាង៖
«ផ្ទះលេខាប៉េង!»

នារីនឹកឃើញដល់ឃ្លាចុងក្រោយនៃ SMS ដែលផ្ដាំប្រយ័ត្នលេខាប៉េងនេះ។
នាងមិនដឹងថាតើយុត្តនាមានតម្រុយអ្វីទាក់ទងនឹងSMS នោះដែរទេ ប៉ុន្តែនាងចាប់ផ្ដើមមានអារម្មណ៍ភ័យខ្លាចហើយរេភ្នែកសម្លឹងពិនិត្យ ជុំវិញបន្ទប់។
ស្រីតូចនៅទើរក្រសៃភ្នែកចំពោះផ្ទាំងរូបថតនារីម៉ូដែល បុស្បានារីដ៏ស្រស់ប្រិមប្រិយលើជញ្ជាំងក្បែរគ្រែពូកតូចមួយម៉ែត្រ ពីរតឹករបស់លេខាប៉េង។ នាងនឹកក្នុងចិត្តទាំងច្រណែននឹងរូបសម្ផស្សល្អហួសពណ៌នារបស់នារី ជាដួងតារានោះ។
«សូម្បីលេខាប៉េងម្នាក់នេះក៏ឆ្កួតវង្វេងតាំងរូបនាងគ្រាន់នឹងគេង មើលរាល់យប់ដែរ កុំថាឡើយបុរសខិលខូចយុត្តនានេះទៀត»
នាងងាកក្រោយទៅរកគេក៏ឃើញគេកំពុងផ្ដោតភ្នែកសម្លឹងមករូបសិល្បៈ ដ៏ល្អវិចិត្រនេះមិនដាក់ភ្នែកដូចគ្នា។ ប្រការនេះធ្វើឲ្យពៅបញ្ញារិះគិតទាំងសៅហ្មងក្នាញ់ខឹងនឹងនាយ៖
«តើបុរសណាទៅមិនឈ្លក់វង្វេងនឹងសម្រស់ស្រី???! ទម្រាំបើនារីម្នាក់នេះស្អាតថ្នាក់ហ្នឹងតើមិនឱ្យគេភ្លឹក ភ្លាំងម៉េចនឹងបាន!»
នៅឯណេះយុត្តនាសម្លឹងនាងព្រោះនឹកព្រួចអាណិតនាងដែលជាប់លើយន្តហោះទៅជប៉ុនតែម្នាក់ឯង។

គេដឹងថាគេបានធ្វើកំហុសធ្ងន់មួយដែលចាកចោលនាងដោយមិនបានលា តែគេត្រូវតែធ្វើព្រោះមុនចូលទៅក្នុងយន្តហោះ ប៉ាធម៌ខ្លួនបាន SMSមកថា «កូនប្រុស! បើសិនអាច កូនកុំ

ទៅឆ្ងាយពីភ្នំពេញក្នុងរវាងប៉ុន្មានថ្ងៃនេះ!»ពេលនោះគឺ លោកប៉ាគេប្រាកដបានតម្រុយអ្វីជុំវិញការបាត់ខ្លួននៅពេលនេះបានជា លោកដាច់ចិត្តផ្ញើសារនេះមក។

តែគេមិនដឹងថាពេលនោះគឺ ហួត ស៊ីវ បានទទួលទូរសព្ទគំរាមទារប្រាក់រួចទៅហើយគ្រាន់តែគាត់មិនអាច និយាយប្រាប់កូនប្រុសច្បង ព្រោះមិនចង់ឱ្យមានបញ្ហាដល់រិទ្ធិដែលស្ថិតនៅក្នុងក្នុងកណ្ដាប់ ដៃគេនោះ។
ទោះបីកន្លងមកគេគ្រាន់តែលេងល្បែងស្និទ្ធស្នាលជាមួយនាងដោយចង់ ដឹងថា តើនាងមានគោលដៅយ៉ាងណា តែគេក៏មិនដែលមានបំណងថានឹងទៅជប៉ុនជាមួយនាងពីរនាក់ទេ រហូតដល់គេរកឃើញមូលហេតុពិតនៅពីក្រោយការបង្ហាញខ្លួនរបស់នាងមក ក្នុងជីវិតគេ ដែលគេជឿថាវាមិនមែនជាស្នេហាឡើយ។ គេដឹងថានាងប្រាកដជាមានបំណងអ្វីមួយក្នុងការពង្វាងគេឱ្យចេញទៅ ឆ្ងាយនេះហើយសារចុងក្រោយរបស់ ហួត ស៊ីវ ហាក់ស៊ីសង្វាក់ណាស់ជាមួយការគិតរបស់គេហេតុដូច្នេះហើយគេមានតែ កាត់ចិត្តរើសយកវិធីគ្មានមេត្តានេះគឺនាំនាងឡើងយន្តហោះរង់ចាំ ដល់ពេលនាងចុះមកវិញលែងកើតទើបគេចេញមកចោលនាង។

……..ទ្វារផ្ទះបិទបើកទៅវិញទៅមកខ្ទាចៗ នាំទាំងរាងកាយតូចច្រឡឹងរបស់ពៅបញ្ញាចេញទៅក្រៅផង។ គេដឹងថាគេឈរសម្លឹងរូបតារាស្រីយូរយ៉ាងនេះនាងប្រាកដជាយល់ ផ្សេងហើយកើតរោគប្រចណ្ឌ ទើបបានអ្នកប្រុសទីមួយឈានមួយៗទាំងញញឹមតម្រង់ទៅរកស្រីតូចដែល ឈរក្រពាត់ដៃមុខក្រញូវនៅពីមុខផ្ទះ៖
«អីគេ? មេធាវីចេះប្រចណ្ឌដែរ!»
គេនិយាយដៀមដាមពីក្រោយខ្នងនាងធ្វើឱ្យស្រីតូចមួហ្មងលើសមុន នាងបែរមកវិញទាំងមុខក្រញូវ៖
«ពីណាប្រចណ្ឌ?»
«ដឹងពីណា?»
«រោគចិត្ត!»
«រោគចិត្តមែនទែន ហ្នឹងដឹងពីណាទេ!?»
«លោកចង់ថាម៉េច?»
«មានថាម៉េច! គ្រាន់តែអាណិតមនុស្សខ្លះដែលនៅសុខៗរត់ចេញមកក្រៅ!»
«ខាងក្នុងកខ្វក់ ធំក្លិនអាក្រក់! នៅសុខៗលោកមកកន្លែងនេះធ្វើអី?»

នាងថាហើយដើរចោលគេប៉ើកៗទៅកាន់ជណ្ដើរធ្វើឲ្យអ្នកប្រុសត្រូវដើរវែងៗទៅតាមព្រោះនាងកាន់តែខឹងដើរកាន់តែញាប់។

«ពូកែខឹងអញ្ចឹងសមនឹងបញ្ជូនឱ្យទៅដេកខឹងនៅផ្ទះម្នាក់ឯង!»

ស្រីស្អាតស្រាប់តែទច់ដំណើរបែរក្រោយខ្វាកស្ទើរបុកប៉ះនឹងទ្រូងនាយ។

«លោកថាម៉េច? មុននេះអ្នកណាសន្យាថា!..... »

«តែពេលនេះខ្ញុំនាំនាងទៅទៀតមិនបានទេ!....»

គេនិយាយហើយដើរហួសពីនាងក្នុងចេតនាគេចដោយចុះជណ្ដើរញាប់ស្មេរ តម្រង់ទៅជាន់ខាងក្រោមធ្វើឱ្យស្រីតូចប្រឹងចុះតាមទាំងហត់គយូស។ ទឹកមុខគេគ្មានអ្វីតឹងតែងទេម៉េចក៏កាយវិការគេប្រញាប់ម្ល៉េះ ហ្ន៎? ស្រីតូចគិតផងឈរសម្លក់គេពីជណ្ដើរ។ នរៈដែលនៅក្នុងរថយន្តទៅជាអស់សំណើចគេ រវែកញ្ចក់អើតមកមកនិយាយបញ្ឈឺ៖

«ម៉េច? ចង់នៅជួយលាងផ្ទះឱ្យគាត់អ្វី? ឡើងមក!»

សាជាថ្មីស្រីតូចកើតចិត្តសៅហ្មងនឹងចរិតគ្មានភាពផ្អែមល្ហែមរបស់គេ។

ពេលឡើងគេចេះដឹកដៃនាងឡើងហេតុអ្វីពេលនេះគេអន្ទះសារហួតដល់ ថ្នាក់រត់ចុះមកសឹងថាគេចពីនាង។ កំពុងសៅហ្មងមិនទាន់អង្គុយជាប់នឹងកៅអីស្រួលបួលផងអ្វីមួយត្រូវ បានហុចមកឱ្យនាង។

ពៅបញ្ញាទទួលសន្លឹករូបថតដ៏សំខាន់នោះមកមើលទាំងធ្លាក់ថ្លើមក្នុកឯ អ្នកប្រុសទីមួយកំពុងតែរវៃចង្កូតចេញឡាន បកក្រោយយ៉ាងរហ័ស។

នៅលើសន្លឹករូបថតដែលប្រែទៅជាពណ៌ពងមាន់ទៅហើយ  ពៅបញ្ញាឃើញរូបសិស្សប្រុសៗបួននាក់ដែលឈរប្រកៀកគ្នា។ នាងស្គាល់ម្នាក់ដែលជាប៉ារបស់ខ្លួន ឯបីនាក់ទៀតគេចាំស្រពិចស្រពិលព្រោះពួកគេក្មេងៗពេក។

នាងងើបមុខសម្លឹងគេដែលប្រកបដោយទឹកមុខតឹងតែង។ ជាលើកទីមួយដែលនាងឃើញគេមានសភាពប្រុងប្រយ័ត្នក្នុងការគិតដល់ ថ្នាក់នេះ ព្រោះរាល់ដងឱ្យតែជួបមុខគ្នាបើគ្មានសម្ដីគំរាមសម្ដីឌឺដងបញ្ឆោះ ឱ្យខឹងគេក៏មានទឹកមុខឈ្លើយកប់អាកាសនិងនិយាយអ្វីក៏ផុយក៏មិនពីរោះស្ដាប់ដូចមនុស្សមិនចេះគិតទេ។

ម្ដងនេះគេប្រថាប់ប្រភីងរត់មកតម្រង់ឡានព្រោះតែគេរកឃើញរូបថត នេះពីផ្ទះលេខាប៉េងហើយតើវាមានអ្វីក្នុងនេះដែលធ្វើឱ្យគេ អន្ទះសាដល់ម្លឹង។

«ម្នាក់នៅជិតលោកប៉ាខ្ញុំនេះ....គឺ...លោកអ៊ំយុទ្ធប៉ាលោក!....ហើយម្នាក់នេះគឺ.... លោកអ៊ំហួត ស៊ីវ តើមែនទេ? »
នាងនិយាយសួរគេមួយៗទាំងអារម្មណ៍ មិននឹងនព្រោះរបៀបបើកឡានរបស់គេធ្វើឱ្យនាងភ័យតែក៏នៅភ័យមិន ដល់ទឹកមុខប្រែប្រួលចុះឡើងរបស់គេឡើយ។
យុត្តនាមិនឆ្លើយតែគេនិយាយប្រាប់នាងតិចៗ៖
«ប៉ានាងនិង ហួត ស៊ីវ ត្រូវគេចាប់ទៅកន្លែងតែមួយហើយ!»
«លោកថាម៉េច?»នាងសួរទាំងធ្លាក់ថ្លើមក្ដុក។
«រូបនេះរកឃើញនៅកន្លែងរបស់លេខាប៉េង មានឯកសារមួយចំនួនទៀត ដែលបង្ហាញថាតានោះមានគំនុំលាក់លួចជាមួយគ្រប់គ្នាក្នុងរូបនេះ !»
ស្រីតូចទន់ដៃជើងព្រោះមុននេះនាងរវល់តែកើតសេចក្ដីប្រចណ្ឌចេញមក ក្រៅទ្វារចោលគេបានជានាងមិនដឹងថាឯកសារអ្វីខ្លះរបស់លេខាប៉េង ត្រូវបានយុត្តនារុករកឃើញសោះ។
«រិទ្ធិក៏ប្រហែលដឹងរឿងនេះដែរបានជាគេបាត់ខ្លួនរហូតដល់ឥឡូវ! SMS ដែលផ្ញើមកមានឃ្លាថាឱ្យប្រយ័ត្នលេខាប៉េងនោះ ប្រហែលជារិទ្ធិជាអ្នកផ្ញើមកក៏ថាបាន ព្រោះបងស្រីនាងមិនស្គាល់លេខាប៉េងទេ!»

មកដល់ពេលនេះយុត្តនាយល់ហើយថាហេតុអ្វីនៅសុខៗក្មួយស្រីរបស់ គាត់ចង់នាំនាយទៅវិស្សមកាលនៅជប៉ុន។ គេរវេរ្នែកគិតរកវិធីផ្សេងៗតែមុនបង្អស់គេគឺគេពីសុវត្ថិភាពនាង ទោះដឹងថានាងនៅមិនទាន់អស់ចិត្តក្ដី។
គេនិយាយបន្ថែម ៖
«នៅថ្ងៃនោះ ថ្ងៃដែលប៉ានាងណាត់ខ្ញុំទៅនិយាយគ្នា បន្ទាប់មកគាត់ក៏គាំងបេះដូង ។នាងបានមករករឿងខ្ញុំ ថាខ្ញុំនិយាយបញ្ឈឺគាត់។ ប្អូនធម៌ខ្ញុំ ចង់ដឹងការពិត គេចេញទៅស៊ើបក្រោយមកគេបានដឹងថា កែវទឹកប៉ានាងមានគេលបដាក់ថ្នាំរំញោច ហើយក្មេងអ្នករត់តុម្នាក់បានប្ដូរវាចេញមុនពេលប៉ូលិសទៅដល់ ចំណែកក្មេងនោះពេលប៉ូលិសចាប់សួរ វាឆ្លើយដាក់លេខាប៉េងនេះដែរ! នាងគួរដឹងហើយថា តើម្នាក់នេះនឹងប៉ានាងមានគំនុំនឹងគ្នាកម្រិតណាពៅបញ្ញា!»
នារីគ្រវីក្បាលយឺតៗហួសនិស្ស័យនឹងជឿ គឺដូចកាលដែលគេធ្លាប់ប្រាប់នាងថា បងប្រុសធំនាងជាអ្នកលេងប៉ានាងពីក្រោយដូច្នោះដែរ គ្រាន់តែពេលនេះនាងហាក់ជឿសម្ដីគេជាងមុនបានជានាងមិនស្រែកមិន ប្រកែកមិនខឹងគេ។

ដោយទឹកមុខអន្ទះសានាងសួរគេបកវិញ៖
«គិតធ្វើម៉េច?? យើងប្ដឹងប៉ូលិសទៅ?»
គេនៅស្ងៀមបណ្ដោយឱ្យនាងរំងាប់ចិត្តបានបន្តិចទើបងាកមកពន្យល់នាងដោយវាចាទន់ភ្លន់៖
«ធ្វើអីមិនបានទាំងអស់! នាងនៅផ្ទះចាំខ្ញុំ! ខ្ញុំនឹងទៅដោះស្រាយរឿងអស់នេះខ្លួនឯង!»
ពៅបញ្ញាដំឡើងសំឡេងព្រោះនាងភ័យតក្កមា៖
«អត់ទេ! ឈប់និយាយដដែលៗ! បើអ្វីដែលលោករកឃើញនៅផ្ទះអំបាញ់មិញជាការពិត ខ្ញុំត្រូវការយករឿងទាំងអស់នេះទៅប្រាប់ប៉ូលិស!»

នាងកាន់តែគិតរឹតតែអន្ទះសា...ឯគេនៅតែមិនមាត់ ហើយបើកឡានលឿនស្លេវទៅមុខ។ នាងនឹកឃើញដល់សម្ដីគេដែលចេញមកពីផ្ទះនោះ គឺគេនៅមានចិត្តមកដៀមដាមនាងលេងថានាងប្រចណ្ឌគេជាមួយបុស្បានារី គិតទៅមានរឿងធំប៉ុណ្ណឹងគេនៅមកសប្បាយធ្វើមិនដឹងកើតទៀត ?នេះ ហេតុតែអ្នកដែលត្រូវលេខាប៉េងចាប់មិនមែនប៉ាគេ បងស្រីបានជាគេមិនព្រមអន្ទះសាប្ដឹងប៉ូលិស? គេនៅមានចិត្តលេងសើចបើកឡានធ្វើហីព្រោះគេស្អប់ប៉ានាងឃើញគាត់ កាន់តែគ្រោះថ្នាក់គេកាន់តែសប្បាយចិត្ត??
គិតឃើញកាលណាស្រីតូចសង្កត់ពាក្យដាច់ណាត់ដាក់គេ៖
«យុត្តនា! ខ្ញុំឱ្យលោកឈប់ឡានភ្លាម!»
បុរសងាកមកបម្រុងនិយាយតបនាង តែឃើញភ្នែកនាងមុតពេក ថ្ពាល់នាងក្រហមពេក អ្នកដឹងហើយថាភ្លើងកំពុងឆេះមានតែរកទឹកត្រជាក់មកពន្លត់មិនមែន ចាក់សាំងថែមឡើយ។... គេបន្ថយល្បឿន ហើយស៊ីញ៉ូអែបខាងសន្សឹមៗ។
បានដូចចិត្ត ធីតាអ្នកច្បាប់រៀបចំបើកទ្វារចុះពីលើរថយន្តគេនឹងអាលទៅធ្វើការ តាមចិត្តអន្ទះសារបស់នាង តែត្រូវបានយុត្តនាទាញដៃនាងជាប់ រលាស់យ៉ាងណាក៏មិនរលាព្រោះអ្នកចាប់បានត្រៀមលក្ខណៈរួចហើយថាគេ មិនឱ្យនាងទៅណាឡើយ។
«កុំទៅពៅបញ្ញា!»
«លែងខ្ញុំយុត្តនា! ប៉ាខ្ញុំ បងស្រីខ្ញុំអ្នកផ្ទះខ្ញុំបីបួននាក់កំពុងគ្រោះថ្នាក់ លោកដឹងអត់?!»
នាងថាផងមានះទាញបម្រះពីប្រអប់ដៃគេផង តែសំឡេងគេលាន់មកបន្ថែមបង្អាក់នាង៖
«អញ្ចឹងហើយបានជាខ្ញុំមិនចង់បាត់នាងម្នាក់ទៀត!»

នាងនៅទ្រឹងនិមិត្តតែឮសម្ដីនេះហើយសន្សឹមៗងាកមុខមករកគេ។
....ភ្នែកនាងរលោងតែនាងប្រឹងទប់...បបូរមាត់នាងញ័រច្នោះហើយនាងប្រឹងខាំវា....
«អគ្គទេសាភិបាល ហ្គូត ស៊ីវ ក៏ជាប៉ាធម៌របស់ខ្ញុំដែរពៅបញ្ញា! ច្រើនឆ្នាំមកនេះគាត់ជាអ្នកទំនុកបម្រុងមើលថែខ្ញុំ! ចុងក្រោយឱ្យតំណែងធំបង្អស់របស់គាត់ឱ្យមកខ្ញុំទៀត! នាងស្មានថាខ្ញុំនៅស្ងៀមមិនធ្វើអ្វីបានដែរ?»

ស្រីស្អាតស្រឡាំងកាំងចំពោះពាក្យថាគេជាកូនធម៌របស់បុរសនោះ ហើយរឹតតែនៅស្ងៀមនិយាយអីមិនចេញនៅពេលដែលយល់ថាគេក៏កំពុង អន្ទះសាតែគេកំពុងអត់ធ្មត់ណាស់ព្រោះក្នុងចំណោមអ្នករងគ្រោះក៏មានអ្នកមានគុណរបស់គេហើយគាត់ ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដូចគ្នា។
«នៅប្រលានយន្តហោះ ប៉ាធម៌ខ្ញុំបានផ្ញើសារឱ្យខ្ញុំផ្អាកទៅជប៉ុន! ខ្ញុំដឹងថាមានរឿងមិនស្រួលហើយព្រោះធម្មតាប៉ាខ្ញុំមិនដែលឃាត់ ខ្ញុំរឿងដើរលេងសើចទេ!»
នាងនៅស្ងៀម ក្នុងពេលគេសម្លឹងភ្នែកនាងហើយនិយាយបន្ត៖
«លេខាប៉េងតាំងរូបបុស្បានៅចុងជើងគាត់មិនមែនគាត់ជាទស្សនិកជន របស់នាងទេ គឺគាត់ជាពូរបស់នាងដែលចិញ្ចឹមនាងឱ្យរៀនសូត្រតាំងពីតូចមក! ក្រោយមកគាត់បានឱ្យនាងចូលមកកៀកនឹងខ្ញុំហើយរៀបគម្រោងនាំខ្ញុំ ចេញទៅជប៉ុន! តាមពិតគឺអញ្ចឹងសោះ! គេឆ្លៀតពេលខ្ញុំមិននៅចង់លេងប៉ាខ្ញុំ!»
ឮតែឈ្មោះបុស្បានាងរលាស់ដៃគេរបូតហើយងាកមុខចេញ៖
«ឱ្យស្រលះលោកទៅ! ឃើញគេស្អាតមិនបាន!»
នាងជ្រួញចិញ្ចើមងរង៉ក់ហើយងាកមុខចេញធ្វើឱ្យយុត្តនាអស់សំណើច។ នរះលើកហត្ថទាំងទ្វេទាញនាងមកវិញហើយឱនសម្លឹងមុខស្រីដែល ប្រែប្រួលម្ដងស្លាំងម្ដងក្រហម៖
«ហើយម៉េចដឹងគេស្អាត? តាមលបមើលគេ? ច្រណែនគេ?»
«ឆ្អន់ណាស់!»

នាងពេបមាត់ចំអកនាយហើយងាកមុខចេញតែគេមើលធ្លុះដល់បេះដូងនាង។ ក្មេងស្រីតូចទន់ខ្សោយឧស្សាហ៍ឈឺស្គមកំព្រឹង តែឆ្លាតវៃ កាលពីអតីតកាលនៅតែស្ថិតក្នុងបេះដូងបុរសឯកោ។នាងខ្ពង់ខ្ពស់យ៉ាងណា កាចឆ្នាសយ៉ាងណា មានះយ៉ាងណា នាងនៅតែមានអ្វីមួយទន់ភ្លន់អាថ៌កំបាំងដែលនាយយល់ថានាយមានសិទ្ធិ គ្រប់គ្រាន់នឹងគ្រប់គ្រងជីវិតនាង។ ពន្លឺ

ភ្នែកយុត្តនាសម្លឹងនាងយ៉ាងស្រទន់ខុសពីសម្ដីគំរាមកំហែង បង្ខំនាងឱ្យចាកចោលពីជប់លៀងមករកគេរហូតដល់របូតស្បែកជើងនិង បង្ខំនាងឱ្យចេញពីផ្ទះទាំងយប់មកជួបគេនៅ Apartment ជាន់ទី ៦ កាលពីពេលមុនព្រោះដើមឡើយគេយល់ថាឪពុកនាងជាមនុស្សអាក្រក់ជា មិត្តទ្រុស្តមិត្ត ដូច្នេះច្រើនឆ្នាំមកនេះកូនស្រីគាត់ដែលខ្ពស់ផុតដីមានរឿងអី នៅចំណាំបងប្រុសម្នាក់នេះបាន? ហើយអំនួតរបស់ពួកនាងហ្នឹងហើយដែលធ្វើឱ្យនាយចង់ជាន់ពន្លិច។ ដឹងអីថា ស្រីម្នាក់នេះនៅតែដដែល។ សញ្ញាប័ត្រនៅប្រទេសជឿនលឿននិងភាពជាអភិជនរបស់នាងមិនបានបិទបាំង ស្រទាប់បេះដូងទន់ភ្លន់ស្មោះត្រង់និងស៊ិចស៊ីរោលរាលគួរឱ្យគ្រឹត ក្ដាញ់នោះឡើយ។ ទីបំផុតអ្នកចូលទៅជាន់ពន្លិចគេបែរជាលិចខ្លួនឯងទៅក្នុងអន្លង់ស្នេហ៍ហែលមិនចង់រួច ហើយប្រចែប្រចណ្ឌសូម្បីតែឃើញ នាងនៅជាមួយប្រុសណាម្នាក់ សូម្បីតែខេមរិទ្ធិប្អូនធម៌របស់គេក្ដី។

ធីតាងើបមុខមករកអ្នកសាជាថ្មីនៅពេលដែលគេស្ងាត់ស្ងៀមយូរយ៉ាងនេះ។
សង្វាក់ដង្ហើមរបស់គេលាន់មកកំដរច្រមុះនាង....ខ្សែភ្នែកចាប់ផ្ដើម ពាក់ព័ន្ធគ្នាសាជាថ្មី ធ្វើឱ្យនាងក៏យល់ដែរថាអ្វីទៅកំពុងកើតឡើងក្នុងបេះដូងគេ។
យុត្តនានិយាយមួយៗទៅកាន់ស្រីស្អាត៖
«បើអ្នកដែលបាត់ខ្លួននៅហ្គ៉ាស់សាំងកាលពីព្រឹកមិញមិនមែនជា ប៉ែន ពេជ្រសក្ខណា ហើយបែរជានាងវិញ! នាងដឹងថាខ្ញុំនឹងឆ្កួតយ៉ាងណាដែរទេ?»
ស្រីតូចកាន់តែនិយាយអ្វីលែងចេញនៅពេលដែលឮវាចាត្រង់ៗអស់នេះ ចេញមកពីបបូរមាត់បុរសដែលធ្លាប់តែគ្រោតគ្រាតនិងបង្ខិតបង្ខំនាង។
នាងនៅធ្មឹងមិនមានអ្វីតបហាក់ទុកពេលឱ្យអ្នកប្រុសនិយាយបន្ត៖
«នាងដឹងថាពេលខ្ញុំឃើញSMSនេះ ដំបូងចិត្តខ្ញុំវេទនាយ៉ាងណាទេ? ហើយពេលខ្ញុំឃើញនាងនៅហ្គ៉ាសសាំងនោះចិត្តខ្ញុំត្រេកអរយ៉ាង ណាដែរ?»
នាងដកភ្នែកចេញពីគេវឹង ព្រោះលែងហ៊ានសម្លឹងគេតទៅទៀត។ ហេតុអ្វីគេដាច់ចិត្តនិយាយពាក្យអស់នេះចេញមក? កាលៈទេសៈជំរុញគេឬអ្វី?
នាងព្យាយាមនិយាយបន្លប់ដោយមិនមើលមុខគេទេ៖
«គ្មានអ្នកណាគេហ៊ានមកចាប់ខ្ញុំទេ! លោកស្មានតែខ្លួនឯង!»
យុត្តនាសើចខឹកចំអកឱ្យចរិតត្រង់ហួសរបស់នាង៖

«អូ! ឮហើយខ្លាចណាស់អ្នកនាងធំ! គេមានប៉ានាងក្នុងដៃ បងនាងក្នុងដៃគេ ដូចនាងហ្នឹងអ្វីគេតែមកឱ្យទៅ ស្មានថានាងហ៊ានប្រកែកពៅបញ្ញា???»
ស្រីតូចនៅស្ងៀមព្រោះទាល់គំនិត។
«នាងនៅផ្ទះចាំខ្ញុំ! ខ្ញុំនឹងដោះស្រាយរឿងនេះ!»

នាងងើបមុខសម្លឹងគេ។ តើប្រុសម្នាក់នេះគួរឱ្យទុកចិត្តបានទេ។ នាងនៅវាងចន្លោះសំណួរសំខាន់ពីរដែលមិនអាចឆ្លើយរួចសម្រាប់ចិត្ត ខ្លួនឯងនោះ គឺថាតើមនុស្សដូចគេដែលស្អប់ប៉ានាង អាចជួយប៉ានាងដើម្បីនាងដែរ? ហើយតើគេ ខ្លួនឯងអាចមានគ្រោះថ្នាក់ម្នាក់ទៀតទេ? បើសូម្បីតែជំនួយការរិទ្ធិដ៏ឆ្លាតវៃនិងរហ័សរហួនគង់តែបាត់ដំណឹង ស្ងាត់សូន្យ។
«យើងប្ដឹងប៉ូលិសទៅ!»
គេនៅស្ងៀម នាងនិយាយបន្ថែម៖
«ឮអត់យុត្តនា! យើងត្រូវធ្វើអ្វីតាមច្បាប់លោកដឹងអត់?»
គេធ្វើមុខស្មើបន្ទោសនាងខ្សឹបៗដោយមិនងាកសម្លឹងមុខ៖
«ស្រីល្ងង់! ចាស់ៗអស់នោះមិនដឹងមានរឿងអីនឹងគ្នាខ្លះទេ! ជាពិសេសប៉ានាង គាត់ធ្វើអាក្រក់ច្រើនណាស់មិនដឹងធ្លាប់ធ្វើអីប៉ះពាល់អាម្នាក់ នោះបានជាវាគុំកួនយ៉ាងនេះ! បើនាងនាំប៉ូលិសទៅ ដូចនាំ គេឱ្យចាប់ទាំងសងខាង!!! មុនពេលដឹងការពិតមិនត្រូវធ្វើឱ្យរឿងនេះលេចឮចេញទេ ! រៀនបានច្រើនគួរចេះគិតផង!»
ស្រីតូចសញ្ជឹងគិតទាំងក្តុកក្តាក់ក្នុងទ្រូង។
តើមានរឿងអ្វីបានជាខ្លួនសុខចិត្តចេញពីមន្ទីរពេទ្យទៅទាំងឈឺ ទាំងជាមានរឿងអ្វីទៅបានជាសូម្បីតែជំនួយការរិទ្ធិដ៏សកម្មនិង ក្លាហានជានិច្ចនៅសុខៗក៏បាត់ខ្លួន? បើប៉ូលិសឬបណ្ដាញព័ត៌មានដឹងរឿងនេះ កិត្តិយសគ្រួសារនាងត្រូវបាក់មុខដែរទេ? លើកនេះនាងគួរស្តាប់គេ ឬមួយក៏រកមធ្យោបាយដោយខ្លួនឯង។

ស្នូរទូរសព្ទគេ រោទ៍ឡើងបង្អាក់ចង្វាក់គំនិតរបស់នាង ....នាងងាកទៅឃើញគេលើកវាមកនិយាយ ហើយចុះចេញពីលើរថយន្តហាក់មិនចង់ឱ្យនាងបានឮការសន្ទនានោះក្នុង ពេលដែលនាងប្រឹងសម្លឹងតាមដានគេទាំងថប់បារម្ភ។
បុរសនេះឬដែលអាចដោះស្រាយទុក្ខលំបាករបស់យើងបានក្នុងពេលនេះ?
គេបែរកាយមកវិញតែនៅបន្តនិយាយទូរសព្ទនៅឡើយ។

ស្នាមញញឹមនឹងសេចក្តីសង្ឃឹមក្នុងពន្លឺភ្នែកគេ ធ្វើឱ្យនាងនឹកឃើញដល់រាត្រីមួយដែលនាងបានឡើងទៅរកគេនៅ Apartmentកម្ពុហោស៍។ គេធ្វើបាបនាងខ្លះតែគេអាចដោះស្រាយបញ្ហាដ៏ធំរបស់ប៉ានាង។ ឬមួយលើកនេះទៀតនាងត្រូវផ្ញើក្តីសង្ឃឹមលើគេជាជាងពឹងប៉ូលិស?

....គេទម្លាក់ទូរសព្ទចុះ ហើយដើរត្រលប់មកវិញ។ នាងចុះពីឡានយឺតៗដើរទៅរកគេ ....មេឃងងឹតសន្សឹមៗ...ជាសញ្ញាថារាត្រីកាលកំពុងឈានចូលមកដល់ហើយអ្វី ៗនៅលើផែនដីនេះត្រូវចុះចាញ់ការវាយប្រហារនិងបន្លាចដោយភាព ងងឹត...ចិត្តនាងក៏កំពុងនឹកដល់អ្នកមានគុណនិងអ្នកផ្ទះគ្រប់គ្នាដែល បាត់ខ្លួននោះជាខ្លាំងដែរ.....

....បុរសមាឌធំខ្ពស់ដើរមកប្រឈមនឹងនាង....គេនិយាយតិចៗដោយទឹកមុខស្ងួត៖

«ស្តាប់ខ្ញុំ!....ទៅផ្ទះ....ហើយរង់ចាំដំណឹងល្អពីខ្ញុំ!»

មិនរង់ចាំឱ្យនាងឆ្លើយទេ ព្រោះនាងកំពុងបើកភ្នែកមូលក្លុំសម្លឹងមកដោយរន្ធត់ ដូច្នេះអ្នកមានតែបន្លប់បេះដូងខ្លួនឯងដោយគេចបែរខ្នង ហើយដើរទៅបើកទ្វារឡានឱ្យនាងចូលទៅអង្គុយវិញ។ ដឹងអីដើរបានតែពីរជំហានសំឡេងនាងលាន់មករអាក់រអួល៖

«ក្រែងលោកថាស្រលាញ់ខ្ញុំមែនអត់?.....»

គឺសម្លឹងស្មាគេពីក្រោយនាងដឹងហើយថាគេទើបតែបានទទួលទូរសព្ទ អ្នកណាម្នាក់ទាក់ទងនឹងរឿងដែលទាក់ទងនឹងលេខាប៉េងនោះហើយបានជាគេ មិនឱ្យនាងស្តាប់ខ្លាចនាងភ័យ។ វាប្រាកដជារឿងមិនល្អដែលសូម្បីតែបងរិទ្ធិដ៏មាំទាំរបស់នាងក៏ ត្រូវបាត់ខ្លួនកុំថាឡើយគេគ្រាន់តែជាមនុស្សចិត្តស្លូយម្នាក់ដូច គេ។ ណាមួយគេមានរឿងអីក៏លាក់ក្នុងចិត្តមិននិយាយវាចេញ ក្នុងកាលៈទេសៈលំបាកបែបណានៅតែឌឺដងលេងជាមួយនាងយ៉ាងងាយស្រួល តើឱ្យនាងទុកចិត្តគេ សុខចិត្តទៅសំងំយកសុខម្នាក់ឯងកើតដែរ?។

មុននេះខ្លួនឯងគេ ចេះនិយាយដែរថាលេខាប៉េងមានប៉ានាងក្នុងដៃ តានោះចង់ហៅនាងឱ្យទៅ ក៏នាងមិនអាចប្រកែកបានចុះគេវិញប៉ាធម៌គេក៏នៅក្នុងដៃលេខាប៉េង ដូចគ្នាស្ថានភាពគេមានអីល្អជាងនាងទៅ?។ គេចេះតែដេញនាងឱ្យទៅផ្ទះម្តងជាពីរដងតើគេមានអ្វីលាក់លៀមនាង ? ឬមួយគេដឹងថាខ្លួនគេក៏មិនប្រាកដបានសុខបានជាគេមិនចង់ឱ្យនាង ទៅរងលំបាក?

«....មនុស្សស្រលាញ់គ្នាឯណា គេទៅចោលគ្នាក្នុងពេលពិបាកៗអញ្ចឹង?»

នាងនិយាយបន្ថែមទាំងរំជួលចិត្តធ្វើឱ្យនរៈទៅជាស្ងៀមទ្រឹងមិនដឹង ពន្យល់នាងយ៉ាងណា។ ស្នេហារបស់នាងចំពោះអ្នកបង្ហាញចេញមកកណ្តាលវាលរហូតដល់អ្នកមិនដឹង ឆ្លើយតបថា

យ៉ាងណាក្រៅពីហាបន្ទោសតិចៗទាំងពន្លឺភ្នែកអណ្ដែតអណ្ដូង ៖
«នាងឆ្កួតហើយមេធាវី!»